# បទានុក្រមធម្មបទ

ភាគទី ២

## ក-ង

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥៣៨ គ. ស. ១៩៩៤

ភាគទី ២ បទានុក្រមធម្មបទ

Websites: WatKhemaraRatanaram.org or WatKhmers.org

# ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " បទានុក្រមធម្មបទ " នេះ ត្រូវបានបោះពុម្ពឡើងវិញ ក្នុងឆ្នាំ ១៩៩៤ ដោយមានការឧបត្ថម្ភពីអង្គការជំនួយសូតូស៊ូជប៉ុន Japan Sotoshu Relief Committee (JSRC) និងមូលនិធិនៃតូយ៉ូតា (The Toyota Foundation) ។

គោលបំណងនៃការបោះពុម្ពឡើងវិញ ហើយចែកផ្សាយទូលាយទៅដល់មូលដ្ឋាន គឺសំដៅ :

- ផ្តល់អោយសិស្ស និងគ្រូ មានឧបករណ៍សំរាប់ស្រាវជ្រាវយ៉ាងល្អប្រសើរ ដើម្បីរៀន និងបង្រៀន ពោលគឺ មានមធ្យោបាយបកប្រែបាលីមកជាខ្មែរដោយខ្លួនឯងបានត្រឹមត្រូវ និងឆាប់រហ័ស ។

- រក្សាមរតិកវប្បធម៌ អក្សរសាស្ត្រសាសនា អក្សរសាស្ត្រជាតិអោយគង់វង្សឡើងវិញ និងរីកចំរើន ។

- ពង្រីកចំណេះចេះដឹងទូទៅខាងភាសាបាលី ដែលជាចំណែកមួយជួយទ្រទ្រង់ភាសា អក្សរសាស្ត្រ និងការប្រតិបត្តិពុទ្ធសាសនា ក្នុងភាពបរិសុទ្ធត្រឹមត្រូវ ក្នុងចំណោមពុទ្ធមាមកជន ទាំងនៅទីក្រុង ទាំងនៅជនបទ ។

ការបោះពុម្ពក្នុងគ្រាទី ២ នេះ ពុទ្ធសាសនបណ្ឌិត្យ រក្សាអត្ថន័យខ្លឹមសារ ព្រមទាំងអារម្ភកថារបស់អ្នករៀបរៀងទាំងស្រុង ហើយបោះពុម្ពផ្សាយតាមភាគនីមួយៗ ជាបន្តបន្ទាប់ ។

សូមឧទ្ទិសសៀវភៅ " បទានុក្រមធម្មបទ " នេះ ចំពោះការរីកចំរើនស្មារតីសិក្សា, ស្មារតីស្រឡាញ់ និង លើកស្ទួយអក្សរសាស្ត្រជាតិ ហើយជា

Websites: WatKhemaraRatanaram.org or WatKhmers.org

ពិសេស ស្មារតីបង្រួបបង្រួមជាតិ ដើម្បីសុខសន្តិភាពដ៏ស្ថិតស្ថេរ នៅកម្ពុជា ។

សូមព្រះពុទ្ធសាសនា បានចំរើនរុងរឿងស្ថិតស្ថេរ ជាស្ថាពរ !

សូមជនានុជនក្នុងកម្ពុជរដ្ឋ បានចំរើនល្អតលាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេសជាតិ និងលើកស្ទួយព្រះពុទ្ធសាសនា អោយបានរីកចំរើនជាភិយ្យោភាព តរៀងទៅ !

ដោយអានុភាពនៃកុសលកម្មនេះ សូមអោយវិញ្ញាណក្ខន្ធ របស់ព្រះគ្រូ សិរីសោភ័ណ កិម ត្រូវ បានសំរេចឥដ្ឋមនុញ្ញផលគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការជំនួយសូតូស្ទ៊ូជប៉ុន និង អង្គការតូយ៉ូតាហ្វោនដេហ្សិន ដែលបានជួយឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តមដល់ការបោះពុម្ពសៀវភៅនេះ ។

*ភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ព.ស ២៥៣៨ គ.ស ១៩៩៤*

**ពុទ្ធសាសនបណ្ឌិត្យ**

Websites: WatKhemaraRatanaram.org or WatKhmers.org

# អារម្ភកថា

សៀវភៅបទានុក្រមធម្មបទភាគទី២នេះ ខ្ញុំបានរៀបរៀងហើយស្រេច តាំងពីឆ្នាំ១៩៥១ម្ល៉េះ បំរុងនឹងឱ្យឡើងកាន់ពុម្ពក្នុងរវាងបន្ទាប់គ្នានឹងបទានុក្រមធម្មបទភាគទី១ដែរ ប៉ុន្តែមិនស្រេច ដោយមានឧបសគ្គចូលមកបង្អាក់ដំណើរ បានជានាំឱ្យយឺតយូរបរហូតមកដល់ពេលនេះវិញ ។ ការបោះពុម្ពភាគទី២នេះ ក៏ដោយសារលោកជាសិក្ខាកាមកុលបុត្រ ទាំងភិក្ខុ ទាំងសាមណេរ ដែលធ្លាប់បានយកភាគទី១ ទៅអាន សិក្សាហើយ ឃើញថាមានប្រយោជន៍ ដ៏សំខាន់ក្នុងវិធីរៀនភាសាបាលី ក៏នាំគ្នាទន្ទឹងចាំមើលភាគទី២ និងភាគទី៣ ទៀត ។ ដោយអាស្រ័យហេតុនេះឯង ដែលនាំឱ្យខ្ញុំអត់ទ្រាំពុំបាន ក៏ខំពិនិត្យរៀបចំសំណៅនោះ រួចហើយប្រគល់ឱ្យទៅគេចាត់ការបោះពុម្ព ដើម្បីបំពេញបំណងរបស់អស់លោកអ្នកត្រូវការ ។

ឯយោបល់ និង គោលបំណងរបស់ខ្ញុំក្នុងការរៀបរៀងសៀវភៅនេះ យ៉ាងណាៗនោះ ខ្ញុំបានពណ៌នាទុកក្នុងអារម្ភកថាភាគទី១ រួចហើយ ។ ក្នុងទីនេះ គ្រាន់តែប្រាប់ថា មេពាក្យដែលប្រើក្នុងភាគទី២នេះ គឺកំណត់ពីអក្សរ ក ដល់ ន, ដល់ទៅភាគទី៣ ខាងមុខ ពីអក្សរ ប ដល់ ឡ ។ អ្នករៀន កាលបើបានមើលបាលីក្នុងធម្មបទទាំង៨ភាគ ភាគណាមួយ ឃើញស័ព្ទណាដែលទើសទាក់ នឹងគំនិតរបស់ខ្លួន មិនយល់ពាក្យប្រែ និងធាតុ, បច្ច័យ ឬ វិគ្គហៈ . ល . ចូរបើករកតាមលំដាប់បទអក្សរទៅ គង់នឹងប្រទះឃើញភ្លាមៗ ទាន់ចិត្តបំណងរបស់ខ្លួន ។

មួយទៀត សូមអស់លោកដែលត្រូវការប្រែស័ព្ទនិមួយៗ តោងលៃតម្រូវទៅតាមដំណើរសេចក្ដីក្នុងរឿងនោះៗផង កុំប្រកាន់យកតែមួយបែប ពីព្រោះ ក្នុងសៀវភៅនេះ មានបាលីខ្លះប្រែតែមួយយ៉ាង ខ្លះប្រែច្រើនយ៉ាង

Websites: WatKhemaraRatanaram.org or WatKhmers.org

ដូចជា អនុភវតិ<អនុ+ភូ+អ+តិ = បើប្រែតាមរូបបុព្វបទ និងធាតុថា" កើតតាម ឬមានតាម, កើតរឿយៗ ឬមានរឿយៗ" អភិភវតិ< អភិ+ភូ+អ+តិ = បើប្រែតាមរូបបុព្វបទ និងធាតុថា" កើតចំពោះ ឬមានចំពោះ" ប៉ុន្តែគេមិនសូវប្រែដូច្នេះទេ ពីព្រោះដោយអំណាចស័ព្ទជាបុព្វបទនៅសង្កត់ពីខាងមុខ អាចបំបែរធាតុឱ្យប្រែផ្សេងពីនេះគឺ អនុភវតិ ថា" រង " ថា" សោយ", អភិភវតិ ថា" គ្របសង្កត់, ជិះជាន់, រំលោភ " ដូច្នេះវិញ ។ បទដទៃក្រៅពីនេះ ដូចយ៉ាងកិរិយាស័ព្ទក្តី នាមស័ព្ទជាបទសមាសក្តី តទ្ធិតក្តី សាធនកិតកៈក្តី គប្បីលៃលកប្រែអនុវត្តទៅតាមដំណើរសេចក្តីក្នុងផ្ទៃរឿងនោះៗ ដូចគ្នាដែរ ។ មួយវិញទៀត អ្នកដែលមានយោបល់យល់ច្រើន មិនសូវមើលទាក់ក្នុងវិធីប្រែប្រយោគបាលី ហើយអាចប្រែដោយរូសរ៉ាវទៅបាន អាស្រ័យដោយអង្គ ៣ យ៉ាង គឺ ១ - ចាំយល់បាលីវេយ្យាករណ៍ច្រើន, ២ - យល់របៀបបាលីដែលគេរៀងទៅជាប្រយោគមួយៗ ក្នុងវាចកៈទាំង៥ មានកត្តុវាចកៈជាដើម, ៣ - យល់ដំណើរសេចក្តីក្នុងផ្ទៃរឿងនោះៗ ជាក់ច្បាស់; បណ្តាអង្គទាំង៣យ៉ាងនេះ បើអ្នកប្រែខ្វះអង្គណាមួយហើយ មិនអាចនឹងប្រែឱ្យត្រឹមត្រូវអស់ជើង ទៅបាន រមែងមានការភ្លាត់ខុសខ្លះមិនខាន បើមិនច្រើនក៏តិចដែរ ។

ការរៀបរៀងសៀវភៅនេះ ខ្ញុំមិនមែនប្រកាន់មានះថាឥតភ្លាំងភ្លាត់ឥតឆ្គងសោះនោះទេ គង់មានខ្លះ ព្រោះការធ្វើរបៀបបែបនេះ ស្ទើរតែហួសវិស័យរបស់ខ្ញុំទៅហើយ ហេតុនេះ ខ្ញុំសុំផ្ញើសេចក្តីភ្លាំងភ្លាត់ គ្រប់បទណានិមួយ ដោយក្រែងតំនិតខ្ញុំដើរទៅមិនដល់នោះ ចំពោះលោកជាវេយ្យាករណ-បណ្ឌិត ក្នុងបច្ចុប្បន្ននេះ និងអនាគត សូមឱ្យជួយតម្រង់ដោយសុទ្ធចិត្តផងតែកុំមើលរិះគន់ដោយអសុទ្ធចិត្ត ជាហេតុនាំឱ្យរំខានប្រយោជន៍ ព្រោះថា ក្នុង

Websites: WatKhemaraRatanaram.org or WatKhmers.org

លោកទាំងមូល តាមតែកិច្ចការអ្វីក៏ដោយ អ្នកធ្វើរមែងតែមានការភ្លាំងភ្លាត់ខុសខ្លះ ជាធម្មតា ឯការគ្មានភ្លាត់ខុសសោះនោះ ចំពោះតែអ្នកដែលមិនធ្វើអ្វីប៉ុណ្ណោះ ។

ទីបំផុតនៃអារម្ភកថានេះ ខ្ញុំសូមឧទ្ទិសកុសលដែលកើតអំពីកម្លាំងព្យាយាមក្នុងការរៀបរៀងសៀវភៅនេះ ជូនចំពោះលោកជាបុព្វការីទាំងឡាយមានមាតាបិតារបស់ខ្ញុំជាដើម ។ ដោយអានុភាពនៃកុសលនេះ សូមឱ្យអស់លោកជាបុព្វការីទាំងអំបាលនោះ បានសម្រេចឥដ្ឋមនុញ្ញផលគ្រប់ប្រការ កុំបីឃ្លៀងឃ្លាត ! សូមឱ្យប្រជាជនក្នុងកម្ពុជរដ្ឋទាំងមូលបានសន្តិភាព ព្រមទាំងបានចម្រើនល្អលាស់ដុះដាលដោយវិទ្យា និងវិបុលសុខគ្រប់ប្រការ កុំបីឃ្លាតក្លាយទៅជាប្រការដទៃឡើយ ! ។

វត្តឧណ្ណាលោម, ថ្ងៃពុធ ៦ រោច ខែបឋមាសាឍ ឆ្នាំមមែ បញ្ចស័ក
ព.ស. ២៤៨៦ ត្រូវនឹងថ្ងៃទី១ កក្កដា គ.ស. ១៩៤៣

ព្រះទេពសត្ថា ភិម - ភូរ ( ចន្ទមង្គលោ )

# អក្សរសង្ខេប

## ប្រើក្នុងវចនានុក្រមធម្មបទនេះ

| | | |
|---|---|---|
| វិ.ស.អ. | គឺ | វិសេសនសព្ទនាមអនិយមៈ |
| អ.ស. | - | អព្យយសព្ទនាម |
| កិ.វិ. | - | កិរិយាសព្ទវិសេសនៈ |
| ប. សំ. | - | បកតិសំខ្យា |
| បូ.សំ. | - | បូរណសំខ្យា |
| បុំ. | - | បុំលិង្គ |
| ឥ. | - | ឥត្ថីលិង្គ |
| នបុំ. | - | នបុំសកលិង្គ |
| គុ. | - | គុណ ឬ គុណនាម |
| កិ. | - | កិរិយា ឬ កិរិយាសព្ទ |
| អ. | - | អព្យយកិរិយា ឬ អព្យយសព្ទ |
| វិ.ស.និ. | - | វិសេសនសព្ទនាមនិយមៈ |
| និ. | - | និបាត |
| កា. ស. | - | កាលសត្តមី |
| ឥ. អា. | - | ឥ. អាគម |
| ឋា.អា. | - | ឋា. អាគម |
| ស.អា. | - | ស.អាគម |
| អា.ឥ. | - | អា.ឥត្ថីលិង្គ |
| ក.ស. | - | ក.សកត្តៈ |

Websites: WatKhemaraRatanaram.org or WatKhmers.org

| | | |
|---|---|---|
| អា.និ. | គឺ | អាលបននិបាត |
| សិ.វិ. | - | សិ. វិភត្តិ |
| តិ.វ. | - | តិ. វត្តមានា |
| តុ.ប. | - | តុ.បញ្ចមី |
| ឯយ្យ.ស. | - | ឯយ្យ.សត្តមី |
| អ. បរោ. | - | អ. បរោក្ខា |
| អា. ហី. | - | អា. ហីយត្តនី |
| ឦ - អជ្ជ. | - | ឦ - អជ្ជត្តនី |
| ស្សតិ.ភ. | - | ស្សតិ.ភវិស្សន្តិ |
| ស្សា.កា. | - | ស្សា. កាលាតិបត្តិ |
| និ. អា. | - | និគ្គហិត អាគម |
| វិ. | - | វិគ្គហៈ |
| សំ. ស. | - | សំខ្យាសព្វនាម |
| ឧ. ស. | - | ឧបសគ្គ |
| យ. អភិ. | - | យោជនាអភិធម្មត្ថវិភាវិនី |
| អ. សុ. | - | អដ្ឋកថា សុត្តន្តបិដក |
| ដី. វិ. | - | ដីកាវិសុទ្ធិមគ្គ |
| អ. វិ. | - | អដ្ឋកថាវិន័យ |
| ណិក.ស. | - | ណិក. សកត្ថៈ |
| អ. ន. | - | អសាធារណនាម |
| ត្ថ - ហី. | - | ត្ថ. ហីយត្តនី |
| អភិ. សុ. | - | អភិធានប្បទីបិកាសូចិ |

Websites: WatKhemaraRatanaram.org or WatKhmers.org

| | | |
|---|---|---|
| យ. វិ. | គឺ | យោជនាវិន័យ |
| បុ. ស. | - | បុរិសសព្វនាម |
| អ. និ. | - | អព្យយនិបាត ឬ មោនត្ថវាចកនិបាត |
| កា. និ. | - | ការណត្ថវាចកនិបាត |
| លិ. វិ. | - | លិង្គវិបល្លាស |
| ក. ក. | - | កត្តុរូប កត្តុសាធន |
| ស. ត. | - | សមាសរូប តស្សីលសាធន |
| អា. ន. | - | អាលបននាម |
| បុ. និ. | - | បុច្ឆនត្ថវាចកនិបាត |

Websites: WatKhemaraRatanaram.org or WatKhmers.org

# បទានុក្រមធម្មបទ

## ក

**កកុជបាទ** គុ. [ កកុជ+បាទ ] មានជើងដូចជាជើងនៃព្រាប; វិ. កកុជស្ស បាទា> កកុជបាទា, កកុជបាទា ឥវ បាទា យេសំ តានិ> កកុជបាទានិ ។

**កកុធរុក្ខ** ចុំ. [ កកុធ+រុក្ខ ] ដើមនៃថ្កាន់, ដើមថ្កាន់ ។

**កកុសន្ធ** អ.ន. ព្រះពុទ្ធទ្រង់ព្រះនាមកកុសន្ធៈ ។

**កក្កដក** ចុំ. [ ក+កដ+អ+ក_ស. ] សត្វហាមនូវភ្លៀង (ក្ដាម); វិ. កំ ចស្សំ កដតីតិ> កក្កដកោ ។

**កកស** គុ. [ ករ+អស ] អាក្រក់, ទ្រគោះ, គ្រោតគ្រាត (វិ. កិច្ចំសំ ករោតីតិ> កក្កសោ) ។

**កក្ខល** គុ. [ កក្ខ+អល ] របឹង, រឹងរូស, អាក្រក់,... ។ . តា ឥ. ភាវៈនៃ...នោះជា...រឹងរូស ។ . កម្ម នចុំ. កម្មដ៏រឹងរូស, អំពើដ៏អាក្រក់ ។ ប្រើជា **កក្ខឡ** ក៏មាន ។

**កង្ខា** ឥ. [ កង្ខ+អ+អា_ឥ. ] សេចក្ដីសង្ស័យ; វិ. កង្ខនំ> កង្ខា ។ ធម្មជាតិជាគ្រឿងសង្ស័យ; វិ. កង្ខតិ ឯតាយាតិ> កង្ខា ។ . **ឆេទន** នចុំ. កិរិយាកាត់នូវសេចក្ដីសង្ស័យ ។

**កចវរ** ចុំ. [ កច+វរ+អ ] សម្រាម (វិ. នានាវិធេ សង្ការេ វាសិ. ករណវសេន កចតិ ពន្ធតីតិ> កចោ, សោ ឯត្ថ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឥច្ចិកព្យោតិ> កចចវោ) ។ . ឆឌ្ឌិក, កា, គុ. សម្រាប់ចាក់ចោលនូវសម្រាម, អ្នកចាក់ចោលនូវសម្រាម; វិ. កចចរំ ឆឌ្ឌេតីតិ> កចចរឆឌ្ឌិកា ។ . រាសិ ចុំ. គំនរនៃសម្រាម ។

កច្ចាន អ.ន. [ កច្ច+ណាន ] ភិក្ខុជាពូជពង្សនៃកច្ចៈ (ភិក្ខុឈ្មោះកច្ចៈ); វិ. កច្ចស្ស អបច្ចំ> កច្ចានោ ។ អបច្ច = កូន, កូនចៅ, ជាសាធារណនាម នចុំ.

កច្ចិ ចុ. និ. និបាតប្រាប់សេចក្ដីសួរ, ដណ្ដឹង ប្រែថា «ឬ,ដែរឬ,ទេឬ, ខ្លះដែរឬ» ។

កច្ឆ ចុំ., នចុំ. [ កច+ឆ ] ប្រទេសដែលជនចង (ក្បិន, កន្ទុយក្បិន, ក្បៀក); វិ. កចិយតិ ពន្ធិយតីតិ> កច្ឆោ, កច្ឆំ ។

កច្ឆប ចុំ. [ កច្ឆ+បា+ក្វិ ] សត្វផឹក (នូវទឹក) តាមក្បៀក (អណ្ដើក); វិ. កច្ឆេន (ឧទកំ) បិវតីតិ> កច្ឆបោ ។ . ណ្ឌ នចុំ. ពងនៃអណ្ដើក, ស៊ុតនៃអណ្ដើក ។

កច្ឆុ នចុំ. [ កស+ឆុ ] រោគជាតជាទីអេះ (ខ្ទារ, ខ្ទាំ) នៃជន (រមាស់, ខ្ទួរ); វិ. កសន្តិ ចិលេខន្តិ ឯត្ថាតិ> កច្ឆុ ។ . បរិកិណ្ណ គុ. ដេរដាសដោយរមាស់, ស្អេកស្កាស់ដោយរមាស់ ។ . ចុណ្ណ នចុំ. លំអិតនៃខ្ទួ, ផង់នៃខ្ទួ ។

កញ្ចនថូប ចុំ. [កញ្ចន+ថូប ] ស្តូបជាវិការៈនៃមាស ឬ ស្តូបដែលជនធ្វើ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយដោយមាស; វិ. កញ្ចនស្ស ថិការោ ថូបោ> កញ្ចនថូបោ, កញ្ចនេន កតោ វា ថូបោ> កញ្ចន-ថូបោ ។ ប្រើជា កាញ្ចន ក៏មាន ។

**កញ្ជិក** នថុំ. [ ក+អញ្ជ+ឥក ] ទឹកបាយ, បាយចុងអង្ករ ។ - តេល នថុំ. ទឹកបាយនិងប្រេង, ប្រេងដ៏លាយដោយទឹកបាយ ។ - មត្ត គុ. វត្ថុត្រឹមតែទឹកបាយ, វត្ថុត្រឹមតែទឹកបាយចុងអង្ករ ។

**កដកដាយតិ** កិ. [ កដកដ+អាយ+តិ.វ. ] ប្រព្រឹត្តនូវសម្លេងថាកដកដះ ។

**កដច្ឆុ** ថុំ. [ កដ+ឆុ ] វែក, ស្លាបព្រា ។ - **ភិក្ខា** ឥ. បាយមានវែកជាប្រមាណ, បាយមួយវែក ។ - **ភិក្ខាទានវស** ថុំ. អំណាចនៃកិរិយាឱ្យនូវបាយមួយវែក ។ - **ភិក្ខាមត្តទាន** នថុំ. កិ.ឱ្យនូវវត្ថុត្រឹមតែបាយមួយវែក ។ - **ភិក្ខាមត្ត** គុ. វត្ថុត្រឹមតែបាយមួយវែក, វត្ថុមានបាយមានវែកមួយជាប្រមាណ ។ - **មត្ត** គុ. ត្រឹមតែមួយវែក, មានវែកមួយជាប្រមាណ ។

**កដសារក** ថុំ. [ កដ+សរ+ណ្វុ ] កន្ទេល, កន្ទេលផែង, ថែប ។

**កដាហក** អ.ន. បុរសឈ្មោះ កដាហក, ទាសះ(ខ្ញុំ)ឈ្មោះកដាហកៈ ។ - **ជាតក** នថុំ. ជាតកគឺបណ្ឌិតកំណត់ដោយទាសះឈ្មោះកដាហកៈ ។

**កដិ** ឥ. [ កដ+ឥ ] ធម្មជាតិដែលគេបិទបាំងដោយវត្ថុមានសំពត់ជាដើម (ចង្កេះ, ត្រគាក); វិ. កដីយតេ អាវរិយតេ វត្ថាទីហីតិ> កដិ ។ - **ប្បទេស** ថុំ. ប្រទេសនៃចង្កេះ ។ - **ប្បមាណ** នថុំ. ប្រមាណនៃចង្កេះ, ប្រមាណត្រឹមចង្កេះ, គុ. មានចង្កេះជា

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រមាណ ។

**កដុក** គុ. [ កដ+ណ្ហុ ] ហឹរ, ហឹរក្តៅ, ផ្សាក្តៅ, ក្តៅផ្សា ។ - **ភណ្ឌ** នបុំ. ភណ្ឌៈដ៏ហឹរក្តៅ, ភណ្ឌៈក៏ក្តៅផ្សា, គ្រឿងទេស ។ - **វិបាក** គុ. មានវិបាកដ៏ក្តៅផ្សា, មានផលដ៏ផ្សាក្តៅ ។ - **ប្បភេទន** គុ. មានប្រេងជាគ្រឿងបែកខ្ទេចទៅដ៏ផ្សាក្តៅ (ចុះប្រេងដ៏ផ្សាក្តៅ) ។ - **ប្ផល** គុ. មានផលដ៏ផ្សាក្តៅ ។

**កដ្ឋ** នបុំ. [ កាស ឬកស+ត ] ធម្មជាតរុងរឿងដោយភ្លើង ឬ ធម្មជាតវិនាសដោយភ្លើង (ឈើ, ឱស); វិ. **កាសតេ អគ្គិនា ទិប្បតេតិ> កដ្ឋំ, កសតិ អគ្គិនា វិនាសតីតិ វា> កដ្ឋំ** ។ - **កលិង្គរ** នបុំ. ឈើនិងអង្កត់ឱស (អង្កត់ឱស) ។ - **ខណ្ឌ** នបុំ. កំណាត់នៃឈើ ។ - **អង្គរុក្ខ** បុំ. ឈើជាអវយវៈនៃឱស ។ - **ត្ថរ** គុ. ទីជាទីក្រាលដោយឈើ, កម្រាលជាវិការៈនៃឈើ ។ - **បាទុកា** ឥ. ទ្រនាប់ជើងជាវិការៈនៃឈើ, ស្បែកជើងជាវិការៈនៃឈើ ។ - **វាហនរាជ** បុំ. ស្តេចព្រះនាមកដ្ឋវាហនៈ ។ - **ហត្ថី** បុំ. ដំរីជាវិការៈនៃឈើ; វិ. **កដ្ឋស្ស វិការោ ហត្ថី> កដ្ឋហត្ថី** ។ ដំរីដែលគេធ្វើហើយដោយឈើ; វិ. **កដ្ឋេន បកតោ ហត្ថី> កដ្ឋហត្ថី** ។ - **ហារិកា** ឥ. [ ហរ+ណ្ហុ+ឥ_អា.+អា_ឥ. ] អ្នកនាំទៅនូវឈើ, អ្នកនាំទៅនូវឱស; វិ. **កដ្ឋានិ ហរតីតិ> កដ្ឋហារិកា** ។ - **ហារិយជាតក** នបុំ. ជាតកតីបណ្ឌិតកំណត់ហើយដោយបុគ្គលអ្នកនាំទៅនូវឱស ។

**កឌ្ឍន្ត** គុ. [ កឌ្ឍ+អ+អន្ត ] កាលទាញទៅ, កាលយឺត, កាលកន្ត្រាក់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កឌ្ឍិ** កិ. [ កឌ្ឍ+អ+ឦ_អជ្ជ. ] ទាញហើយ, យឺតហើយ, កន្ត្រាក់ហើយ ។

**កឌ្ឍិតុំ** អ. [ កឌ្ឍ+ឥ_អា.+តុំ ] ដើម្បីទាញទៅ, ដើម្បីយឺត, ដើម្បីកន្ត្រាក់ ។

**កណិការ** បុំ. [ កណ+ករ+ណ ] ឈើកណិការ, ផ្កាកណិការ; (វិ. **អគន្ធបុប្ផកាយ អក្កានំ កណិជ្ជំ ករោតីតិ> កណិការោ**) ។ - **បុប្ផរាសិ** បុំ. គំនរនៃផ្កាកណិការ ។

**កណេរុកា** ឥ. [ កណ+ឥរុ+ក_ស.+អា_ឥ. ] មេដំរី ។ ប្រើជា **ករេណុកា** ក៏មាន ។

**កណេរុ** បុំ. [ កណ+ឥរុ ] ដំរី, ដំរីឈ្មោល (ន័យខ្លះថា ឥ. មេដំរី) ។ - **បិដ្ឋ** នបុំ. ខ្នងនៃដំរី, ខាងក្រោយនៃដំរី ។

**កណ្ដក** បុំ. កន្លា, ឈើមានបន្លា ។ - **ឧទ្ធរណ** នបុំ. [ ឧ+ធរ+យុ ] កិ.ដកឡើងនូវបន្លា, កិ.ដោះនូវបន្លា ។

**កណ្ថក** អ.ន. សេះឈ្មោះកណ្ថកៈ ។

**កណ្ឌ** នបុំ. [ កណ+ឌ ] វត្ថុជាគ្រឿងដែលជនបាញ់ទៅ (ព្រួញ, កូនសរ); វិ. **កណិយតេ ខិបិយតេ ឯតេនាតិ> កណ្ឌំ** ។

**កណ្ឌុវណដ្ឋាន** នបុំ. [ កណ្ឌុវណ+ឋាន ] ទីជាទីអេះ, ទីជាទីតាំងនៃកិ.អេះ (ខ្លះថា ទីមានដំបៅដ៏រមាស់); **កណ្ឌុវណ**<កណ្ឌុ+យុ, ផ្លាស់អនៃកណ្ឌុ>ឧវ, ផ្លាស់យុ>អន>អណ ។

**កណ្ឌុវន្តិ** តុ. ឥ. [ កណ្ឌុ>កណ្ឌុវ+អន្ត+ឦ ] កាលអេះ, កាលខ្វាំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កណ្ណ** ថុំ. [ ករ+ណ ] អវយវៈជាគ្រឿងស្តាប់ ឬឬនៃជន (ត្រចៀក ឬស្លឹកត្រចៀក); វិ. **កណ្ណតិ សុណាតិ ឯតេនាតិ> កណ្ណោ** ។ កន្លែងខ្លះប្រែថា «ជ្រុំ, ជាយ, ជ្រុង ។ - **ចូឡិកា** ឥ. គុម្ពនៃត្រចៀក, គល់នៃត្រចៀក ។ - **នាសា** ឥ. ត្រចៀកនិងច្រមុះ ។ - **បិដ្ឋិ** ឥ. ខ្នងនៃត្រចៀក ។ - **មូល** នថុំ. ប្រទេសជាទីតាំងនៃត្រចៀក, ជិតនៃត្រចៀក, គល់នៃត្រចៀក ។ - **វិជ្ឈន-មង្គលាទិ** គុ. (មង្គល) មានមង្គលជាទីចោះនូវត្រចៀកជាដើម, មានមង្គលគឺបុគ្គលគប្បីធ្វើក្នុងកាលជាទីចោះនូវត្រចៀកជាដើម ។ - **វិជ្ឈនមង្គល** នថុំ. មង្គលជាទីចោះនូវត្រចៀក ។ - **សក្ខលិ** ឥ. គុម្ពនៃត្រចៀក ។ - **សោត** នថុំ. ប្រហោងនៃត្រចៀក, រន្ធនៃត្រចៀក ។

**កណ្ណិកា** ឥ. [ កណ្ណ+ណិក ] ហោជាង, ជព្យា ។ - **មណ្ឌល** នថុំ. មណ្ឌលនៃហោជាង ។ - **រុក្ខ** ថុំ. ឈើសំរាប់ធ្វើនូវហោជាង ។ - **ពទ្ធ** គុ. ដែលបុគ្គលចងឱ្យជាចង្កោម, ជាប់គ្នាដោយចង្កោម ។ - **អារោបនទិវស** ថុំ, នថុំ. ថ្ងៃជាទីលើកឡើងនូវហោជាង ។

**កណ្ណិការ** ថុំ. [ កណ្ណ+ករ+ណ ] ឈើកណិការ, ផ្កាកណិការ (វិ. ចូរមើល «កណិការ») ។ - **បុប្ផទាមសទិស** គុ. ប្រាកដស្មើដោយកម្រង (ចង្កោម, ភួង) នៃផ្កាកណិការ ។ - **បុប្ផបទុមបុប្ផាទិ** គុ. (ផ្កា) មានផ្កានៃកណិការនិងផ្កានៃឈូកជាដើម ។

**កណ្ហ** គុ. [ កសឬកុ+ណ្ហ ] ខ្មៅ, គោឈ្មោះកណ្ហៈ ។ - **ឧសភជាតក**

Websites: WatKhemaraRatanaram.org or WatKhmers.org

នចុំ. ជាឥតកគឺបណ្ឌិតកំណត់ដោយគោឧសភឈ្មោះកណ្ហៈ ។

**កណ្ហាជិនាសទិស** គុ. [ កណ្ហាជិនា+សទិស ] ប្រាកដស្មើដោយកុមារីឈ្មោះកណ្ហាជិនា ។

**កត** គុ. [ ករ+ត ] គឺ...ធ្វើហើយ; វិ. **ករិយិត្ថាតិ > កតោ, កតា, កតំ** ។ - **ឧបដ្ឋាននិស្សន្ទ** ចុំ. វិបាកជាគ្រឿងហូរចេញនៃកិ. បំរើគឺ....ធ្វើហើយ, អានិសង្សនៃកិ.បំរើគឺ....ធ្វើហើយ ។ - **កម្មវស** ចុំ. អំណាចនៃកម្មគឺ....ធ្វើហើយ ។ - **កម្ម** នចុំ. កម្មគឺ...ធ្វើហើយ; គុ. មានកម្មគឺ....ធ្វើហើយ, មានកម្មធ្វើហើយ ។ - **កល្យាណ** គុ. មានកម្មគឺបណ្ឌិតគប្បីរាប់ធ្វើហើយ, មានអំពើដ៏ល្អធ្វើហើយ ។ - **កិច្ច** គុ. មានកិច្ចធ្វើហើយ ។ - **កិរិយា** ឥ. កិរិយាគឺ...ធ្វើហើយ ។ - **គន្ធបរិភណ្ឌ** គុ. មានកិ.ប្រោះព្រំដោយវត្ថុមានក្លិនធ្វើហើយ ។ - **ចិត្តក** គុ. មានវិចិត្រធ្វើហើយ, មានកម្មដ៏វិចិត្រគឺ....ធ្វើហើយ ។ - **ចិត្តកម្ម** គុ. មានកម្មដ៏វិចិត្រគឺ...ធ្វើហើយ, មានគំនូរធ្វើហើយ ។ - **ដ្ឋាន** នចុំ. ទីនៃ....គឺ....ធ្វើហើយ ។ - **ត្ត** នចុំ. ភាវៈនៃ....ជា...គឺ....ធ្វើហើយ ។ - **ទាន** នចុំ. ទានគឺ....ធ្វើហើយ ។ - **និយាម** ចុំ. ហេតុជាគ្រឿងកំណត់នៃ.....គឺ....ធ្វើហើយ, ទំនងនៃ....គឺ....ធ្វើហើយ ។ - **បច្ចុត្តមន** គុ. មានកិ.ក្រោកទទួលធ្វើហើយ; វិ. **កតំ បច្ចុត្តមនំ យេន សោ> កតបច្ចុត្តមនោ** ។ - **បដិសន្ថារៈ** គុ. មានបដិសន្ថារៈធ្វើហើយ, មានវាចៈជាគ្រឿងរៀបរៀងព្រមចំពោះធ្វើហើយ ។ - **បដិសម្មោទន** គុ. មាន

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្ដីរីករាយព្រមចំពោះធ្វើហើយ ។ - **បត្តបូជ** គុ. មានសំបុក (កញ្ចប់) នៃស្លឹកគឺ...ធ្វើហើយ ។ - **បរិច្ចាគ** ចុំ. កិ. លះបង់គឺ... ធ្វើហើយ; គុ. មានការបរិច្ចាគធ្វើហើយ ។ - **បាតរាស** គុ. មានភោជនគឺបុគ្គលគប្បីស៊ីក្នុងវេលាព្រឹកធ្វើហើយ; វិ. **បាតោ អសិតព្វន្តិ> បាតរាសំ; កតំ បាតរាសំ យេន សោ> កតបាតរាសោ** ។ - **បាបកម្មវស** ចុំ. អំណាចនៃបាបកម្មគឺ....ធ្វើហើយ ។ - **បាបកម្ម** នចុំ. កម្មដ៏លាមកគឺ...ធ្វើហើយ; គុ. មានកម្មដ៏លាមកធ្វើហើយ ។ - **បុញ្ញកម្ម** គុ. មានបុញ្ញកម្ម (កម្មគឺបុណ្យ) ធ្វើហើយ ។ - **បុញ្ញ** គុ. អ្នកមានបុណ្យធ្វើហើយ ។ - **បុព្វ** គុ. គឺ...ធ្លាប់ធ្វើហើយ ។ - **ភត្តកិច្ច** គុ. អ្នកមានកិច្ចដោយភត្តធ្វើហើយ, អ្នកមានភត្តកិច្ចធ្វើហើយ; វិ. **ភត្តេន កិច្ចំ>ភត្តកិច្ចំ, កតំ ភត្តកិច្ចំ យេន សោ> កតភត្តកិច្ចោ** ។ - **ភារ** ចុំ. ភារៈនៃ...នោះជា...គឺ...ធ្វើហើយ ។ - **មង្គល** គុ. អ្នកមានមង្គលធ្វើហើយ; នចុំ. មង្គលគឺ...ធ្វើហើយ ។ - **វត្ត** នចុំ. វត្តគឺ...ធ្វើហើយ ។ - **វេទី** ចុំ. អ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយ, អ្នកសម្ដែងនូវឧបការៈដែលអ្នកដទៃធ្វើហើយ; វិ. **កតំ ឧបការំ វេទេតីតិ> កតវេទី** ។ - **សក្ការសម្មាន** គុ. អ្នកមានសក្ការៈនិងសម្មានៈ (សេចក្ដីរាប់អាន) ធ្វើហើយ; ។ - **សក្ការ** ចុំ. សក្ការៈគឺ...ធ្វើហើយ; គុ. អ្នកមានសក្ការៈធ្វើហើយ ។ - **សន្នាហ** គុ. អ្នកមានវត្ថុជាគ្រឿងចងព្រមធ្វើហើយ, អ្នកមានវត្ថុជាគ្រឿងស៊ើកសៀតធ្វើហើយ ។ - **សមាហិត** គុ. អ្នកមានចិត្តតាំងមាំធ្វើហើយ ។ - **សិរីសម្បុ-**

Websites: WatKhemaraRatanaram.org or WatKhmers.org

ជត្តន គុ. អ្នកមានកិរិយាជំរះនូវសរីរៈធ្វើហើយ ។ . សមណ-ធម្ម គុ. អ្នកមានសមណធម៌ធ្វើហើយ ។ . សស្ស នបុំ. សំទូងគឺ...ធ្វើហើយ ។

**កតម** វិ.ស.អ. [ កឹ+តម>កតម ] ណា, ណាមួយ, ណាខ្លះ, អ្វី, ដូចម្ដេច... ។

**កតរ** វិ.ស.អ. [ កឹ+តរ>កតរ ] ណា, ណាមួយ, ណាខ្លះ, អ្វី, ដូចម្ដេច,.... ។ . កុល នបុំ. ត្រកូលណា ។ . ត្ថេរ បុំ. ព្រះថេរៈអង្គណា ។ . ទានរសរតិ ឥ. ទាននិងរសនិងសេចក្ដីត្រេកអរអ្វី ។ . ធីតា ឥ. ធីតាណា, ធីតានៃជនណា ។ . នគរ នបុំ. នគរណា ។ . បច្ចយ បុំ. បច្ច័យអ្វី ។ . សក្ក បុំ. សក្យៈណា ។

**កតាកត** គុ. [ កត+អកត ] គឺ...ធ្វើហើយនិងមិនធ្វើហើយ ។ . វិជា-ននក បុំ. អ្នកដឹងច្បាស់នូវកម្មដែលបុគ្គលធ្វើហើយនិងមិនធ្វើហើយ; វិ. កតាកតំ វិជានាតីតិ> កតាកតវិជាន-នកោ ។

**កតាធិការ** គុ. [ កត+អធិការ ] មានអធិការៈធ្វើហើយ មានកុសលគឺបុគ្គលគប្បីធ្វើដ៏ក្រៃលែងធ្វើហើយ, មានកិ.កសាងធ្វើហើយ ។

**កតាបរាធ** បុំ. [ កត+អបរាធ ] សេចក្ដីខុសគឺ...ធ្វើហើយ, កំហុសគឺ....ធ្វើហើយ; គុ. មានកំហុសធ្វើហើយ ។

**កតាភិនីហារ** គុ. [ កត+អភិនីហារ ] អ្នកមានអភិនីហារធ្វើហើយ, អ្នកមានធម៌ជាគ្រឿងនាំចេញដើម្បីគុណដ៏ក្រៃលែងធ្វើហើយ; វិ. កតោ អភិនីហារោ យេន សោ> កតាភិនីហារោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កតាភិយោគភាវ** បុំ. [ កត+អភិយោគ+ភាវ ] ភាវៈនៃ...អ្នកមានព្យាយាមជាគ្រឿងប្រកបដ៏ក្រៃលែងធ្វើហើយ; វិ. **អភិយុញ្ជតិ ឯតេនាតិ> អភិយោគោ; កតោ អភិយោគោ យេន សោ> កតាភិយោគោ; កតាភិយោគស្ស ភាវោ> កតាភិយោគភាវោ** ។

**កតិ** និ. ប៉ុន្មាន, ចំនួនប៉ុន្មាន ។ - **វស្ស** គុ. មានវស្សាប៉ុន្មាន, ប៉ុន្មានវស្សា ។

**កតិកា** ឥ. [ កតិ+ណិក ] សញ្ញាដែលកើតអំពីការធ្វើ (សេចក្ដីប្ដេជ្ញា, ពាក្យប្ដេជ្ញា); វិ. **ករណំ> កតិ; កតិយា ជាតា** (សញ្ញា)> **កតិកា** ។

**កតិបយ** គុ. [ កតិ+បិ>កតិបយ ] ពីរបី, ពីរបីនាក់, ពីរបីរូប ។

**កតិបាហ** នបុំ. [ កតិបិ+អហ ] ថ្ងៃពីរបី, ពីរបីថ្ងៃ ។ - **អច្ចយ** បុំ. កាលជាទីប្រព្រឹត្តកន្លងទៅនៃថ្ងៃពីរបី, កាលជាទីប្រព្រឹត្តកន្លងទៅអស់ពីរបីថ្ងៃ ។

**កតុបាសន** គុ. [ កត+ឧបាសន ] មានការបាញ់នូវកូនសរស្ទាត់ហើយ, -ធ្មឹកហើយ (ខ្លះថា មានគ្រឿងក្រោះធ្វើស្រេចហើយ); វិ. **កតំ ឧបាសនំ យេហិ តេ> កតុបាសនា** ។

**កតោកាស** គុ. [ កត+ឱកាស ] អ្នកមានឱកាសធ្វើហើយ, អ្នកមានឱកាសគឺ...ធ្វើហើយ ។

**កតោបការ** គុ. [ កត+ឧបការ ] អ្នកមានឧបការៈធ្វើហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កត្វា** អ. [ ករ+ត្វា ] ធ្វើ, ធ្វើហើយ ។

**កត្តព្វ** គុ. [ ករ+តព្វ ] គឺ...គប្បីធ្វើ.គួរធ្វើ, .ត្រូវធ្វើ ។ . **កម្ម** នបុំ. កម្មគឺបុគ្គលគប្បីធ្វើ ។ . **កិច្ច** នបុំ. កិច្ចគឺ...គប្បីធ្វើ ។ . **បរិហារ** គុ. វត្ថុជាគ្រឿងរក្សាគឺ...គប្បីធ្វើ, (វត្ថុជាគ្រឿងនាំទៅជុំវិញគឺអ្នកទាំងឡាយគប្បីធ្វើ) ។ . **យុត្តក** គុ. គួរគឺ...គប្បីធ្វើ ។ . **រូប** គុ. មានរូបគឺ...គប្បីធ្វើ, មានសភាពគឺ...គប្បីធ្វើ ។ . **វត្ថុ** នបុំ. វត្ថុគឺ...គប្បីធ្វើ ។ . **សិប្ប** នបុំ. សិល្បៈ (សិល្បសាស្ត្រ) គឺ...គប្បីធ្វើ ។

**កត្តរ** គុ. [ កត្តរ+អ ] ចាស់, គ្រាំគ្រា (វិ. **កត្តរយតីតិ> កត្តរោ**) ។ . **យដ្ឋិ** ឥ. ឈើច្រត់ចាស់, ឈើច្រត់នៃបុគ្គលចាស់ ។ . **សុប្ប** នបុំ. ចង្អេរចាស់ ។

**កត្តរិយគ្គ** នបុំ. [ កត្តរិយ+អគ្គ ] ចុងនៃកន្ត្រៃ ។

**កត្តា** បុំ. [ ករ+តុ ] អ្នកធ្វើ; វិ. **ករោតីតិ> កត្តា** ។

**កត្តុកម្យតាឆន្ទវស** បុំ. [ កត្តុកម្យតា+ឆន្ទ+វស ] អំណាចនៃឆន្ទៈ (សេចក្ដីពេញចិត្ត) គឺភាវៈនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ (កត្តុកម្យតា<កត្តុកាម+ណ្យ+តា, វិ. **កត្តុំ កាមេតីតិ> កត្តុកាមោ, កត្តុកាមស្ស ភាវោ> កត្តុកម្យំ, កត្តុកម្យំ ឯវ> កត្តុកម្យតា**) ។

**កត្តុកាម** គុ. [ កត្តុំ+កម+ណ ] អ្នកប្រាថ្នាដើម្បីធ្វើ, អ្នកចង់ដើម្បីធ្វើ, វិ. **កត្តុំ កាមេតីតិ> កត្តុកាមោ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កត្ថចិ** អ.ស. [ កឹ+ត្ថ+ចិ ] ក្នុងទីណា, ក្នុងទីដូចម្ដេច ។

**កត្ថវាសិក** គុ. [ កត្ថ+វស+ណិក ] អ្នកនៅក្នុងទីណា ។

**កថន** នថុំ. [ កថ+យុ ] កិ.ពោល, កិ.សម្ដែង,...វិ. **កថិយតេ> កថ-នំ** ។ ជាទីពោល; វិ. **កថេតិ ឯតស្មិន្តិ> កថនំ** ។ . **កាល** ថុំ. កាលជាទីពោល ។ . **ភយ** នថុំ. ភ័យ (សេចក្ដីខ្លាច) អំពីកិ. ពោល ។

**កថយមាន** គុ. [ កថ+ណយ+មាន ] កាលពោល, កំពុងពោល ។

**កថយិត្វា** កិ. [ កថ+ណយ+ត្វា_ហិ., ចុះឥ_អា. ] ពោលហើយ ។

**កថយិស្វា** កិ. [ កថ+ណយ+ខ្វំ_អជ្ជ. ] ពោលហើយ, សម្ដែងហើយ,... ។

**កថំ** ប.និ. ដោយប្រការដូចម្ដេច, ដូចម្ដេច, អ្វី, យ៉ាងណា ។ . **កថា** ឥ. វាចាជាគ្រឿងពោលថាដូចម្ដេច; វិ. **កថំ កថេតិ ឯតាយាតិ> កថំកថា** ។ . **ភូត** គុ. កើតហើយយ៉ាងណា, កើតហើយដូចម្ដេច ។ . **រូប** គុ. មានសភាពយ៉ាងណា, មានសភាពដូចម្ដេច, មានអ្វីជារូប ។

**កថំ** អ.ត. [ កឹ+ថំ ] វិប្រការដូចម្ដេច, នូវប្រការដូចម្ដេច, ដោយប្រការដូចម្ដេច ។ល។

**កថា** ឥ. [ កថ+អ+អា_ឥ. ] វាចាជាគ្រឿងពោល; វិ. **កថេតិ ឯតាយាតិ> កថា** ។ វាចាដែលជនពោល (ពាក្យ, សំដី); វិ. **កថិយតីតិ> កថា** ។ . **ទោស** ថុំ. ទោសនៃវាចាជាគ្រឿងពោល ។ . **បបញ្ច** ថុំ. កាលដ៏យឺតយូរព្រោះវាចាជាគ្រឿងពោល,

Websites: WatKhemaraRatanaram.org or WatKhmers.org

ដំណើរឃើញច្បាស់ព្រោះវាចាជាគ្រឿងពោល ។ . បរិយោសាន នបុំ. កាលជាទីបំផុតជុំវិញនៃកថា, កាលជាទីចប់នៃវាចាជាគ្រឿងពោល ។ . បវត្តិ ឥ. កិ.ប្រព្រឹត្តិទៅនៃវាចាជាគ្រឿងពោល ។ . វត្ថុ នបុំ. កថាវត្ថុ, វត្ថុ (រឿង) នៃវាចាជាគ្រឿងពោល ។ . សទ្ទ បុំ. សំឡេងនៃវាចាជាគ្រឿងពោល, សូរនៃ... ។ . សមុដ្ឋាបនវត្ត នបុំ. វត្តគឺកិ.ញ៉ាំងវាចាជាគ្រឿងពោលឱ្យតាំងឡើងព្រម; វិ. កថំ សមុដ្ឋាបិយតេតិ> កថាសមុដ្ឋាបនំ, កថាសមុដ្ឋាបនំ ឯវ វត្តំ> កថាសមុដ្ឋាបនវត្តំ ។ . សល្លាប បុំ. កិ.ចរចាដោយវាចាជាគ្រឿងពោល, ការនិយាយឆ្លើយឆ្លងដោយសំដី (សល្លាប<សំ+លប+ណ); វិ. សល្លបនំ> សល្លាបោ , កថាយ សល្លាបោ> កថាសល្លាបោ ។

**កថាបេតុំ** អ. [ កថ+ណាបេ+តុំ ] ដើម្បីញ៉ាំង...ឱ្យពោល, វិកិ.ញ៉ាំង...ឱ្យសម្ដែង ។

**កថាបេត្វា** អ. [ កថ+ណាបេ+ត្វា ] ញ៉ាំង...ឱ្យសម្ដែងហើយ ។

**កថាបេថ** កិ. [ កថ+ណាបេ+ថ.ប. ] ចូរញ៉ាំង...ឱ្យពោល ។

**កថាបេសុំ** កិ. [ កថ+ណាបេ+ឧំ.អជ្ជ., ចុះស. អា. ] ញ៉ាំង...ឱ្យពោលហើយ ។

**កថាបេស្សាមិ** កិ. [ កថ+ណាបេ+ស្សាមិ.ភ. ] និងញ៉ាំង...ឱ្យពោល ។

**កថិត** គុ. [ កថ+ឥ.អា+ត ] គឺ...ពោលហើយ ។ . **កថា** ឥ. វាចាជា

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្រឿងពោលគឺ...ពោលហើយ ។ - ការណ ឧចុំ. ហេតុនៃ... គឺ...ពោលហើយ ។ - កាល ចុំ. កាលនៃ... គឺ... ពោលហើយ ។ - ត្ថ ឧចុំ. ភាវៈនៃពាក្យនោះជាពាក្យគឺ...ពោលហើយ ។ - ធម្ម ចុំ. ធមិគឺ...សម្ដែងហើយ ។ - និយាម ចុំ. ទំនងនៃពាក្យគឺ... ពោលហើយ ។ - ភាវ ចុំ. ភាវៈនៃពាក្យនោះជាពាក្យគឺ...ពោល ហើយ ។ - វត្ថុ ឧចុំ. វត្ថុគឺ...ពោលហើយ, វត្ថុគឺ...ប្រាប់ហើយ ។

**កថិយមាន** គុ. [ កថ+ឥ_អា.+យ+មាន ] គឺ...កាលពោល, គឺ...កំពុង ពោល ។

**កថេតព្វ** គុ. [ កថ+ណេ+តព្វ ] គឺ...គប្បីពោល, គឺ...ត្រូវពោល ។ - យុត្តក គុ. គួរគឺ...គប្បីពោល ។

**កថេតិ** កិ. [ កថ+អ(១)+តិ_វ. ] ពោល, សម្ដែង, ប្រាប់, និយាយ, ស្ដី, ថា ។

**កថេតុំ** អ. [ កថ+អ+តុំ ] ដើម្បីពោល, វីកិ.ពោល ។

**កថេត្វា** អ. [ កថ+អ+ត្វា ] ពោលហើយ, សម្ដែងហើយ ។

**កថេន្តិ** កិ. [ កថ+អ+អន្តិ_វ. ] ពោល, សម្ដែង ។

**កថេន្តី** គុ. ឥ. [ កថ+អន្ត+ឦ ] កាលពោល, កាលសម្ដែង ។

**កថេន្ត** គុ. [ កថ+អ+អន្ត ] កាលពោល, កាលសម្ដែង ។

**កថេយ្យ** កិ. [ កថ+អ+ឯយ្យ_ស. ] គប្បីពោល, គប្បីសម្ដែង ។

១ .ចុះអបច្ច័យធ្វើទៅជាឯ ឬចុះឯបច្ច័យតែម្ដងក៏បាន ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កថេសិ កិ. [ កថ+អ+ឥស្សិ-អជ្ជ, ចុះស-អា. ] ពោលហើយ, សម្ដែងហើយ ។

កថេស្សតិ កិ. [ កថ+អ+ស្សតិ-ភ. ] នឹងពោល, នឹងសម្ដែង ។

កថេហិ កិ. [ កថ+អ+ហិ-ប. ] ចូរពោល, ចូរសម្ដែង ។

កទម្ពបុប្ផ នថុំ. [ កទម្ព+បុប្ផ ] ផ្កានៃឈើកទម្ព, ផ្កាកទម្ព ។

កទរិយ គុ. [ កទរ+ឥយ ] (បុគ្គល) អ្នកមានសេចក្ដីកំណាញ់; វិ. កទរំ យស្ស អត្ថីតិ> កទរិយោ ។

កទា កា.ស. [ កឹ+ទា, កឹ>ក ] ក្នុងពេលណា, អង្កាល់, ពីអង្កាល់ ។

កទ្ទមពហុល គុ. [ កទ្ទម+ពហុល ] ច្រើនដោយភក់, មានភក់ដ៏ច្រើន ។

កទ្ទមលេបនាការ ថុំ. [ កទ្ទម+លេបន+អាការ ] អាការគឺកិ.លាបដោយភក់ ។

កទលិគព្ភសទិស គុ. [ កទលិ+គព្ភ+សទិស ] ប្រាកដស្មើដោយបណ្ដូលនៃចេក, ប្រហែលដោយត្រួយនៃចេក ។

កទលិបណ្ណ នថុំ. [ កទលិ+បណ្ណ ] ស្លឹកនៃចេក ។

កទលិបត្ត នថុំ. [ កទលិ+បត្ត ] ស្លឹកនៃចេក ។

កនកមយ គុ. [ កនក+មយ ] ជាវិការៈនៃមាស; វិ. កនកស្ស វិការោ> កនកមយំ ។ សម្រេចហើយដោយមាស; វិ. កនកេន និព្វត្តំ> កនកមយំ ។

**កនកវិមាន** នបុំ. [ កនក+វិមាន ] វិមានជាវិការៈនៃមាស, វិមានដែលបុញ្ញកម្មធ្វើហើយដោយមាស; វិ. **កនកមយំ វិមានំ> កនកវិមានំ** ។

**កនិដ្ឋ** គុ. [ យុវ>កន+ឥដ្ឋ ] ក្មេងដោយវិសេស ឬ ក្មេងជាង (ប្អូន, ប្អូនតូច, ប្អូនពៅ); វិ. **អយញ្ច យុវា អយញ្ច យុវា អយមិមេសំ វិសេសេន យុវាតិ> កនិដ្ឋោ** ។ . **កុដុម្ពិក** បុំ. កុដុម្ពិកៈ ឬ កុដុម្ពីជាប្អូន ។ . **កុមារ** បុំ. កុមារជាប្អូន ។ . **ធីតា** ឥ. ធីតាជាប្អូន ។ . **បុត្ត** បុំ. កូនជាប្អូន, កូនតូចជាង, កូននៃប្អូន (កូនពៅ) ។ . **ភគិនី** ឥ. ប្អូនស្រី ។ . **ភាតា** បុំ. ប្អូនប្រុស, បងប្អូនប្រុស ។

**កន្តតិ** កិ. [ កត ឬកន្ត+អ+តិ_វ. ] កាត់, លះ, ពុះ, ច្រៀក, រវៃ ។

**កន្តន្ត** គុ. [ កន្ត+អន្ត ] កាលរវៃ, កំពុងរវៃ,... ។

**កន្ត** គុ. [ កម+ត ] គឺបុគ្គលគប្បីប្រាថ្នា, .ត្រេកអរ, ជាទីត្រេកអរ ។

**កន្តារ** បុំ. [ កំ+តរ+ណ ] ផ្លូវជាទីញ៉ាំងទឹកឱ្យឆ្លង (ផ្លូវឆ្ងាយ, ផ្លូវលំបាក, ផ្លូវឆ្ងាយដាច់ស្រយាល, ផ្លូវដែលត្រូវយកទឹកទៅជាមួយផង); វិ. **កំ តារេន្តិ ឯត្ថាតិ> កន្តារោ** ។ . **អទ្ធាន** នបុំ. ផ្លូវឆ្ងាយជាទីញ៉ាំងទឹកឱ្យឆ្លង, ផ្លូវឆ្ងាយដាច់ស្រយាល, ផ្លូវឆ្ងាយគឺកន្តារៈ ។

**កន្តិត្វា** អ. [ កន្ត+ឥ_អា.+ត្វា ] កាត់ហើយ, លះហើយ, មុតហើយ, រវៃហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កន្ទតំ** គុ. [ កន្ទន្ត+នំ_វិ., ផ្លាស់ន្ត+នំ>តំ ] កំពុងយំ, កំពុងទ្រហោយំ, កំពុងកន្ទក់កន្ទេញ ។

**កន្ទថ** កិ. [ កទ+ ឬ កន្ទ+អ+ថ_វ. ] រំមែងយំ, ទ្រហោយំ, កន្ទក់កន្ទេញ ។

**កន្ទន្ត** គុ. [ កទ+អន្ត ] កាលកន្ទក់កន្ទេញ,.. ។

**កន្ទសិ** កិ. [ កទ+អ+សិ_វ. ] កន្ទក់កន្ទេញ, រអ៊ូរទាំ... ។

**កន្ទិត្វា** អ. [ កទ+ឥ_អា.+ត្វា ] កន្ទក់កន្ទេញហើយ, រអ៊ូរទាំហើយ,... ។

**កន្ទីសុ** កិ. [ កទ+អ+ឦ_អជ្ជ., ចុះនិ_អា. ] កន្ទក់កន្ទេញហើយ,... ។

**កន្ទេយ្យុំ** កិ. [ កទ+អ+ឯយ្យុំ_ស., ចុះនិ_អា.] គប្បីកន្ទក់កន្ទេញ,... ។

**កន្ទរ** ចុំ. ឥ. [ ក+ទរ+អ ] ប្រទេសដែលទឹកហូរច្រោះ (ជ្រោះ, ជ្រោះភ្នំ, ច្រកភ្នំ); វិ. **កេន ឧទកេន ទរិយតិ បទាលិយតីតិ> កន្ទរោ, -រា** ។

**កបណ** គុ. [ កប+យុ ] មនុស្សដែលគេគប្បីអាណិត(កំព្រា, មនុស្សកំព្រា); វិ. **កបិតព្វោ ករុណាយិតព្វោតិ> កបណោ** ។ ន័យខ្លះថា : មនុស្សមានដៃគួរខ្ពើម; វិ. **កុច្ឆិតោ បណោ យស្ស សោ> កបណោ** ។ **.ជន** ចុំ. ជនកំព្រា ។ **-អទ្ធិកវណិព្វកយាចក** ចុំ. ជនកំព្រា និងជនអ្នកដំណើរ និងវណិព្វកៈ និងយាចក, ជនកំព្រា និងជនអ្នកដើរទៅកាន់ផ្លូវឆ្ងាយ និងជនអ្នកពណ៌នាហើយទើបសូមនិងជនអ្នកសូម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កបល្ល** នថុំ. [ ក+បាល+អ ] អំបែង (ដូច កបាល) ។ - **ជាតិ** ន. ភាជនៈគឺអំបែង ។ - **បូវបព្ភារ** ថុំ. ញកនៃនំអំបែង, ញកជាទីធាក់ចោលនូវនំអំបែង ។ - **បូវ** ថុំ. នំអំបែង, នំដែលបុគ្គលចំអិនលើអំបែង ។

**កបាល** នថុំ. [ ក+បាល+អ ] វត្ថុរក្សានូវក្បាល ឬភាជនៈជាគ្រឿងចិញ្ចឹមនូវជីវិត (អំបែង); វិ. **កំ សីសំ បាលេតីតិ> កបាលំ, កប្បន្តិ ជីវិតំ ឯតេនាតិ វា> កបាលំ** ។ - **ខណ្ឌ** គុ. បំណែកនៃអំបែង ។ - **ខណ្ឌាទិភាវ** ថុំ. ភាវៈនៃវត្ថុមានចំណែកនៃអំបែងជាដើម ។ - **ហត្ថ** គុ. មានអំបែងក្នុងដៃ; វិ. **កបាលំ ហត្ថេ យស្ស សោ> កបាលហត្ថោ** ។

**កបិ** ថុំ. [ កប+ឥ ] សត្វតែងកម្រើកញាប់ញ័រ (ស្វា); វិ. **កម្បតិ ចលតីតិ> កបិ** ។

**កបិល** [ កព>កប+ឥល ] គុ. ពណ៌ក្រហម, គោក្រហម, គោមានសម្បុរក្រហម, អ.ន. ត្រីឈ្មោះកបិលៈ, ភិក្ខុឈ្មោះកបិលៈ ។ - **មច្ឆ** ថុំ. ត្រីឈ្មោះកបិលៈ ។ - **វត្ថុនគរ** នថុំ. ក្រុងឈ្មោះកបិលព័ស្តុ ។ - **វត្ថុប្បវេសនាទិ** គុ. (កាល) មានកាលជាទីចូលទៅកាន់ក្រុងឈ្មោះកបិលព័ស្តុជាដើម ។ - **វត្ថុបុរ** នថុំ. បុរី (ក្រុង) ឈ្មោះកបិលវត្ថុ ។ - **វត្ថុវាសិក** គុ. អ្នកនៅក្នុងក្រុងឈ្មោះកបិលព័ស្តុ; វិ. **កបិលវត្ថុម្ហិ វសតីតិ> កបិល-វត្ថុវាសី , កបិលវត្ថុវាសី ឯវ> កបិល-វត្ថុវាសិកោ** ។ - **វត្ថុសាមន្ត** គុ. ទីជិតនៃក្រុងឈ្មោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

កបិលព័ស្តុ ។

**កបោតក** ចុំ. [ កប+ឧត+ក.ស. ] ព្រាប, សត្វព្រាប, សត្វលលក ។ **-វណ្ណ** គុ. មានសម្បុរដូចជាសម្បុរនៃសត្វព្រាប ។

**កប្បក** ចុំ. [ កប្ប+ណ្វុ ] អ្នកការកាត់នូវសក់ (ខ្មាន់ប្រកេស); វិ. **កប្បតិ កេសេ ឆិន្ទតីតិ> កប្បកោ** ។ **-អន្តេវាសិក** ចុំ. អន្តេវាសិក (សិស្ស) ឈ្មោះកប្បកៈ ។ **-វេស** ចុំ. ភេទនៃខ្មាន់ប្រកេស ។

**កប្បកោដិ** ឥ. [ កប្ប+កោដិ ] កោដិនៃកប្ប ។

**កប្បកោដិសហស្ស** នចុំ. [ កប្ប+កោដិ+សហស្ស ] ពាន់នៃកោដិនៃកប្ប ។

**កប្បដ្ឋិតិក** គុ. [ កប្ប+ឋិតិ+ណិកប្ប.ក.ស. ] មានកិ.តាំងនៅអស់កប្ប, ប្រកបក្នុងកិ.តាំងនៅអស់កប្ប ។

**កប្បតិ** កិ. [ កបឬកប្ប+អ+តិ.វ. ] សម្រេច, គួរ, ចិញ្ចឹម ។

**កប្បរជន្នុកាទិ** គុ. [ កប្បរ+ជន្នុក+អាទិ ] (អវយវៈ) មានជុំដៃនិងក្បាលជង្គង់ជាដើម ។

**កប្បរុក្ខ** ចុំ. [ កប្ប+រុក្ខ ] ដើមកល្បព្រឹក្ស, ឈើញ៉ាំងសេចក្ដីប្រាថ្នាឱ្យសម្រេច, ឈើដ៏តាំងនៅអស់កប្ប ។

**កប្បវិនាសក** គុ. [ កប្ប+វិ+នស+ណ្វុ ] ដែលញ៉ាំងកប្បឱ្យវិនាស (ភ្លើងប្រល័យកល្ប); វិ. **កប្បំ វិនាសេតីតិ> កប្បវិ.នាសកោ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កប្បសតសហស្ស** នថុំ. [ កប្ប+សតសហស្ស ] សែននៃកប្ប ។
**. បរិយោសាន** នថុំ. កាលជាទីបំផុតនៃសែននៃកប្ប ។
**. បូរិតបារមី** គុ. មានបារមីបំពេញហើយអស់សែននៃកប្ប ។
**. មត្ថក** គុ. ទីបំផុតនៃសែននៃកប្ប ។

**កប្បសតសហស្សាធិក** គុ. [ កប្បសតសហស្ស+អធិក ] ដ៏ក្រៃលែងដោយសែននៃកប្ប ។

**កប្ប** អ.ន. តាបសឈ្មោះកប្បៈ ។

**កប្បាសដ្ឋិកភាវ** ថុំ. [ កប្បាស+អដ្ឋិក+ភាវ ] ភាវៈនៃ...ជាគ្រាប់នៃកប្បាស ។

**កប្បាសិករនសណ្ឌ** ថុំ. [ កប្បាសិក+វន+សណ្ឌ ] ដងនៃព្រៃដ៏ដេរដាសដោយដើមកប្បាស, ដងនៃព្រៃគឺបុគ្គលកំណត់ហើយដោយដើមកប្បាស ។

**កប្បិយ** គុ. [ កប្ប+ណ្យ+ឥ.អា. ] វត្ថុដែលបុគ្គលគប្បីសម្រេច, ជារបស់គួរ, ដ៏សមគួរ ។ **. ការកសាមណេរសទិស** គុ. ប្រាកដស្មើដោយសាមណេរអ្នកធ្វើនូវវត្ថុឱ្យជារបស់គួរ ឬអ្នកធ្វើនូវកប្បិយៈ ។ **. ការក** ថុំ. នថុំ. អ្នកធ្វើនូវវត្ថុឱ្យជារបស់គួរ, អ្នកធ្វើនូវកប្បិយៈ; រ៉ី. ***កប្បិយំ ករោតីតិ*** > ***កប្បិយការកោ*** ។ **. ភណ្ឌ** នថុំ. ភណ្ឌៈដ៏គួរ, ភណ្ឌៈជាកប្បិយៈ ។ **. ភូមិ** ឥ. ផែនដីជាកប្បិយៈ, ផែនដីដ៏សមគួរ, ទីដ៏គួរ ។ **. មំស** នថុំ. សាច់ជាកប្បិយៈ, សាច់ដ៏គួរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កប្បេយ្យំ** កិ. [ កប្ប+អ+ឯយ្យំ.ស. ] គប្បីសម្រេច, -កាប់, -កាត់, -ក្រវែល ។

**កប្បេតិ** កិ. [ កប្ប+អ+តិ.វ. ] សម្រេច, គួរ, ចិញ្ចឹម, ... ។

**កប្បេតុ** កិ. [ កប្ប+អ+តុ.ប. ] ចូរកាប់, ចូរក្រវែល, ...។

**កប្បេន្តិ** គុ. [ កប្ប+អ+អន្ត ] កាលសម្រេច, កាលចិញ្ចឹម, កាលកាប់,... ។

**កប្បេសិ** កិ. [ កប្ប+អ+ឦ.អជ្ជ., ចុះស.អា. ] សម្រេចហើយ, ចិញ្ចឹម,... ។

**កពន្ធ** នថុំ. [ កុ+អន្ធ ] សាកសព (ដូចកលេវរ) ។

**កពរ** គុ. [ កុ+អល, អល>អរ+អ ] ពពាល ។ . **គាវីសទិស** គុ. ប្រាកដស្មើដោយមេគោពពាល, ដូចជាមេគោពពាល ។ . **គោរូប** នថុំ. រូបនៃគោពពាល ។ . **ច្ឆាយ** គុ. មានស្រមោលពពាល, មានម្លប់ប៉ើងរើង, មានស្រមោលរង្នើល ។

**កពល** ថុំ. [ កុ+អល+អ ] ពំនូត, ពំនូតបាយ; (វិ. **កេន ករោយេន ពលមស្សាតិ> កពលោ**) ។ ប្រើជា **កពឡោ** ក៏មាន ។

**កមណ្ឌលុទក** នថុំ. [ កមណ្ឌលុ+ឧទក ] ទឹកក្នុងកុណ្ឌី ។ (កមណ្ឌលុ<កមណ្ឌ+លា+ឧ) វត្ថុកាន់យកនូវភាវៈនៃទឹកថ្លា (កុណ្ឌី); វិ. **កស្ស ជលស្ស មណ្ឌោ បសន្នភាវោ> កមណ្ឌោ , កំ លាតីតិ> កមណ្ឌលុ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កម្បនាការប្បត្ត** គុ. [ កម្បន+អាការ+បត្ត ] ដល់ហើយនូវអាការគឺ កិ.កញ្រើក, -កញ្រើក, -ញាប់ញ័រ ។

**កម្បមាន** គុ. [ កម្ប+មាន ] កាលញាប់ញ័រ, កំពុងញាប់ញ័រ ។ - **សរីរ** គុ. មានសរីរៈកំពុងញាប់ញ័រ ។

**កម្បតិ** កិ. [ កម្ប+អ+តិ_វ. ] កញ្រើក, ញាប់ញ័រ ។

**កម្បិ** កិ. [ កម្ប+អ+ឦ_អជ្ជ. ] កញ្រើកហើយ, ញាប់ញ័រហើយ ។

**កម្បេតុំ** អ. [ កម្ប+ណេ+តុំ ] ដើម្បីញាប់ញ័រ...ឱ្យកញ្រើក,... ។

**កម្បេត្វា** អ. [ កម្ប+ណេ+ត្វា ] ញ៉ាំង...ឱ្យកញ្រើកហើយ ។

**កម្ពល** ចុំ. [ កម+អល, ចុះព_អា. ] សំពត់ដែលជនគប្បីប្រាថ្នា (សំពត់កម្ពល); វិ. *កមនីយោតិ> កម្ពលោ* ។ - **កុដាគារ** នចុំ. កុដាគារគឺបុគ្គលបិទបាំងដោយសំពត់កម្ពល, ផ្ទះគឺបុគ្គលសង្គ្រោះដោយកំពូលដែលបុគ្គលពាសដោយសំពត់កម្ពល, ផ្ទះប្រកបដោយកំពូលគឺបុគ្គលពាសដោយសំពត់កម្ពល ។ - **អត្ថិក** គុ. អ្នកមានសេចក្តីត្រូវការដោយសំពត់កម្ពល; វិ. *កម្ពលេន អត្ថោ> កម្ពលត្ថោ , សោ យេសមត្ថីតិ> កម្ពលត្ថិកា* ។ - **ទាយកតិស្ស** អ.ន. សាមណេរឈ្មោះកម្ពលទាយកតិស្សៈ ឬសាមណេរឈ្មោះតិស្សៈអ្នកឱ្យនូវសំពត់កម្ពល ។ - **បាទុកា** ឥ. ស្បែកជើងជាវិការៈនៃសំពត់កម្ពល ។ - **សហស្សភារ** ចុំ. ភារៈនៃសំពត់កម្ពលមានពាន់ជាប្រមាណ, ភារៈនៃពាន់នៃសំពត់កម្ពល ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កម្ម** ចុំ. [ ករ+រម្ម ] កិច្ចដែលជនធ្វើ ឬ កិច្ចដែលជនត្រូវធ្វើ (កម្ម, អំពើ); ថៃ. **ករិយតេត៍> កម្មំ , ភាគពង្គិ ថា> កម្មំ** ។ -**ករណ** នចុំ. កម្មករណ៍, កិ.ធ្វើនូវកម្ម, មោសជាតជាគ្រឿងធ្វើនូវកម្ម ។ -**ករ** ចុំ. កម្មករ, ជនអ្នកធ្វើនូវការងារ; ថៃ. **កម្មំ ករោតិត៍> កម្មករោ** ។ -**កិលិដ្ឋ** គុ. កម្មដ៏សៅហ្មង, សេចក្ដីសៅហ្មងនៃកម្ម, សេចក្ដីសៅហ្មងព្រោះកម្ម ។ -**កុព្វ** គុ. អ្នកធ្វើនូវកម្ម ។ -**តប្បន** នចុំ. សេចក្ដីក្ដៅក្រហាយព្រោះកម្ម ។ -**បច្ចវេក្ខណវស** ចុំ. អំណាចនៃកិ.ឃើញចុះចំពោះនូវកម្ម, អំណាចនៃកិ.ពិចារណានូវកម្ម ។ -**បថ** ចុំ. កម្មបថ, កម្មជាគន្លង, គន្លងគឺកម្ម, ផ្លូវនៃកម្ម ។ -**ផលសម្ពន្ធ** គុ. ដែលជាប់ព្រមដោយកម្មនិងផលនៃកម្ម, ដែលជាប់ព្រមដោយផលនៃកម្ម, ដែលទាក់ទងដោយផលនៃកម្ម ។ -**ពល** នចុំ. កម្លាំងនៃកម្ម ។ -**មោទន** នចុំ. សេចក្ដីត្រេកអរព្រោះកម្ម ។ -**វិបាក** ចុំ. វិបាកនៃកម្ម, ផលនៃកម្ម ។ -**វិសុទ្ធិ** ឥ. កម្មជាគ្រឿងស្អាតដោយវិសេស, សេចក្ដីស្អាតដោយវិសេសនៃកម្ម ឬ ព្រោះកម្ម, សេចក្ដីបរិសុទ្ធិនៃកម្ម ។ -**សន្និចយ** ចុំ. ការសន្សំព្រមនូវកម្ម, កិ.សន្សំព្រមនូវកម្ម (សន្និចយ<សំ+និ+ចិ+អ) ។ -**សរិក្ខក** គុ. ប្រាកដស្មើដោយកម្ម, ប្រហែលដោយកម្ម (សរិក្ខក<សមាន>ស, ទិស>រិក្ខ+ណ្យ); ថៃ. **សមានមិច នំ ឋស្សតិត៍> សរិក្ខកោ** ; ម៉្យាងទៀត គឺបុគ្គលគប្បីឃើញស្មើ; ថៃ. **សមានំ ធដ្ឋព្វោតិត៍> សរិក្ខកោ** ។ -**សោចន** នចុំ. សេចក្ដីសោកព្រោះកម្ម, សេចក្ដីសោកស្ដាយព្រោះកម្ម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កម្មជវាត** ពុំ. [ កម្មជ+វាត ] ខ្យល់ដែលកើតអំពីកម្ម (ខ្យល់កម្មជវាត); វិ. **កម្មុនា ជាតោ វាតោ> កម្មជវាតោ** ។

**កម្មដ្ឋាន** នពុំ. [ កម្ម+ឋាន ] កម្មដ្ឋាន, អារម្មណ៍ជាទីតាំងនៃកម្ម; វិ. **តិដ្ឋតិ ឯត្ថាតិ> ឋានំ , កម្មស្ស ឋានំ> កម្មដ្ឋានំ** ។

**- ភាវនា** ឥ. ភាវនាដែលប្រព្រឹត្តទៅក្នុងកម្មដ្ឋាន; វិ. **កម្មដ្ឋានេ បវត្តា ភាវនា> កម្មដ្ឋានភាវនា** ។ គុណជាតិជាគ្រឿងញុំាងកម្មដ្ឋានឱ្យចំរើន; វិ. **កម្មដ្ឋានំ ភាវេតិ ឯតាយាតិ> កម្មដ្ឋានភាវនា** ។ កិ.ចំរើននូវកម្មដ្ឋាន, កិ. ញុំាងកម្មដ្ឋានឱ្យកើត; វិ. **កម្មដ្ឋានស្ស ភាវនា> កម្មដ្ឋានភាវនា** ។

**- មនសិការ** ពុំ. ការធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋាន ។ **- សីស** នពុំ. ធម៌ជាប្រធាននៃកម្មដ្ឋាន ។

**កម្មដ្ឋានាភិមុខ** គុ. [ កម្មដ្ឋាន+អភិមុខ ] មានមុខឆ្ពោះទៅកាន់កម្មដ្ឋាន, មានមុខបែទៅរកកម្មដ្ឋាន ។

**កម្មនីយ** គុ. [ កម្ម+អនីយ ] គួរនូវកម្ម, គួរដល់កម្ម, គួរដល់ការងារ ។

**កម្មន្ត** ពុំ. [ កម្ម+អន្ត_ស. ] ការងារ, **កម្មំ ឯវ> កម្មន្តោ** ។

**- កិរិយា** ឥ. កិ.ធ្វើនូវការងារ ។

**កម្មាធិដ្ឋាយិក** គុ. [ កម្ម+អធិដ្ឋាយិក ] អ្នកតាំងទុកនូវកម្ម, អ្នកតាំងទុកនូវការងារ (អ្នកចាត់ការ); វិ. **កម្មំ អធិដ្ឋាតីតិ> កម្មាធិដ្ឋាយី, កម្មាធិដ្ឋាយី ឯវ> កម្មាធិដ្ឋាយិកោ** ។

**កម្មានុរូប** គុ. [ កម្ម+អនុរូប ] ដ៏សមគួរដល់កម្ម, ដ៏សមគួរដល់ការងារ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កម្មារ** ពុំ. [ កំ+មរ+ណ ] ជនអ្នកញាំងទីកឱ្យស្លាប់ (ជាង, ជាងមាស ឬ ជាងប្រាក់; វិ. **កំ មារេតីតិ> កម្មារោ** ។ . **កុល** នពុំ. ត្រកូលនៃជាងមាស ឬ ត្រកូលនៃជាងប្រាក់ ។

**កយិរតិ** កិ. [ ករ+យិរ+តិ.វ. ] ធ្វើ ។

**កយិរមាន** គុ. [ ករ+យិរ+មាន ] កាលធ្វើ, កំពុងធ្វើ ។

**កយិរា** កិ. [ ករ+យិរ+ឯយ្យ.ស. ] គប្បីធ្វើ ។

**កយិរាថ** កិ. [ ករ+យិរ+ឯយ្យាថ.ស. ] គប្បីធ្វើ ។

**ករជកាយ** ពុំ. [ ករជ+កាយ ] ករជកាយ, កាយដែលកើតអំពីធូលិប្រព្រឹត្តទៅក្នុងសរីរៈ; វិ. **កេ សរីរេ បវត្តោ រជោ> ករជោ, ករជេន សម្ភូតោ កាយោ> ករជកាយោ** ។ ឃ.វិ. ។

**ករណ** នពុំ. [ ករ+យុ ] កិ.ធ្វើ; វិ. **ករិយតេតិ> ករណំ** ។ ជាទីធ្វើ; វិ. **ករោតិ ឯតស្មិន្តិ> ករណំ** ។ ជាគ្រឿងធ្វើ, ជាហេតុធ្វើ; វិ. **ករោតិ ឯតេនាតិ> ករណំ** ។ . **កាល** ពុំ. កាលជាទីធ្វើ, កាលនៃកិ.ធ្វើ ។ . **ក្ខណ** ពុំ. ខណៈនៃកិ.ធ្វើ, ខណៈជាទីធ្វើ ។ . **សម្បត្តិជនិតសុខវិនិត្តមធុរោទារ-វចនលាវណ្ណយុត្ត** គុ. អ្នកប្រកបដោយសេចក្ដីក្បោះក្បាយនៃពាក្យដ៏ពិរោះក្រៃលែងដែលចេញទៅហើយដោយស្រួលជាពាក្យគឺករណសម្បត្តិឱ្យកើតហើយ, អ្នកប្រកបហើយដោយពាក្យដ៏ក្បោះក្បាយពិរោះក្រៃលែងដែលចេញទៅដោយងាយជាពាក្យញាំង

Websites: WatKhemaraRatanaram.org or WatKhmers.org

ករណសម្បត្តិឱ្យកើតហើយ ។

**ករណីយ** គុ. [ ករ+អនីយ ] គឺ...គប្បីធ្វើ; វិ. **ភាគពុទ្ធិ> ករណីយំ** ។

**ករណុត្តរិយករណ** នបុំ. [ ករណ+ឧត្តរិយ+ករណ ] កិ. ធ្វើឱ្យក្រៃលែងជាងកិ.ធ្វើ, កិ.ធ្វើឱ្យចម្រើនក្រៃលែងជាងកិ.ធ្វើ, -ជាងអំពើ ។

**ករណ្ឌកកណ្ណិកា** ឥ. [ ករណ្ឌក+កណ្ណិកា ] ចំពួយនៃផប, ចំពួយនៃខ្ទួច, ចំពួយនៃកំប៉ុក, ចំពួយនៃកំសៀវ ។

**ករមរ** បុំ. [ ករ+មរ+អ ] ជនអ្នកស្លាប់ក្នុងដៃនៃសត្រូវ, ជនអ្នកត្រូវស្លាប់ដោយដៃនៃសត្រូវ (មនុស្សឈ្លើយ); វិ. **សត្តំ ករេ ហត្ថេ មរតីតិ> ករមរោ, សត្តូនំ ករេន ហត្ថេន មរេយ្យាតិ> ករមរោ** ។

**ករស្សុ** កិ. [ ករ+អ+ស្សុ-ប. ] ចូរធ្វើ ។

**ករិ** កិ. [ ករ+អ+ឦ-អជ្ជ. ] ធ្វើហើយ ។

**ករិត្វាន** អ. [ ករ+ឥ-អា.+ត្វាន ] ធ្វើហើយ, លុះធ្វើហើយ ។

**ករិត្ថ** កិ. [ ករ+អ+ឥ-អា.+ត្ថ-ហី. ] ធ្វើហើយ ។

**ករិស្សតិ** កិ. [ ករ+អ+ឥ-អា.+ស្សតិ-ភ ] នឹងធ្វើ ។

**ករិសុ** កិ. [ ករ+អ+ឧំ-អជ្ជ. ] ធ្វើហើយ ។

**ករីស** នបុំ. [ ករ+ឦស ] អាហារវត្ថុដែលជនធ្វើ, -បន្ទោបង់ (ករីស, អាហារចាស់, គូថ); វិ. **ករិយតីតិ> ករីសំ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ករុណា** ឥ. [ កិរ+យុ+អា.ឥ.; ករ+ឧណា+អា.ឥ. ] ធម្មជាតិនាំបង់នូវទុក្ខនៃបុគ្គលដទៃ ឬធម្មជាតបំផ្លាញនូវទុក្ខនៃបុគ្គលដទៃ (សេចក្តីអាណិត); វិ. **កិរតិ វិក្ខិបតីតិ> ករុណា, ករោតិ បរទុក្ខំ វិនាសេតីតិ វា> ករុណា** ។ ល ។ . **ភាវនា** ឥ. គុណជាតិញាំងករុណាឱ្យចម្រើន; វិ. **ករុណំ ភាវេតីតិ> ករុណាភាវនា** ។ ភាវនាប្រកបដោយករុណា; វិ. **ករុណាយ សម្បយុត្តា ភាវនា> ករុណាភាវនា** ។ កិ.ចំរើននូវករុណា ឬកិ.ញាំងករុណាឱ្យចំរើន ។ . **វេគសមុស្សាហិតមានស** គុ. មានចិត្តគឺកម្លាំងនៃករុណាឱ្យឧស្សាហ៍ព្រមហើយ, មានឆន្ទៈមានក្នុងចិត្តគឺកម្លាំងនៃករុណាឱ្យខ្មីឃ្មាតហើយ ។ . **សហគត** គុ. ទៅមួយអន្លើដោយករុណា, ប្រព្រឹត្តទៅមួយអន្លើដោយករុណា, ប្រកបដោយករុណា ។

**ករេ** កិ. [ ករ+អ+ឯយ្យ.ស., លុបយ្យ ] គប្បីធ្វើ, ត្រូវធ្វើ ។

**ករេយ្យ** កិ. [ ករ+អ+ឯយ្យ.ស. ] គប្បីធ្វើ ។

**ករោតិ** កិ. [ ករ+ឱ+តិ.វ. ] ធ្វើ, រមែងធ្វើ ។

**ករោន្តិ** កិ. [ ករ+ឱ+អន្តិ.វ. ] ធ្វើ, រមែងធ្វើ ។

**ករោន្តី** គុ. [ ករ+ឱ+អន្ត+ឦ ] កំពុងធ្វើ, កាលធ្វើ ។

**ករោន្តុ** កិ. [ ករ+ឱ+អន្តុ.ប. ] ចូរធ្វើ, សូមធ្វើ ។

**ករោហិ** កិ. [ ករ+ឱ+ហិ.ប. ] ចូរធ្វើ, សូមធ្វើ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កល** បុំ. [ កល+អ ] សភាវៈគឺបុគ្គលគប្បីរាប់ (ចំណិត); វិ. **កលិ-យិតព្វោ សំខ្យាយិតព្វោតិ> កលោ** ។

**កលន្ទកនិវាប** បុំ. [ កលន្ទក+និវាប ] កលន្ទកនិវាបដ្ឋាន, ប្រទេសជាទីឱ្យនូវចំណីដល់សត្វកង្ហែន ។

**កលល** នបុំ. [ កល+អល ] ភក់ ។ - **មក្ខិតបាទ** គុ. មានជើងប្រឡាក់ហើយដោយភក់, មានជើងគឺភក់ប្រឡាក់ហើយ ។ - **មក្ខិត** គុ. ប្រឡាក់ហើយដោយភក់, គឺភក់ប្រឡាក់ហើយ ។

**កលហ** បុំ. [ កល+ហ ] វាទៈជាទីបៀតបៀននូវគ្នា និងគ្នា ឬវាទៈជាទីចាក់ដោតនូវគ្នានិងគ្នា (ការឈ្លោះ, ជំលោះ); វិ. **កលតិ ហឹសតិ អញ្ញមញ្ញំ អស្មិន្តិ> កលហោ** ។ - **វូបសមន** នបុំ. កិ.ចូលទៅរម្ងាប់នូវជំលោះ, កិ.ញ៉ាំងជំលោះឱ្យចូលទៅរម្ងាប់ ។ - **វូបសមនវត្ថុ** នបុំ. រឿងនៃកិ.ចូលទៅរម្ងាប់នូវជំលោះ, រឿងនៃកិ.ញ៉ាំងជម្លោះឱ្យចូលទៅរម្ងាប់ ។ - **សង្ខាត** គុ. ពោលគឺជំលោះ, គឺបណ្ឌិតរាប់ព្រមហើយថាជំលោះ ។

**កលាប** បុំ. [ កល+បា+អ ] សភាវៈរក្សាទុកនូវអវយវៈ (កណ្ដាប់, បាច់, សំណុំ); វិ. **កលំ អវយវំ បាតិ រក្ខតីតិ> កលា-បោ** ។ - **អគ្គ** គុ. មានដីថ្មោងគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីធ្វើនូវកណ្ដាប់ ។ - **អាទិ** គុ. (កាល) មានកាលជាទីធ្វើនូវកណ្ដាប់ជាដើម ។

**កលាពុរាជភូត** គុ. [ កលាពុរាជ+ភូត ] កើតជាស្ដេចឈ្មោះកលាពុ, ជា

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្តេចឈ្មោះកលាពុកើតហើយ ។

**កលិ** ចុំ. [ កល+ឥ ] ទោស, បាប, កំហុស ។

**កលិង្គរ** ចុំ., នចុំ. [ ក+លិគ+អរ, ចុះល.អា. ] ឈើដែលឃ្លាតទៅដោយខ្យល់ (ឧស, អង្កត់ឧស); វិ. **គេន ចារគេន ឥច្ចតិ អប. តច្ចតិ> កលិង្គរោ** ។

**កលីរ, កឡីរ** [ កល+ឦរ ] ពន្លក, ពន្លកឈើ, (ទំពាំង) ។

**កល្យាណ** នចុំ. [ កល+យាណ ] គុណជាតដែលជនគួររាប់ (សេចក្តីល្អ, លំអ, ពីរោះ, ជាទីពេញចិត្ត); វិ. **កលិតព្វំ សំខ្យា គច្ឆតិ> កល្យាណំ** ។ - **កម្ម** នចុំ. កម្មមានគុណគឺបណ្ឌិតគប្បីរាប់, កម្មដ៏ល្អ ។ - **អជ្ឈាសយ** គុ. អ្នកមានអធ្យាស្រ័យមានគុណគឺបុគ្គលគប្បីរាប់, អ្នកមានអធ្យាស្រ័យល្អ, ។ - **ធម្ម** គុ. មានធម៌មានគុណគឺបុគ្គលគប្បីរាប់, មានធម៌ដ៏ល្អ ។ - **បាបក** គុ. មានអំពើល្អ និងអំពើអាក្រក់ ។ - **មិត្ត** បុ. មិត្រមានគុណគឺបណ្ឌិតគប្បីរាប់, មិត្រល្អ, កល្យាណមិត្រ ។

**កល្ល** នចុំ. [ កល+ល ] ធម្មជាតជាគ្រឿងរាប់ (គួរ, ចំណិត); វិ. **កល្យន្តេ សំខ្យាយន្តេ អនេនាតិ> កល្លំ** ។ - **ភាគ** ចុំ. ចំណែកនៃចំណិត ។

**កល្លកមហាវិហារ** ចុំ. [ កល្លក+មហាវិហារ ] មហាវិហារ (វិហារធំ) ឈ្មោះកល្លកៈ ។

**កល្លវាឡគាមក** ចុំ. [ កល្លវាឡ+គាមក ] ស្រុកតូចឈ្មោះកល្លវាឡៈ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កវរគាវី** ឥ. [ កវរ+គាវី ] មេគោពពាល ។

**កវលិង្ការាហារ** បុំ. [ កវលិង្ការ+អាហារ ] អាហារដែលបុគ្គលធ្វើឱ្យទៅជាពំនូត ។

**កវាដ** បុំ. សន្ទះ, សន្ទះទ្វារ, (គន្លឹះ, គន្លឹះទ្វារ) ។

**កសក** បុំ. [ កស+ណ្វុ ] ជនអ្នកភ្ជួរ (អ្នកស្រែ ឬអ្នកចំការ); វិ. **កសតីតិ> កសកោ** ។ . **ឧបាសក** បុំ. បុគ្គលអ្នកភ្ជួរជាឧបាសក, ឧបាសកអ្នកភ្ជួរ (ឧបាសកអ្នកស្រែ) ។

**កសន** នបុំ. [ កស+យុ ] ជាទីភ្ជួរ, កិ.ភ្ជួរ; វិ. **កសន្តិ ឯត្ថាតិ> កសនំ, កសិយតេតិ> កសនំ** ។ . **ដ្ឋាន** នបុំ. ទីជាទីភ្ជួរ ។ . **អត្ថ** បុំ. ប្រយោជន៍ដល់កិ.ភ្ជួរ, ត្រូវការដល់កិ.ភ្ជួរ ។

**កសា** ឥ. [ កស+អ+អា.ឥ ] រំពាត់, ខ្សែតី ។

**កសាបេតព្វ** គុ. [ កស+ណាបេ+តព្វ ] គឺ...គប្បីឱ្យភ្ជួរ ។

**កសាបេត្វា** អ. [ កស+ណាបេ+ត្វា ] ញុំាង...ឱ្យភ្ជួរហើយ ។

**កសាមសេ** កិ. [ កស+ អ+ម.វ.+សេ.និ. ] ភ្ជួរ, រមែងភ្ជួរ ។

**កសាវ** បុំ. [ ក+សិ+អវ ] សភាវៈសេពនូវទឹក (ទឹកចត់, ទឹកម្ចត់, រសចត់); វិ. **កំ បានីយំ សេចេតីតិ> កសាវោ** ។

**កសិកម្ម** នបុំ. [ កសិ+កម្ម ] កម្មគឺកិ.ភ្ជួរ; វិ. **កសនំ> កសិ; សា ឯវ កម្មំ> កសិកម្មំ** ។ . **អាទិក** គុ. មានកសិកម្មជាដើម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កសិគោរក្ខាទិ** គុ. [ កសិ+គោរក្ខ+អាទិ ] (ជីវិតោបាយ) មានកិ.ភ្ជួរ និង កិ.រក្សានូវគោជាដើម, (កម្ម) មានកសិកម្មនិងគោរក្ខកម្មជាដើម ។

**កសិណបរិកម្ម** នថុំ. [ កសិណ+បរិកម្ម ] បរិកម្មមានកសិណជាអារម្មណ៍, បរិកម្មក្នុងកសិណ ។

**កសិណមណ្ឌល** នថុំ. [ កសិណ+មណ្ឌល ] មណ្ឌលនៃកសិណ ។

**កសិត** គុ. [ កស+ឥ.អា.+ត ] ដែល...ភ្ជួរហើយ ។ . **ដ្ឋាន** នថុំ. ទីនៃ...គី...ភ្ជួរហើយ ។

**កសិតុំ** អ. [ កស+ឥ.អា.+តុំ ] ដើម្បីភ្ជួរ, -រាស់ ។

**កសិត្វា** អ. [ កស+ឥ.អា.+ត្វា ] ភ្ជួរហើយ, រាស់ហើយ ។

**កសិភណ្ឌ** នថុំ. [ កសិ+ភណ្ឌ ] ភណ្ឌៈសម្រាប់ភ្ជួរ, គ្រឿងភ្ជួរ ។

**កសិរ** គុ. [ កស+ឥរ ] ធម្មជាតដល់នូវភាពមិនមែនជាបុណ្យ (លំបាក, ត្រដាបត្រដួស; វិ. ***កសតិ អបុញ្ញន្តិ> កសិរំ***) ។

**កសិវណិជ្ជាទិ** គុ. [ កសិ+វណិជ្ជ+អាទិ ] (កម្ម) មានកិ.ភ្ជួរនិងកិ.ជួញជាដើម, មានកសិកម្មនិងវណិជ្ជកម្មជាដើម ។

**កស្មា** [ កឹ+ស្មា ] ព្រោះហេតុអ្វី, ព្រោះហេតុដូចម្ដេច ។

**កស្សចិ** វិ.ស.អ. [ កឹ+ស.វិ.+ចិ ] ដល់អ្នកណា, ដើម្បីអ្នកណា,... ។

**កស្សប** អ.ន. ភិក្ខុឈ្មោះកស្សបៈ, កុមារឈ្មោះកស្សបៈ, ព្រះពុទ្ធព្រះនាមកស្សបៈ ។ . **ទសពល** ថុំ. ព្រះទសពលព្រះនាមកស្សបៈ ។ . **ពុទ្ធកាល** ថុំ. កាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ។ . **ពុទ្ធសា-**

Websites: WatKhemaraRatanaram.org or WatKhmers.org

**សន** នថុំ. សាសនានៃព្រះពុទ្ធព្រះនាមកស្សបៈ ។ **. សម្មាសម្ពុទ្ធកាល** ថុំ. កាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ។

**កហាបណ** ថុំ.នថុំ. កហាបណៈ (សាច់ប្រាក់ទម្ងន់៤បាទ) ។ **. ការណ** នថុំ. ហេតុនៃកហាបណៈ ។ **. អគ្ឃនក** គុ. ដល់នូវថ្លៃមានកហាបណៈជាប្រមាណ, ដល់នូវថ្លៃមួយកហាបណៈ, ថ្លៃមួយកហាបណៈ, តម្លៃមួយកហាបណៈ, ។ **. គព្ភទ្វារ** នថុំ. ទ្វារនៃបន្ទប់ដ៏ពេញដោយកហាបណៈ; វិ. **កហាបណេហិ បូរោ ឃដោ**> **កហាបណឃដោ** ។ បន្ទប់សម្រាប់ដាក់នូវកហាបណៈ; វិ. **កហាបណានំ ឋបនំ ឃដោ**> **កហាបណឃដោ** ។ **. បសិព្វក** នថុំ. ការុងដ៏ពេញដោយកហាបណៈ, ការុងសម្រាប់ដាក់នូវកហាបណៈ ។ **. បូរ** គុ. ដ៏ពេញដោយកហាបណៈ ។ **. ភណ្ឌិក** នថុំ. បង្វិចនៃកហាបណៈ, បង្វិចដ៏ពេញដោយកហាបណៈ ។ **. រាសិ** ថុំ. គំនរនៃកហាបណៈ ។ **. វស្ស** នថុំ. ភ្លៀងគឺកហាបណៈ ។ **. សត** នថុំ. រយនៃកហាបណៈ ។

**កហំ** អ.ស. [ កឹ+ហំ ] ក្នុងទីណា, ក្នុងទីដូចម្តេច ។

**កំ** វិ.ស.អ. [ កឹ+អំ.វិ ] អ្នកណា, បុគ្គលណា ។

**កំស** ថុំ. [ កន+ស ] មាស, សំរិទ្ធិ, រគាំង ។ **. តាលស្សរ** ថុំ. សំឡេងនៃរគាំង, សូរនៃរគាំង ។ **. ថាល** នថុំ. ភាជនៈជាវិការៈនៃមាស ឬថាសជាវិការៈនៃសំរិទ្ធិ ។ **. ភាជនបូរ** គុ. ដ៏ពេញក្នុងភាជនៈជាការៈនៃសំរិទ្ធិ, .នៃមាស ។ **. បាតិ** ឥ. ភាជនៈជាវិការៈនៃមាស (ភាជនៈមាស) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កា** វិ.ស.អ. [ កឹ+សិ.វិ. ] ណា, នាងណា, ដូចម្ដេច ។

**កាក** ចុំ. [ កា+ក ] សត្វធ្វើនូវសំឡេងថា «កា» (ក្អែក); វិ. **កាតិ សទ្ទំ ករោតីតិ> កាកោ** ។ - **បេយ្យ** ចុំ. កាកប្រេត, ប្រេតមានសីសៈដូចជាសីសៈនៃក្អែក, ប្រេតដូចជាក្អែក ។ - **យោនិ** ឥ. កំណើតនៃក្អែក ។ - **វល្លិយ** អ.ន. សេដ្ឋីឈ្មោះកាកវល្លិយៈ ។ - **សទិស** គុ. អ្នកដូចជាក្អែក, អ្នកប្រហែលដោយក្អែក, អ្នកប្រាកដស្មើដោយក្អែក ។ - **សុនខសន្និបាត** ចុំ. កិ.ប្រជុំនៃក្អែកនិងឆ្កែ, កិ.ជួបជុំនៃ... ។ - **ស្សូរ** គុ. អ្នកក្លៀវក្លាដូចជាក្អែក ។

**កាកណិក** នចុំ. (ឈ្មោះប្រាក់បុរាណ ដែលគេប្រើក្នុងមជ្ឈិមប្បទេស) កាកណិក, ទ្រព្យមានកាកណិកជាប្រមាណ ។ - **មត្ត** គុ. មានកាកណិកជាប្រមាណ, ត្រឹមតែមួយកាកណិក, ទ្រព្យត្រឹមតែមួយកាកណិក ។

**កាកីសទិស** គុ. [ កាកី+សទិស ] ដូចជាមេក្អែក, ប្រហែលដោយមេក្អែក, ប្រាកដស្មើដោយមេក្អែក ។

**កាកោបមា** ឥ. [ កាក+ឧបមា ] វាចាជាគ្រឿងប្រៀបដោយក្អែក, សេចក្ដីប្រៀបដោយក្អែក, ឧបមាដោយក្អែក ។

**កាកោឡូក** ចុំ. [ កាក+ឧឡូក ] ក្អែកនិងមៀម ។

**កាញ្ចនគុហា** ឥ. [ កាញ្ចន+គុហា ] គុហាជាវិការៈនៃមាស, គុហាដែលគេធ្វើដោយមាស ។

**កាញ្ចនថូប** ចុំ. [ កាញ្ចន+ថូប ] ស្តូបជាវិការៈនៃមាស, (ចេតិយជា

Websites: WatKhemaraRatanaram.org or WatKhmers.org

វិការៈនៃមាស); វិ. **ភាញ្ចនស្ស ឋិភារោ ថ្វេបោ> ភាញ្ចនថ្វេបោ** ។ ស្លាបដែលគេធ្វើដោយមាស; វិ. **ភាញ្ចនេន ភតោ ថ្វេបោ> ភាញ្ចនថ្វេបោ** ។

**កាញ្ចនរូបក** នបុំ. [ កាញ្ចន+រូបក ] រូបតូចជាវិការៈនៃមាស (រូបប្រៀបជាវិការៈនៃមាស) ។

**កាណ** គុ. [ កណ+ណ ] ខ្វាក់, មានភ្នែកខ្វាក់ ។ អភិ.សុ. ភ្នែកខ្វាក់តែម្ខាងក្តី ខ្វាក់ទាំងពីរខាងក្តី ហៅថា «កាណ» ។ អ.ក. ភ្នែកខ្វាក់តែម្ខាងហៅថា «កាណ» ; ខ្វាក់ទាំងពីរខាងហៅថា «អន្ធ», ពាក្យនេះសមតាមកាណកច្ឆបោបមសូត្រ ដែលនិយាយអំពីអណ្តើកខ្វាក់ភ្នែកតែម្ខាង ។ **-អាទិភាវ** បុំ. ភាវៈនៃ...ជាសត្វមានភ្នែកខ្វាក់ជាដើម ។ **-មាតា** ឥ. មាតានៃស្ត្រីឈ្មោះកាណា ។ **-មាតាវត្ថុ** នបុំ. រឿងនៃមាតានៃស្ត្រីឈ្មោះកាណា ។

**កាណាជិក** នបុំ. [ កណ+ជន+ឥក ] បាយកើតអំពីចុងអង្ករ (បាយចុងអង្ករ, បាយលាយដោយកន្ទក់, បាយទាំងកន្ទក់); វិ. **ភណាតោ ខាយតីតិ> ភាណាខិភំ** ។ ប្រើជា «កណាជក» ក៏មាន ។

**កាតព្វ** គុ. [ ករ+តព្វ ] គឺ...គប្បីធ្វើ, -ត្រូវធ្វើ, -គួរធ្វើ ។

**កាតុកាម** គុ. [ កាតុំ+កម+ណ ] អ្នកប្រាថ្នាដើម្បីធ្វើ, អ្នកចង់ដើម្បីធ្វើ; វិ. **ភាតុំ ភាមេតីតិ> ភាតុភាមោ** ។

**កាតុំ** អ. [ ករ+តុំ ] ដើម្បីធ្វើ, វីកិ.ធ្វើ ។

**កាបុរិស** បុំ. [ កុ>កា+បុរិស ] បុរសដែលបណ្ឌិតគួរខ្ពើម (បុរសលាមក,

Websites: WatKhemaraRatanaram.org or WatKhmers.org

បុរសអាក្រក់); វិ. **កុច្ឆិតោ បុរិសោ> កាបុរិសោ ។**

**កាបោតក** គុ. [ កបោត+ណក ] មានពណ៌ដូចជាពណ៌នៃព្រាប, មានសម្បុរដូចជាសម្បុរនៃព្រាប ។

**កាម** ពុំ. [ កម+ណ ] សេចក្ដីប្រាថ្នា, សេចក្ដីចង់បាន, ចំណង់; វិ. **កមនំ ឥច្ឆនំ> កាមោ ។ - កណ្ដក** ពុំ. បន្លាគឺកាម, កាមដូចជាបន្លា ។ **- កាម** គុ. អ្នកប្រាថ្នានូវកាម ។ **- ការណ** នពុំ. ហេតុនៃកាម ។ **- គវេសក** គុ. អ្នកស្វែងរកនូវកាម; វិ. **កាមំ គវេសតិ> កាមគវេសកោ ។ - គវេសី** ពុំ. អ្នកស្វែងរកនូវកាម, អ្នកស្វែងរកនូវកាមដោយប្រក្រតី, អ្នកមានកិ.ស្វែងរកនូវកាមជាប្រក្រតី; វិ. **កាមេ គវេសតិ> កាម-គវេសី; កាមេ គវេសតិ សីលេនាតិ> កាមគវេសី; កាមេ គវេសិតុំ សីលមស្សាតិ> កាមគវេសី ។ - ច្ឆន្ទាទិ** គុ. (កិលេស) មានកាមច្ឆន្ទៈជាដើម, មានសេចក្ដីពេញចិត្តក្នុងកាមជាដើម, មានសេចក្ដីពេញចិត្តប្រព្រឹត្តទៅក្នុងកាមជាដើម ។ **- បង្ក** ពុំ. ភក់គឺកាម, កាមដូចជាភក់ ។ **- បរិឡាហ** ពុំ. សេចក្ដីរោលរាលព្រោះកាម, សេចក្ដីក្ដៅក្រហាយព្រោះកាម ។ **- ព្យាបាទវិហឹសាវិតក្កវសិកតា** ឥ. ភាវៈនៃ...នោះជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃកាមវិតក្កៈ និងព្យាបាទវិតក្កៈ និងវិហឹសាវិតក្កៈ ។ **- ភវបរិក្ខីណ** គុ. មានកាមភពអស់ជុំវិញហើយ, មានកាមភពអស់រលីងហើយ ។ **- ភវាទិ** គុ. (ភព) មានកាមភពជាដើម ។ **- ភោគី** ពុំ. អ្នកបរិភោគនូវកាម, អ្នកបរិភោគ

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវកាមដោយប្រក្រតី, អ្នកមានកិ.បរិភោគនូវកាមជាប្រក្រតី ។ - យន្ត គុ. [ <កម+ណយ+អន្ត ] កាលប្រាថ្នា, កាលចង់បាន ។ - យោគាទិ គុ. (យោគៈ) មានកាមយោគៈជាដើម ។ - រជ ចុំ. ធូលីគឺកាម ។ - រតិនិស្សិត គុ. អ្នកអាស្រ័យហើយនូវសេចក្តីត្រេកអរក្នុងកាម, អ្នកគឺសេចក្តីត្រេកអរក្នុងកាមអាស្រ័យហើយ ។ - រតិសន្ថវ ចុំ. សេចក្តីរីករាយព្រមដោយអំណាចនៃសេចក្តីត្រេកអរក្នុងកាម ។ - រាគសំយោជនាទិក គុ. មានសំយោជនៈគឺកាមរាគជាដើម, មានកាមរាគសំយោជនៈជាដើម ។ - រាគាទិ គុ. មានសេចក្តីរីករាយក្នុងកាមជាដើម, មានកាមរាគជាដើម ។ - វិតក្កាទិ គុ. មានសេចក្តីត្រិះរិះក្នុងកាមជាដើម, មានកាមវិតក្កៈជាដើម ។ - សញ្ញោជនីយជន នចុំ. ការតនូវកិ.ប្រកបព្រមដោយកាម, កិ.ដើម្បីកិ.ប្រកបព្រមដោយកាម ។ - សំយោគាទិ គុ. មានធម៌ជាគ្រឿងប្រកបព្រមគឺកាមជាដើម, មានធម៌ជាគ្រឿងប្រកបព្រមដើម្បីកាមជាដើម ។ - សុខសទិស គុ. ប្រាកដស្មើដោយសុខ ក្នុងកាម ។ - សុខ នចុំ. សេចក្តីសុខក្នុងកាម ។ - ហេតុ ចុំ. ហេតុនៃកាម ។

**កាមគុណ** ចុំ. [ កាម+គុណ ] កាមគុណ, សភាវៈជាគ្រឿងចងគឺកាម, កាមជាគ្រឿងចង ។ - បរិយេសន នចុំ. កិ.ស្វែងរកនូវកាមគុណ ។ - សម្បត្តិ ឥ. ឬ គុ. កិ.ដល់ព្រមដោយកាមគុណ, ធម្មជាតិជាហេតុដល់ព្រមដោយកាមគុណ ។

**កាមាវចរ** គុ. [ កាម+អវ+ចរ+អ ] ដែលត្រាច់ចុះក្នុងកាមភព ឬដែល

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រព្រឹត្តទៅក្នុងកាមភពជាកាមាវចរ; វិ. **កាមភវេ អវចរតិ បវត្តតីតិ> កាមាវចរំ** ។ - **កុសលចិត្ត** នបុំ. ចិត្តជាកុសលជាកាមាវចរ, កុសលចិត្តជាកាមាវចរ ។ - **កុសលាទិភេទ** គុ. ផ្សេងដោយចិត្តមានចិត្តជាកុសលជាកាមាវចរជាដើម, មានចិត្តជាកុសលជាកាមាវចរជាដើមជាប្រភេទ ។

**កាមោឃាទិ** គុ. [ កាមោឃ+អាទិ ] (ឱឃៈ) មានកាមោឃៈជាដើម, (អន្លង់) មានអន្លង់គឺកាមជាដើម ។

**កាមំ** និ. ពិត, ដោយពិត ។

**កាយ** បុំ. [ កុ+អាយ ] សភាវៈជាទីនៅនៃធម៌ប្រព្រឹត្តទៅមួយអន្លើដោយអាសវៈដែលបណ្ឌិតគួរខ្ពើម, ប្រទេសជាទីកើតនៃអាការៈមានសក់ជាដើមដែលបណ្ឌិតគួរខ្ពើម, (កាយ, សរីរៈ, ពួក, ក្រុម); វិ. **កុច្ឆិតានំ សាសវធម្មានំ អាយោតិ> កាយោ** ; **កុច្ឆិតានំ កេសាទីនំ អាយោ ឧប្បត្តិទេសោតិ> កាយោ** ។ - **កម្ម** នបុំ. កាយកម្ម, កម្មគឺបុគ្គលគប្បីធ្វើដោយកាយ; វិ. **កាយេន កាតព្វំ កម្មំ> កាយកម្មំ** ។ - **កម្មាទិក** គុ. មានកាយកម្មជាដើម ។ - **គត** គុ. ទៅហើយក្នុងកាយ, តាំងនៅក្នុងកាយ ។ - **ចលនសីសុក្ខិបនភមុកវិការាទិ** គុ. (អាការ) មាន កិ.កម្រើកនៃកាយ និងកិ.ងើបនៃក្បាល និងកិ.ញាក់នូវចិញ្ចើមជាដើម ។ - **ទណ្ឌាទិវិរហិត** គុ. ដែលប្រាសចាកអាជ្ញា មានអាជ្ញាគឺកាយជាដើម, ដែលវៀរចាកអាជ្ញា មានអាជ្ញាគឺកាយជាដើម។ - **ទណ្ឌាទិ** គុ. (អាជ្ញា) មានអាជ្ញាគឺកាយជាដើម,

Websites: WatKhemaraRatanaram.org or WatKhmers.org

មានអាជ្ញាដោយកាយជាដើម ។ . **ទុច្ចរិតាទិអកុសលកម្មាភិរត** គុ. អ្នកត្រេកអរស៊ប់ហើយក្នុងអកុសលកម្មមានកាយទុច្ចរិតជាដើម ។ . **ទុច្ចរិតាទិ** គុ. (ទុច្ចរិត) មានកាយទុច្ចរិតជាដើម ។ . **ទុច្ចរិតតាទិប្បវេសននិវារណត្ថាចារ** គុ. មានអាចារៈគឺកិ.ឃាត់នូវកិ.ចូលទៅ នៃទុច្ចរិតមានកាយទុច្ចរិតជាដើមជាប្រយោជន៍ ។ . **ទុច្ចរិតាទិភេទ** គុ. ផ្សេងដោយទុច្ចរិតមានកាយទុច្ចរិតជាដើម ។ . **ទុច្ចរិតាទិវិរហិត** គុ. ដែលប្រាសចាកទុច្ចរិតមានកាយទុច្ចរិតជាដើម, ដែលវៀរចាកទុច្ចរិតមានកាយទុច្ចរិតជាដើម ។ . **ទ្វារ** នថុំ. កាយទ្វារ, ទ្វារគឺកាយ ។ . **និស្សិត** គុ. អាស្រ័យហើយនូវកាយ, អាស្រ័យហើយក្នុងកាយ ។ . **ប្បគ-ព្ភិយាទិ** គុ. (សេចក្តីឃ្នើសឃ្នង) មានសេចក្តីឃ្នើសឃ្នងដោយកាយជាដើម, (អាការ) មានកិ.ច្រឡើសបើសដោយកាយជាដើម ។ . **ប្បកោប** ថុំ. កិ.កម្រើកដោយកាយ, កិ.កម្រើកនៃកាយ ។ . **ពន្ធនមណ្ឌន** នថុំ. កិ.ប្រដាប់នូវចីវរ (នូវសំពត់) សម្រាប់ចងនូវកាយ, កិ.ប្រដាប់ នូវវត្ថពន្ធ, កិ.ប្រដាប់នូវវត្ថពន្ធចង្កេះ ។ . **ពន្ធន** នថុំ. សំពត់សម្រាប់ចងនូវកាយ, វត្ថពន្ធចង្កេះ ។ . **វចី-មនោកម្ម** នថុំ. កាយកម្ម និងវចីកម្ម និងមនោកម្ម ។ . **វង្កាទិ** គុ. (កិ.វៀច) មានកិ.វៀច ដោយកាយជាដើម ។ . **វត្ថុក** គុ. មានកាយជាវត្ថុ, មានកាយជាលំនៅ, មានកាយជាទីតាំង ។ . **វាចាទិ** គុ. (ទ្វារ) មានកាយ និងវាចាជាដើម ។ . **វិជម្ភនរហិត** គុ. ដែលប្រាសចាកកិ.មិតពត់នូវកាយ, ដែលវៀរចាកកិ.កែក្រាយដោយកាយ ។ . **វិជម្ភិតា** ឥ. ភាវៈនៃ...ជាអ្នកមានកិ.មិតពត់នូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

កាយ, ភាវៈនៃ...ជាអ្នកមានកិ.កែក្រាយដោយកាយ ។ . **វិវេកាទិក** គុ. មានសេចក្ដីស្ងប់ស្ងាត់នៃកាយជាដើម, មានកាយវិវេកជាដើម ។ . **វិវេក** ចុំ. សេចក្ដីស្ងប់ស្ងាត់នៃកាយ (វិវេក<វិ+វិច+ណ) ។ . **វេយ្យាវច្ចិក** គុ. កិ.ខ្វល់ខ្វាយដោយកាយ, កិច្ចប្រកបដោយកិ.ខ្វល់ខ្វាយដោយកាយ, អ្នកប្រកបក្នុងកិ.ខ្វល់ខ្វាយដោយកាយ ។ . **សញ្ញមាទវិរហិត** គុ. ដែលប្រាសហើយចាកកិ.សង្រួមមានកិ.សង្រួមដោយកាយជាដើម, វៀរហើយចាកកិ.សង្រួមមានកិ.សង្រួមដោយកាយជាដើម ។ . **សញ្ញមាទិ** គុ. (កិ.សង្រួម) មាន កិ.សង្រួមដោយកាយជាដើម ។ . **សមាចារ** ចុំ. សមាចារៈនៃ កាយ, មារយាទជាគ្រឿងប្រព្រឹត្តស្មើដោយកាយ ។ . **សុចរិត** នចុំ. កាយសុចរិត, កម្មដែលបុគ្គលប្រព្រឹត្តល្អហើយដោយកាយ ។ . **សុចរិតាទិ** គុ. មានកាយសុចរិតជាដើម ។ . **សុចរិតាទិភេទ** គុ. ផ្សេងដោយសុចរិតមានកាយសុចរិតជាដើម, មានកម្មដែលបុគ្គលប្រព្រឹត្តល្អហើយដោយកាយជាដើមជាប្រភេទ ។ . **អាទិសញ្ញមវិរហិត** គុ. អ្នកប្រាសហើយចាកកិ.សង្រួមនូវទ្វារមានកាយទ្វារជាដើម, អ្នកវៀរហើយចាកកិ.សង្រួមនូវទ្វារមានកាយទ្វារជាដើម ។ . **អានុបស្សនាភាវនា** កិ.ញុំាងបញ្ញា ជាគ្រឿងឃើញរឿយៗក្នុងកាយឱ្យចម្រើន, គុណជាតិជាគ្រឿងញុំាងបញ្ញាជាហេតុឃើញតាមនូវកាយឱ្យចម្រើន, ភាវនាប្រព្រឹត្តទៅដោយអំណាចនៃបញ្ញាជាគ្រឿងឃើញរឿយៗក្នុងកាយ ។ . **អារុឡ្ហ** គុ. ឡើងកាន់កាយ ។ . **អាលសិយ** នចុំ. ភាវៈនៃបុគ្គលខ្ជិលដោយកាយ; វិ. អល-

Websites: WatKhemaraRatanaram.org or WatKhmers.org

**សស្ស ភាវោ> អាលសិយំ; កាយេន អាលសិយំ> កាយាលសិយំ** ។

**កាយិក** គុ. [ កាយ+ណិក ] ប្រព្រឹត្តទៅក្នុងកាយ, វិ. **កាយេ បវត្ត-តីតិ> កាយិកំ** ។ ប្រកបក្នុងកាយ; វិ. **កាយេ និយុត្តំ> កាយិកំ** ។ . **ចេតសិកវិរិយ** នបុំ. ព្យាយាមប្រព្រឹត្តទៅក្នុងកាយ និងប្រព្រឹត្តទៅក្នុងចិត្ត ។ . **បរិឡាហ** បុំ. សេចក្ដីរោលរាលប្រព្រឹត្តទៅក្នុងកាយ, សេចក្ដីក្ដៅក្រហាយប្រព្រឹត្តទៅក្នុងកាយ ។

**ការ** បុំ. [ ករ+ណ ] កុសលគឺបុគ្គលគប្បីធ្វើ, សក្ការៈគឺបុគ្គលគប្បីធ្វើ, វិ. **កាតព្វោតិ> ការោ** ។

**ការក** បុំ.,នបុំ. [ ករ+ណ្វុ ] អ្នកធ្វើ; វិ. **ករោតីតិ> ការកោ** ។ . **បុគ្គល** បុំ. បុគ្គលអ្នកធ្វើ ។ . **សត្ត** បុំ. សត្វអ្នកធ្វើ ។

**ការណ** នបុំ. [ ករ+យុ ] ធម្មជាតធ្វើនូវផលពោលគឺកិ.ដឹងច្បាស់ក្នុងកាលជាខាងក្រោយ (ហេតុ, ការណ៍); វិ. **ករោតិ បច្ឆា សញ្ញាននសង្ខាតំ ផលន្តិ> ការណំ** ។ . **ភូត** គុ. ជាហេតុកើតហើយ, កើតហើយជាហេតុ ។ . **វចន** នបុំ. ជាគ្រឿងពោលនូវហេតុ, កិ.ពោលនូវហេតុ ។ . **វសិកតា** ឥ. ភាវៈនៃ...ជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ; វិ. **ការណស្ស វសោ> ការណវសោ, ការណវសេ វត្តតីតិ> ការណវសិ-កោ, តស្ស ភាវោ> ការណវសិកតា** ។ . **វសិក** គុ. អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ។ . **ឧត្តរយុគគ្គាហកថា**

Websites: WatKhemaraRatanaram.org or WatKhmers.org

ឥ. វាចាជាគ្រឿងពោលគឺកិ.កាន់យកជាតួឱ្យក្រៃលែងជាងហេតុ, វាចាជាហេតុពោលគឺកិ.កាន់យកនូវតួឱ្យក្រៃលែងជាងហេតុ ។

**ការណាការណ** នថុំ. [ ការណ+អការណ ] ហេតុនិងមិនមែនហេតុ, ហេតុគួរ និងហេតុមិនគួរ ។ - **ជានទលក្ខណ** គុ. មានកិ.ដឹងនូវហេតុនិងមិនមែនហេតុជាលក្ខណៈ, មានកិ.ដឹងនូវហេតុគួរ និងហេតុមិនគួរជាលក្ខណៈ ។

**ការយិស្ស** កិ. [ ករ+ណយ+ឥំ_អជ្ជ. ] ញ៉ាំង...ឱ្យធ្វើហើយ, ឱ្យធ្វើហើយ ។

**ការាបនីយ** គុ. [ ករ+ណាបេ+អនីយ ] គឺ...គប្បីញ៉ាំង...ឱ្យធ្វើ, -គប្បីឱ្យធ្វើ; វិ. **ការាបេតព្វោតិ> ការាបនីយោ** ។

**ការាបេត្វា** អ. [ ករ+ណាបេ+ត្វា ] ញ៉ាំងឱ្យធ្វើហើយ, ឱ្យធ្វើហើយ ។

**ការាបេស្សាមិ** កិ. [ ករ+ណាបេ+ស្សាមិ_ភ. ] នឹងញ៉ាំង...ឱ្យធ្វើ, នឹងឱ្យធ្វើ ។

**ការិត** គុ. [ ករ+ណេ+ត ] គឺ...ញ៉ាំង...ឱ្យធ្វើហើយ ។ - **ត្តំ** នថុំ. ភាវៈនៃ...នោះជា...គឺ...ញ៉ាំង...ឱ្យធ្វើហើយ ។ - **បណ្ឌសាលា** ឥ. បណ្ឌសាលាគឺ...ញ៉ាំង...ឱ្យធ្វើហើយ ។

**ការី** ថុំ. [ ករ+ណី ] អ្នកធ្វើ, អ្នកធ្វើដោយប្រក្រតី, អ្នកមានកិ.ធ្វើជាប្រក្រតី; វិ. **ករោតីតិ> ការី, ករោតិ សីលេនាតិ> ការី, ការំ សីលមស្សាតិ> ការី** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ការុញ្ញតរ** គុ. [ ការុញ្ញ+តរ ] ភាវៈនៃករុណាជាង, មានភាវៈនៃសេចក្ដីអាណិតជាង ។

**ការុញ្ញតា** ឥ. [ ករុណា+ណ្យ+តា_ស. ] ភាវៈនៃសេចក្ដីករុណា, ភាវៈនៃសេចក្ដីអាណិត; វិ. **ករុណាយ ភាវោ> ការុញ្ញំ, ការុញ្ញំ ឯវ> ការុញ្ញតា** ។

**ការុញ្ញវស** ចុំ. [ ការុញ្ញ+វស ] អំណាចនៃភាវៈនៃសេចក្ដីករុណា ។

**ការេតុ** កិ. [ ករ+ណេ+តុ_ប. ] ចូរញ៉ាំង...ឱ្យធ្វើ ។

**ការេតុកាម** គុ. [ ការេតុំ+កម+ណ ] អ្នកចង់ដើម្បីញ៉ាំង...ឱ្យធ្វើ ។

**ការេតុំ** អ. [ ករ+ណេ+តុំ. ] ដើម្បីញ៉ាំង...ឱ្យធ្វើ ។

**ការេន្តិ** កិ. [ ករ+ណេ+អន្តិ_វ. ] ញ៉ាំង...ឱ្យធ្វើ ។

**ការេន្ត** គុ. [ ករ+ណេ+អន្ត ] កាលញ៉ាំង...ឱ្យធ្វើ ។

**ការេមិ** កិ. [ ករ+ណេ+មិ_វ. ] ញ៉ាំង...ឱ្យធ្វើ ។

**ការេយ្យុំ** កិ. [ ករ+ណេ+ឯយ្យុំ_ស. ] គប្បីញ៉ាំង...ឱ្យធ្វើ ។

**ការេសិ** កិ. [ ករ+ណេ+ឦ_អជ្ជ., ចុះស_អា. ] ញ៉ាំង...ឱ្យធ្វើហើយ ។

**ការេស្សថ** កិ. [ ករ+ណេ+ស្សថ_ភ. ] នឹងញ៉ាំង...ឱ្យធ្វើ ។

**ការេស្សំ** កិ. [ ករ+ណេ+ស្សំ_ភ. ] នឹងញ៉ាំង...ឱ្យធ្វើ ។

**កាល** ចុំ. [ កល+ណ ] (បរិច្ឆេទ) ដែលជនគប្បីរាប់ ដោយន័យថា កាលមានប្រមាណប៉ុណ្ណោះកន្លងទៅហើយដូច្នេះជាដើម ឬ

Websites: WatKhemaraRatanaram.org or WatKhmers.org

(បរិច្ឆេទ) ដែលញ៉ាំងអាយុនៃសត្វឱ្យអស់ទៅ (កាល, ពេល, សម័យ, សេចក្ដីស្លាប់); វិ. ឯកត្តកោ អតិក្កន្តោតិអាធិនា គលិតព្វោ សទ្ធាគព្វោតិ> កាលោ, សត្តានំ អាយុំ គលយតិ ខេបេតីតិ វា> កាលោ ។ . កត ត្រ. អ្នកមាន កាលៈធ្វើហើយ, អ្នកមានមរណកាលធ្វើហើយ; វិ. កាលោ កតោ យេន សោ> កាលកតោ ។ អ្នកគឺកាលៈ (សេចក្ដី ស្លាប់) ធ្វើហើយ, អ្នកគឺមច្ចុឱ្យវិនាសហើយ; វិ. កាលេន មច្ចុនា កតោ នាសិតោតិ> កាលកតោ ។ . កតភាវ ថ្ម. ភាវៈនៃ...នោះជាអ្នកមានកាលៈធ្វើហើយ, ភាវៈនៃ...នោះជា អ្នកគឺកាលៈធ្វើហើយ ។ . កិរិយា ៥. កិ.ធ្វើនូវកាលៈ, កិ.ធ្វើនូវ មរណកាល ។ . អច្ចយ ថ្ម. សម័យជាទីប្រព្រឹត្តកន្លងទៅនៃកាល; វិ. អច្ចេន្តិ ឯត្ថាតិ> អច្ចយោ, កាលស្ស អច្ចយោ> កាលច្ចយោ ។ . ប្បវេទន នថ្ម. កិ.ញ៉ាំង...ឱ្យដឹងច្បាស់នូវ កាល, កិ.សម្ដែងនូវកាល ។ . ភេទ ថ្ម. សេចក្ដីផ្សេងនៃកាល ។

**កាលស្សេវ** និ. អំពីកាលមែនពិត, អំពីព្រឹក, អំពីព្រលឹម ។

**កាលានុកាល** ថ្ម. [ កាល+អនុកាល ] កាលប្រព្រឹត្តតាមនូវកាល, កាលដ៏សមគួរដល់កាល, មួយដងមួយកាល ។

**កាលិ** អា.៥. ម្នាលទាសីឈ្មោះកាលី ។ ប្រើជា **កាឡិ** ក៏មាន ។

**កាលិង្គរដ្ឋ** នថ្ម. [ កាលិង្គ+រដ្ឋ ] ដែនឈ្មោះកាលិង្គៈ ។

**កាលីទាសី** ៥. [ កាលី+ទាសី ] ទាសីឈ្មោះកាលី, ខ្ញុំស្រីឈ្មោះកាលី ។

**កាលីយក្ខិនី** ឥ. [ កាលិ+យក្ខិនី ] យក្ខិនីឈ្មោះកាលិ, មេយក្សឈ្មោះកាលិ ។

**កាស** ពុំ. [ កាស+អ ] កិ.ក្អក, រោគក្អក ។

**កាសាយ** នពុំ. [ កសាយ+ណ ] សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់ (សំពត់កាសាយៈ); វិ. **កសាយេន រត្តំ> កាសាយំ** ។ **-និវត្ថ** គុ. (<និ+វស+ត) អ្នកស្លៀកនូវសំពត់កាសាយៈ, អ្នកស្លៀកនូវសំពត់ដែលជនជ្រលក់ហើយដោយទឹកចត់; វិ. **កាសាយំ និវាសេតីតិ> កាសាយនិវត្ថោ** ។ អ្នកមានសំពត់កាសាយៈស្លៀកហើយ; វិ. **កាសាយំ និវត្ថំ យេន សោ> កាសាយនិវត្ថោ** ។ **-បជ្ជោត្ត** គុ. គឺសំពត់កាសាយៈបិទបាំងហើយ, មានសំពត់កាសាយៈបិទបាំងហើយ, ដ៏បិទបាំងហើយដោយសំពត់កាសាយៈ ។ **-វត្ថនិវត្ថ** គុ. ស្លៀកនូវសំពត់កាសាយៈ, ស្លៀកនូវសំពត់ដែលជ្រលក់ហើយដោយទឹកចត់ ។ **-វត្ថ** នពុំ. សំពត់កាសាយៈ, សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់ ។

**កាសាវ** នពុំ. [ កសាវ+ណ ] សំពត់ដែលជនជ្រលក់ហើយដោយទឹកចត់, (សំពត់កាសាវៈ); វិ. **កសាវេន រត្តំ> កាសាវំ** ។ **-កណ្ឋ** គុ. មានសំពត់កាសាវៈព្ធដ៏ក, មានកព័ទ្ធព័ទ្ធហើយដោយសំពត់កាសាវៈ ។ **-កោដិ** ឥ. ទីបំផុតនៃសំពត់កាសាវៈ, ចុងនៃសំពត់កាសាវៈ ។ **-ធរ** គុ. អ្នកទ្រទ្រង់នូវសំពត់កាសាវៈ; វិ. **កាសាវំ ធារេតីតិ> កាសាវធរោ** ។

**កាសិក** គុ. [ កាសី+ណិក ] អ្នកនៅក្នុងដែនកាសី, កើតក្នុងដែនកាសី ។

Websites: WatKhemaraRatanaram.org or WatKhmers.org

- កោសលរដ្ឋ នបុំ. ដែនឈ្មោះកាសីនិងដែនឈ្មោះកោសល ។ - គ្គាមក ពុំ. ស្រុកតូចឈ្មោះកាសិកៈ ឬស្រុកតូចតាំងនៅក្នុងដែនកាសី ។ - គ្គាម ពុំ. ស្រុកឈ្មោះកាសិកៈ ឬ ស្រុកតាំងនៅក្នុងដែនកាសី ។ - វត្ថ នបុំ. សំពត់ដែលកើតក្នុងដែនកាសី, សំពត់ដែលជននាំមកអំពីដែនកាសី ។ - រាជ ពុំ. ស្ដេចក្នុងដែនកាសី ។ - បុរ នបុំ. បុរីនៃស្ដេចនៅក្នុងដែនកាសី, ក្រុងឈ្មោះកាសី ។

**កាសិត្វា** អ. [ កាស+ឥ_អា+ត្វា ] ក្អកហើយ ។

**កាហសិ** កិ. [ ករ+អ+ស្សសិ_ភ., ផ្លាស់ក>កាហ, លុបស្សទុកតែសិ ] នឹងធ្វើ ។

**កាហាមិ** កិ. [ ករ+អ+ស្សាមិ_ភ. ] នឹងធ្វើ (រូបសិទ្ធិដូច កាហសិ) ។

**កាឡ** គុ. [ កិរ+ណ ] សភាវៈបោះបង់នូវពណ៌ស (ខ្មៅ, ពណ៌ខ្មៅ); វិ. កិរតិ សុក្កន្តិ> កាលោ, កាលោ ឯវ> កាឡោ ។ - កណ្ណិ អា.ឥ. ម្នាលមេកាឡកណ្ណិ(ម្នាលស្រីអ្នកធ្វើនូវទីនៅនៃខ្លួនឱ្យទៅជាទីមានសម្បុរខ្មៅ, ម្នាលមេចង្រៃ) ។ - កណ្ណិក គុ. ជាកាឡកណ្ណិ ។ - ចម្ម នបុំ. ស្បែកខ្មៅ, ស្បែកមានពណ៌ខ្មៅ ។ - ត្ថេរវត្ថុ នបុំ. រឿងនៃព្រះថេរៈឈ្មោះកាឡៈ ។ - មត្តិកា ឥ. មានដីមានពណ៌ខ្មៅ, ដីខ្មៅ, ដីស្អិតមានពណ៌ខ្មៅ ។ - វណ្ណ គុ. មានពណ៌ខ្មៅ ។ - សិលាបទេស ពុំ. ប្រទេសឈ្មោះកាឡសិលា ។ - សិលា អ.ន. ប្រទេសឈ្មោះកាឡសិលា, ភូមិឈ្មោះកាឡសិលា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កាឡក** គុ. [ កាឡ+ណក ឬក.ស. ] វត្ថុមានពណ៌ខ្មៅ, ធមិមានពណ៌ខ្មៅ ។

**កាឡាយមត្ត** គុ. [ កាឡាយ+មត្ត ] មានសណ្តែកខ្មៅជាប្រមាណ, ប៉ុនសណ្តែកខ្មៅ ។

**កាឡី** ឥ. [ កាឡ+ឦ ] មានពណ៌ខ្មៅ, ស្រីមានសម្បុរខ្មៅ ។

**កាឡុទាយិត្ថេរ** ចុំ. [ កាឡុទាយិ+ថេរ ] ព្រះថេរៈឈ្មោះកាឡុទាយិ ។

**កិកិ** អ.ន. ឈ្មោះកិកិ ។

**កិច្ច** នចុំ. [ ករ+រិច្ច ] កម្មគឺបុគ្គលគប្បីធ្វើ (កិច្ច); វិ. **ការេតព្វន្តិ> កិច្ចំ** ។ . **បរិយោសាន** នចុំ. កាលជាទីបំផុតចុះជុំវិញនៃកិច្ច, កាលជាទីចប់នៃកិច្ច, កាលជាទីស្រេចហើយនៃកិច្ច ។

**កិច្ចាកិច្ច** នចុំ. [ កិច្ច+អកិច្ច ] កិច្ច និងមិនមែនកិច្ច (អ<ន=ប្រែថា «មិនមែន»), កិច្ចនិងកិច្ចដ៏ចំរើន (អ=ប្រែថា«ចំរើន»), កិច្ចតូចនិងកិច្ចធំ(អ=ប្រែថា«ធំ») ។

**កិច្ឆ** គុ. [ កិរ+ឆ ] ធម្មជាតបោះបង់នូវសេចក្តីសុខ (ក្រ, លំបាក, ត្រដាបត្រដួស); វិ. **កិរតិ សុខន្តិ> កិច្ឆំ** ។ (កិច្ឆ<កិត+ឆ) ធម្មជាតជាគ្រឿងលំបាក; វិ. **កិច្ឆតិ កាយ កិលមតីតិ> កិច្ឆា** ។ . **ជីវិក** គុ. អ្នកមានកិ.រស់នៅដោយលំបាក; វិ. **ជីវនំ> ជីវោ, កិច្ឆេន ជីវោ> កិច្ឆជីវោ, កិច្ឆជីវោ យស្ស អត្ថីតិ> កិច្ឆជីវី, កិច្ឆជីវី ឯវ> កិច្ឆជីវិកោ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កិច្ចាធិគត** គុ. [ កិច្ច+អធិគត ] គឺ...បានហើយដោយលំបាក, -ដោយកម្រ ។

**កិញ្ចន** នបុំ. [ កិច+យុ, ចុះនិ_អា. ] កិលេសជាតជាគ្រឿងកង្វល់, កិលេសជាតជាគ្រឿងញាំញី; វិ. **កិញ្ចតិ ឯតេនាតិ> កិញ្ចនំ** ។ សេចក្តីខ្វល់, កង្វល់; វិ. **កិញ្ចិយតេតិ> កិញ្ចនំ** ។

**កិញ្ចាបិ** និ. [ កឹ+ច+អបិ ] ប្រាកដមែនហើយ, ក៏មែនហើយ, ក៏ពិតមែនហើយ, សូម្បីតិចតួច ។

**កិញ្ចិ** វិ.ស.អ. [ កឹ+ចិ ] តិចតួច, អ្វីៗ, នីមួយ,... ។

**កិដាគិរិ** បុំ. ភ្នំឈ្មោះកិដា ។

**កិដ្ឋ** នបុំ. [ កស+ថ ] ធម្មជាតដែលកើតអំពីកិ.ភូរ (សំទូង, សំណាប); វិ. **កសិតោ សម្ភូតំ> កិដ្ឋំ** ។ -**ខាទក៏គោណោ** បុំ. គោទំពាស៊ីនូវសំទូង ។ -**សម្ពាធ** គុ. ដីចង្អៀតដោយសំទូង, ដែលតាន់តាប់ដោយសំទូង, -ដោយសំណាប ។

**កិតវ** បុំ. [ កិត+អវ ] មេកឈើ, គ្រឿងបិទបាំង ។

**កិត្តក** គុ. [ កិត្ត+ក ] មានប្រមាណប៉ុន្មាន, ប៉ុន្មាន; វិ. **កិត្តានិ បរិមាណានិ ឯតស្សាតិ> កិត្តកំ** ។

**កិត្តាវតា** និ. ដោយហេតុមានប្រមាណប៉ុន្មាន, ដោយហេតុមានប៉ុន្មាន ។

**កិត្តិ** ឥ. [ កិត+តិ ] វាចាជាគ្រឿងសម្តែង (សេចក្តីសរសើរ, កេរ្តិ៍ឈ្មោះ); វិ. **កិតេតិ ឯតាយាតិ> កិត្តិ** ។ -**វណ្ណភណន**-

Websites: WatKhemaraRatanaram.org or WatKhmers.org

**សង្ខាត** គុ. ពោលគឺកិរិយាពោលនូវគុណគឺបុគ្គលគប្បីពណ៌នា គឺសេចក្ដីសរសើរ, ពោលគឺកិរិយាពោលនូវកេរ្តិ៍ឈ្មោះនិងសេចក្ដីសរសើរ ។

**កិត្តេន្ត** គុ. [ កិត+ណេ+អន្ត ] កាលសម្ដែង ។

**កិន្តិ** និ. [ កឹ+ឥតិ ] ថាអ្វី, ថាដូចម្ដេច ។

**កិបិល្លិក** ពុំ. ស្រមោចក្រហម(ស្រមោចភ្លើង, អង្ក្រង) ។

**កិមង្គំ** និ. [ កឹ+អង្គំ ] នឹងបាច់ពោលទៅថ្វី, ចាំបាច់និយាយទៅថ្វី(ពាក្យមានអ្វីជាហេតុ) ។

**កិមត្ថំ** និ. ដើម្បីអ្វី ។

**កិមត្ថ** ពុំ. [ កឹ+អត្ថ ] ប្រយោជន៍អ្វី, គុ. មានអ្វីជាប្រយោជន៍ ។

**កិមិល** អ.ន. សក្យៈឈ្មោះកិមិលៈ ។

**កិរ** និ. ឮថា, បានឮថា, មានសេចក្ដីតំណាលថា ។

**កិរិយវាទ** ពុំ. [ កិរិយ+វាទ ] អ្នកពោលថាវីកម្មគឺបុគ្គលធ្វើហើយឈ្មោះថាគឺបុគ្គលធ្វើ, អ្នកមានលទ្ធិជាគ្រឿងពោលថា កម្មឈ្មោះថាគឺបុគ្គលធ្វើ ។

**កិរិយា** ឥ. [ ករ+រិយ ] ធម្មជាតិដែលជនគប្បីធ្វើ; វិ. ករតព្វាតិ> **កិរិយា** ។ នពុំ. កិ.ធ្វើ, ដំណើរធ្វើ; វិ. ករយតេតិ> **កិរិយំ** ។

**កិលញ្ជ** ពុំ. [ កិល+ជន+ក្វិ ] កន្ទេល, កន្ទេលផែង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កិលន្ត** គុ.[ កិលម+ត ] លំបាកហើយ, នឿយហត់ហើយ ។ - **កាយ** គុ. មានកាយលំបាកហើយ, មានកាយនឿយហត់ហើយ; វិ. **កិលន្តោ កាយោ យស្ស សោ> កិលន្តកាយោ** ។ - **ភាវ** បុំ. ភាវៈនៃ...ជាអ្នកលំបាកហើយ ។ - **សរីរ** គុ. អ្នកមានសរីរៈហត់នឿយហើយ ។ - **រូប** គុ. មានរូបលំបាកហើយ ។ - **ឥន្ទ្រិយ** គុ. មានឥន្ទ្រិយលំបាកហើយ ។

**កិលមតិ** កិ. [ កិលម+អ+តិ.វិ. ] លំបាក, នឿយ ។

**កិលមថ** បុំ. [ កិលម+ថ ] សេចក្តីលំបាក, សេចក្តីនឿយ; វិ. **កិលមនំ> កិលមថោ** ។

**កិលមន** នបុំ. [ កិលម+យុ ] សេចក្តីលំបាក; វិ. **កិលមិយតេតិ> កិលមនំ** ។ - **កិច្ច** នបុំ. កិច្ចគឺសេចក្តីលំបាក, កិច្ចដោយសេចក្តីលំបាក ។ - **ភាវ** បុំ. ភាវៈនៃសេចក្តីលំបាក, ភាវៈគឺសេចក្តីលំបាក ។

**កិលមន្ត** គុ. [ កិលម+អ+អន្ត ] កាលលំបាក, កាលនឿយហត់ ។

**កិលមន្តិ** កិ. [ កិលម+អ+អន្តិ.វ. ] លំបាក, នឿយហត់ ។

**កិលមិស្សថ** កិ. [ កិលម+អ+ឥ.អា.+ស្សថ.ភ. ] នឹងលំបាក, នឹងនឿយហត់ ។

**កិលមេន្តិ** កិ. [ កិលម+ណេ+អន្តិ.វ. ] ញុំាង...ឱ្យលំបាក, ... ។

**កិលិដ្ឋ** គុ. [ កិលិស+ត ] សៅហ្មងហើយ, កខ្វក់ហើយ, ។ - **កម្ម** នបុំ.

Websites: WatKhemaraRatanaram.org or WatKhmers.org

កម្មដ៏សៅហ្មង, អំពើដ៏សៅហ្មង ។ . ត្ត គុ. មានខ្លួនសៅហ្មងហើយ ។ . តរ គុ. ជាអ្នកសៅហ្មងជាង, ជាអ្នកធ្វើ...ឱ្យសៅហ្មងជាង ។ . និវាសនបារុបន គុ. មានសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្ដប់សៅហ្មងហើយ, មានសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្ដប់ធ្វើឱ្យសៅហ្មងហើយ ។ . វត្ថ នបុំ. សំពត់សៅហ្មងហើយ, សំពត់ធ្វើឱ្យសៅហ្មងហើយ ។

**កិលិន្នបាយាស** បុំ. [ កិលិន្ន+បាយាស ] បាយបាយាសដ៏ជ្រាយ, បាយាសដ៏ជ្រាយ (**កិលិន្ន**<កិលិទ+ត, ត>ន្ន) ។

**កិលិស្សតិ** កិ. [ កិលិស+យ+តិ.វ. ] សៅហ្មង ។

**កិលិស្សេយ្យ** កិ. [ កិលិស+យ+ឯយ្យ.ស. ] គប្បីសៅហ្មង, គប្បីឱ្យសៅហ្មង ។

**កិលេស** បុំ. [ កិលិស+ណ ] ធម៌ជាគ្រឿងសៅហ្មង (កិលេស); វិ. **កិលិស្សន្តិ ឯតេហីតិ> កិលេសា** ។ . **កាម** បុំ. កិលេសកាម, សេចក្ដីប្រាថ្នាដោយអំណាចនៃកិលេស ។ . **ចោរ** បុំ. ចោរគឺកិលេស ។ . **ជយ** បុំ. កិ.ឈ្នះនូវកិលេស ។ . **ទរ** បុំ. សេចក្ដីក្រវល់ក្រវាយគឺកិលេស, សេចក្ដីក្រវល់ក្រវាយដោយអំណាចនៃកិលេស ។ . **ទុគ្គ** គុ. ទីដែលបុគ្គលទៅបានដោយលំបាកគឺកិលេស (ទុគ្គ<ទុ+គម+រ; វិ. **ទុក្ខេន គមិយតេតិ> ទុគ្គំ**) ។ . **និព្វាន** នបុំ. កិលេសនិព្វាន, កិ.រលត់នៃកិលេស ។ . **បរិនិព្វាន** នបុំ. កិលេសបរិនិព្វាន, កិ.រលត់ជុំវិញនៃកិលេស, កិ.រលត់ស្អិទ្ធនៃកិលេស ។ . **ពន្ធ** នបុំ. វត្ថុជាគ្រឿងចងគឺកិលេស, ចំណង

Websites: WatKhemaraRatanaram.org or WatKhmers.org

គឺកិលេស ។ -ពន្ធនាភាវ ចុំ. កិ.មិនមាននៃវត្ថុជាគ្រឿងចងគឺកិលេស, កិ.មិនមាននៃចំណងគឺកិលេស (ពន្ធន+អភាវ) ។ -ភយ ឧចុំ. ភ័យគឺកិលេស, ភ័យកើតអំពីកិលេស ។ -មយ គុ. ដែលកើតអំពី កិលេស ។ -មល ឧចុំ. មន្ទិលគឺកិលេស ។ -មារសង្ខាត គុ. គឺបណ្ឌិតពោលថាមារគឺកិលេស, ពោលគឺមារគឺកិលេស, ពោលថាមារគឺកិលេស ។ -មារ ចុំ. មារគឺកិលេស ។ -រតិ ឥ. សេចក្ដីត្រេកអរក្នុងកិលេស, សេចក្ដីត្រេកអរដោយអំណាចនៃកិលេស ។ -វដ្ដ ឧចុំ. វដ្ដៈគឺកិលេស ។ -វន ឧចុំ. ព្រៃគឺកិលេស, កិលេសដូចជាព្រៃ ។ -វនថ គុ. ដើមឈើតាំងនៅក្នុងព្រៃគឺកិលេស, កិលេសដូចជាឈើតាំងនៅក្នុងព្រៃ ។ -វូប-សមននិព្វានរតិ ឥ. សេចក្ដីត្រេកអរក្នុងព្រះនិព្វានជាទីញ៉ាំងកិលេសឱ្យចូលទៅរម្ងាប់, សេចក្ដីត្រេកអរក្នុងនិព្វានជាទីចូលទៅរម្ងាប់នូវកិលេស ។ -សង្កិលិក គុ. ដែលច្រឡូកច្រឡំដោយកិលេស ។ -អាតុរ គុ. អ្នកក្ដៅក្រហាយព្រោះកិលេស,អ្នកក្រហល់ក្រហាយព្រោះកិលេស, អ្នករសាប់រសល់ព្រោះកិលេស ។ -អាទិមលវិរហិត គុ. ដែលប្រាសហើយចាកមន្ទិលមានកិលេសជាដើម, ដែលវៀរហើយចាកមន្ទិលមានកិលេសជាដើម ។ -ឧបសម ចុំ. ជាទីចូលទៅរម្ងាប់នូវកិលេស, ជាទីញ៉ាំងកិលេសឱ្យចូលទៅរម្ងាប់, ជាទីស្ងប់នៃកិលេស ។

**កិលេសេតិ** ក. [ កិលិស+ណេ+តិ.វ. ] ញ៉ាំង...ឱ្យសៅហ្មង ។

**កិលេសោឃ** ចុំ. [ កិលេស+ឱឃ ] អន្លង់គឺកិលេស, ធម៌ដូចជាអន្លង់គឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

កិលេស, កិលេសដូចជាអន្លង់ ។

**កិស** គុ. [ កិស+អ ] ស្គម ។ - **សរីរតា** ឥ. ភាវៈនៃ....នោះជាអ្នកមានសរីរៈស្គម; វិ. **កិសំ សរីរំ យស្ស សោ> កិសសរីរោ, តស្ស ភាវោ> កិសសរីរតា** ។

**កិសាគោតមី** អ.ន. កុមារិកាឈ្មោះកិសាគោតមី ។ - **វត្ថុ** នថុំ. រឿងនៃកុមារិកាឈ្មោះកិសាគោតមី ។

**កិស្មិញ្ចិ** វិ.ស.អ. [ កឹ+ស្មឹ+ចិ+ចិ ] ក្នុងអ្វីៗ, ក្នុងបន្តិចបន្តួច,... ។

**កី** និ. ឬ, អី., ដូចម្ដេច, ប្រយោជន៍អ្វី ។

**កីអគ្ឃនក** គុ. [ កី+អគ្ឃន+ក ] មានតម្លៃប៉ុន្មាន; វិ. **កឹ អគ្ឃនំ យស្ស សោ> កីអគ្ឃនកោ** ។

**កីការណា** នថុំ. [ កី+ការណ ] ហេតុដូចម្ដេច, ហេតុអ្វី ។

**កីតណិកជាលា** ឥ. [ កីតណិក+ជាល ] បណ្ដាញនៃកណ្ដៀង ។

**កីនានាករណ** គុ. [ កី+នានាករណ ] មានអ្វីជាគ្រឿងធ្វើផ្សេងៗគ្នា, មានអំពើផ្សេងៗគ្នាដូចម្ដេច ។

**កីនាម** និ. ឈ្មោះអ្វី, ឈ្មោះដូចម្ដេច ។

**កីនុខោ** និ. អ្វីហ្ន៎, ដូចម្ដេចហ្ន៎, ព្រោះហេតុអ្វីអេះ ,... ។

**កីសមាចារ** គុ. [ កី+សមាចារ ] អ្នកមានសមាចារៈដូចម្ដេច, អ្នកមានអ្វីជាសមាចារៈ, អ្នកមានមារយាទដូចម្ដេច, អ្នកមានមារយាទជាគ្រឿងប្រព្រឹត្តល្អដូចម្ដេច ។

**កីសីល** គុ. [ កី+សីល ] អ្នកមានសីលដូចម្ដេច, អ្នកមានអ្វីជាសីល; វិ. **កី សីលំ យស្ស សោ> កីសីលោ** ។

**កីជ** បុំ. [ កិជ+ណ ] កណ្ដូប (ដង្កូវ) ។

**កីទិស** គុ. [ កី+ទិស+អ ] ដូចជាអ្វី, ប្រាកដដូចម្ដេច, ប្រាកដយ៉ាងណាទៅ ។

**កីវទូរ** គុ. [ កីវ+ទូរ ] ឆ្ងាយប៉ុន្មាន, ចម្ងាយប៉ុន្មាន, ចម្ងាយប៉ុន្មានទៅ ។

**កីឡតិ** កិ. [ កីឡ+អ+តិ_វ. ] លេង, ប្រល្បែង ។

**កីឡន** នបុំ. [ កីឡ+យុ ] ជាទីលេង, កិ.លេង; វិ. **កីឡន្តិ ឯត្ថាតិ> កីឡនំ, កីឡីយតេតិ> កីឡនំ** ។ - **កាល** បុំ. កាលជាទីលេង ។ - **អត្ថ** បុំ. ប្រយោជន៍ដល់កិ.លេង, ត្រូវការដល់កិ.លេង ។

**កីឡន្តិ** កិ. [ កីឡ+អ+អន្តិ_វ. ] លេង ។

**កីឡន្ត** គុ. [ កីឡ+អន្ត ] កាលលេង, កំពុងលេង ។

**កីឡមាន** គុ. [ កីឡ+មាន ] កាលលេង, កំពុងលេង ។

**កីឡាបយមាន** គុ. [ កីឡ+ណាបយ+មាន ] កាលញុំាង...ឱ្យលេង ។

**កីឡាបេតិ** កិ [ កីឡ+ណាបេ+តិ_វ. ] ញុំាង...ឱ្យលេង ។

**កីឡាមណ្ឌល** នបុំ. [ កីឡា+មណ្ឌល ] មណ្ឌលជាទីលេង, មណ្ឌលនៃកីឡា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កីឡិត** គុ. [ កីឡ+ឥ.អា.+ត ] គឺ...លេងហើយ ។

**កីឡិតព្វ** គុ. [ កីឡ+ឥ.អា+តព្វ ] គឺ...គប្បីលេង ។

**កីឡិតុំ** អ. [ កីឡ+ឥ.អា.+តុំ ] ដើម្បីលេង ។

**កីឡិតុកាម** គុ. [ កីឡិតុំ+កម+ណ ] អ្នកចង់ដើម្បីលេង, អ្នកចង់លេង ។

**កីឡិត្វា** អ. [ កីឡ+ឥ.អា+ត្វា ] លេងហើយ ។

**កីឡិស្សសិ** កិ. [ កីឡ+អ+ស្សសិ-ភ., ចុះឥ-អា. ] នឹងលេង ។

**កីឡីសុ** កិ. [ កីឡ+អ+ឱ-អជ្ជ.] លេងហើយ ។

**កុក្កុច្ច** នបុំ. [ កុកត+ណ្យ ] ភាវៈនៃកម្មដែលបុគ្គលធ្វើហើយគួរខ្ពើម (សេចក្តីក្តៅក្រហាយ, សេចក្តីសង្ស័យ, សេចក្តីរង្កៀស); វិ. **កុកតស្ស ភាវោ> កុក្កុច្ចំ** ។ - **មត្ត** គុ. កម្មត្រឹមតែសេចក្តីសង្ស័យ, ហេតុត្រាន់តែសេចក្តីរង្កៀស ។

**កុក្កុច្ចាយន្ត** គុ. [ កុក្កុច្ច+អាយ+អន្ត ] កាលប្រព្រឹត្តនូវសេចក្តីសង្ស័យ, កាលប្រព្រឹត្តនូវសេចក្តីរង្កៀស (កាលសង្ស័យ, កាលរង្កៀស) ។

**កុក្កុច្ចាយិត្វា** អ. [ កុក្កុច្ច+អាយ+ឥ.អា.+ត្វា ] ប្រព្រឹត្តនូវសេចក្តីសង្ស័យហើយ, ប្រព្រឹត្តនូវសេចក្តីរង្កៀសហើយ (សង្ស័យហើយ, រង្កៀសហើយ) ។

**កុក្កុដ** បុំ. [ កុ+កុដ+អ ] សត្វកាយនូវផែនដី ឬ ក្តាប់នូវដី (មាន់); វិ.

Websites: WatKhemaraRatanaram.org or WatKhmers.org

**កុំ បឋវឹ កុដតីតិ> កុក្កុដោ** ។ ម៉្យាងទៀត (<កុក+អដ) សត្វតែងកាន់យកនូវចំណី; វិ. **កុកតិ គោចរមាទទាតីតិ ទា> កុក្កុដោ** ។ - **អណ្ឌខាទិកា** ឥ. អ្នកទំពាស៊ីនូវពងនៃមាន់; វិ. **កុក្កុដណ្ឌានិ ខាទតីតិ> កុក្កុដណ្ឌខាទិកា** ។ - **អណ្ឌខាទិកវត្ថុ** នបុំ. រឿងនៃកុមារិកាអ្នកទំពាស៊ីនូវពងនៃមាន់ ។ - **មិត្តវត្ថុ** នបុំ. រឿងនៃនេសាទឈ្មោះកុក្កុដមិត្ត ។ - **វតីនគរ** នបុំ. នគរឈ្មោះកុក្កុដវតី ។ - **សត** នបុំ. រយនៃមាន់ ។ - **សេដ្ឋី** បុំ. សេដ្ឋីឈ្មោះកុក្កុដៈ ។ - **អារាម** បុំ. អារាមឈ្មោះកុក្កុដៈ ។

**កុក្កុដី** ឥ. [ កុក្កុដ+ឦ ] មេមាន់ ។

**កុក្កុរ** បុំ. [ កុក+ឧរ ] (សត្វ) ចាប់នូវម្រឹគមានទន្សាយជាដើម (ឆ្កែ); វិ. **កុកតិ សសាទយោ អាទទាតីតិ> កុក្កុរោ** ។

**កុក្កុល** បុំ. [ កុក្កុ+លុ+អ ] (សភាវៈ) កាត់នូវដៃ (ផេះក្តៅ); វិ. **កុក្កុំ ហត្ថំ លុនាតិ ឆិន្ទតីតិ> កុក្កុលោ** ។ - **សទិស** គុ. ប្រាកដស្មើដោយផេះក្តៅ ។

**កុច្ឆិ** ឥ. [ កុស+ឆិ, ស>ច ] ផ្ទៃ, ពោះ; (វិ. **កុសិយតិ អក្កោសិយតីតិ> កុច្ឆិ**) ។ - **គត** គុ. ទៅហើយក្នុងផ្ទៃ (តាំងនៅក្នុងផ្ទៃ) ។ - **ទាហ** បុំ. សេចក្តីក្តៅក្រហាយក្នុងផ្ទៃ, កិ.រោលរាលក្នុងផ្ទៃ ។ - **បូរមត្ត** គុ. អាហារគ្រាន់តែពេញក្នុងផ្ទៃ, អាហារត្រឹមតែកិ.ញ៉ាំងផ្ទៃឱ្យពេញ ។ - **បូរ** គុ. ដែលញ៉ាំងផ្ទៃឱ្យពេញ, កិ. ពេញក្នុងផ្ទៃ ។ - **ប្បមាណ** គុ. ប្រមាណនៃផ្ទៃ ។ - **រោគ** បុំ.

Websites: WatKhemaraRatanaram.org or WatKhmers.org

រោគក្នុងផ្ទៃ, រោគកើតក្នុងផ្ទៃ ។

**កុជ្ឈតិ** កិ. [ កុធ+យ+តិ_វ. ] ក្រោធ, ខឹង ។

**កុជ្ឈន្ត** គុ. [ កុធ+យ+អន្ត ] កាលក្រោធ, កាលខឹង ។

**កុជ្ឈាបន** នបុំ. [ កុធ+យ+ណាបេ+យុ ] កិ.ញ៉ាំង...ឱ្យក្រោធ, -ខឹង ។

- **វំស** បុំ. អំណាចនៃកិ.ញ៉ាំង...ឱ្យក្រោធ ។

**កុជ្ឈាបេន្ត** គុ. [ កុធ+យ+ណាបេ+អន្ត ] កាលញ៉ាំង...ឱ្យក្រោធ ។

**កុជ្ឈាបេហិ** កិ. [ កុធ+យ+ណាបេ+ហិ_ប. ] ចូរញ៉ាំង...ឱ្យក្រោធ ។

**កុជ្ឈាមិ** កិ. [ កុធ+យ+មិ_វ. ] ក្រោធ ។

**កុជ្ឈាយថ** កិ. [ កុធ+យ+ណាយ+ថ_វ. ] ក្រោធ, ឱ្យក្រោធ ។

**កុជ្ឈិតព្វ** គុ. [ កុធ+យ+ឥ_អា.+តព្វ ] គឺ...គប្បីក្រោធ ។

**កុជ្ឈិត្វា** អ. [ កុធ+យ+ឥ_អា.+ត្វា ] ក្រោធហើយ, ខឹងហើយ ។

**កុជ្ឈិស្សតិ** កិ. [ កុធ+យ+ឥ_អា.+ស្សតិ_ភ. ] នឹងក្រោធ ។

**កុជ្ឈេយ្យ** កិ. [ កុធ+យ+ឯយ្យ_ស. ] គប្បីក្រោធ ។

**កុញ្ចិកច្ឆិទ្ទ** នបុំ. [ កុញ្ចិក+ឆិទ្ទ ] ប្រហោងនៃសោ ។

**កុញ្ចិកហត្ថ** គុ. [ កុញ្ចិក+ហត្ថ ] អ្នកមានសោក្នុងដៃ; វិ. **កុញ្ចិកំ ហត្ថេ យស្ស សោ> កុញ្ចិកហត្ថោ** ។

**កុញ្ជរ** បុំ. [ កុំ+ជរ+អ ] (សត្វ) ញ៉ាំងផែនដីឱ្យត្រាំត្រា (ដំរី); វិ. **កុំ ប-ឋវឹ ជរាបេតីតិ> កុញ្ជរោ** ។ - **សង្ខាត** គុ. ពោលគឺដំរី, គឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

បណ្ឌិតពោលថាកុញ្ជរ ។ - សាលា ឥ. កុញ្ជរសាលា, រោងនៃដំរី (សាលាមានសណ្ឋានដូចជាសណ្ឋាននៃដំរី) ។

**កុដ** ចុំ. នចុំ. ក្អម, ឆ្នាំង, បាវ (បាវគឺប្រដាប់ដែលគេរំលាយមាស) ។

**កុដជ** ចុំ. [ កុដ+ជ ] (ឈើ) កាត់បង់នូវរោគ (ដើមក្លែងគង់); វិ. **រោគំ កុដតិ ឆិន្ទតីតិ> កុដជោ** ។

**កុដមុខវដ្ដិ** ឥ. [ កុដ+មុខ+វដ្ដិ ] កណ្ដាប់ដៃមាត់នៃក្អម ។

**កុដិកណ្ណ** គុ. [ កុដិ+កណ្ណ ] មានត្រចៀកពាក់នូវគ្រឿងប្រដាប់មានតម្លៃមួយកោដិ(១) (តាមទម្លាប់ថា «មានត្រចៀកយារ») ។ **- សោណត្ថេរ** ចុំ. ព្រះថេរឈ្មោះសោណៈមានត្រចៀក... ។

**កុដិក** នចុំ. [ កុដិ+ក ] កុដិតូច, ខ្ទមតូច ។

**កុដិ** ឥ. [ កុដ+ឥ ] កុដិ (ផ្ទះ) ។ **- ទូសកភិក្ខុ** ចុំ. ភិក្ខុអ្នកប្រទូស្ដនូវកុដិ ។

**កុដុម្ព** នចុំ. ទ្រព្យ, សម្បត្តិ ។

**កុដុម្ពិក** ចុំ. [ កុដុម្ព+ណិក ] (ជន) អ្នកមានទ្រព្យ, អ្នកមានសម្បត្តិ; វិ. **កុដុម្ពំ យស្ស អត្ថីតិ> កុដុម្ពិកោ** ។ **- បុត្ត** ចុំ. កូននៃជនអ្នកមានទ្រព្យ, កូននៃជនអ្នកមានសម្បត្តិ, កូននៃកុដុម្ពិកៈ ។

**កុដ្ឋិ** ចុំ. [ កុដ្ឋ+ឦ, ឦ>ឥ ] អ្នកមានរោគឃ្លង់; វិ. **កុដ្ឋំ យស្ស អត្ថីតិ> កុដ្ឋិ** ។ **- ភាវប្បត្តិ** ឥ. កិ.ដល់នូវភាវៈនៃ...ជាអ្នកមានរោគឃ្លង់ ។ **- ភាវ** ចុំ. ភាវៈនៃ....ជាអ្នកមានរោគឃ្លង់ ។

---

១ - មើល «កោដិកណ្ណ» ផង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កុណប** នថុំ. សព, សាកសព ។ - **គន្ធប្បដិកុលតា** ឥ. ភាវៈនៃ... ជា...បដិកូលដោយក្លិននៃសាកសព, ភាវៈនៃ...ជា...មានក្លិននៃ សាកសពជាបដិកូល ។

**កុណី** គុ. [ កុណ+ឦ ] អ្នកមានអវយវៈជាគ្រឿងខ្វះឬរួញ (ក្ញែង); វិ. **កុណោ យស្ស អត្ថិតិ> កុណី** ។

**កុណ្ឋ** គុ. [ កុណ្ឋ+អ ] ខ្ចក, ហិល, រិល វេច ។ - **កុទ្ទាល** ថុំ. ចបរិល, ចបគំរិល ។ - **ធារ** គុ. មានមុខរិល, មានមុខហិល ។ - **បាទ-ច្ឆិន្នជវ** គុ. មានជើងខ្ចក និងមានសន្ទុះដាច់ហើយ, មានសន្ទុះដាច់ហើយ ដោយអំណាចនៃជើងខ្ចក, មានសន្ទុះដាច់ហើយ ព្រោះមាន ជើងខ្ចក ។

**កុណ្ឌក** ថុំ. [ កុណ្ឌ+អ+ក_ស. ] (ផង់នៃអង្ករ, កំទេចនៃអង្ករ) កន្ទក់ ។ - **អង្គារបូវ** ថុំ. នំគឺបុគ្គលចំអិនលើរងើកភ្លើង ដែល ទាសីឈ្មោះបុណ្ណាធ្វើហើយដោយកន្ទក់, នំអំបែង គឺទាសីឈ្មោះ បុណ្ណាធ្វើហើយដោយកន្ទក់ ។ - **មុដ្ឋិ** ឥ. ក្តាប់នៃកន្ទក់, កន្ទក់ មានក្តាប់ជាប្រមាណ ។ - **សិន្ធវបោតកជាតក** នថុំ. ជាតកគឺ បណ្ឌិតកំណត់ហើយដោយគុណនៃសេះសិន្ធវៈស៊ីនូវកន្ទក់ ។ - **អាទិ** គុ. (វត្ថុ) មានកន្ទក់ជាដើម ។

**កុណ្ឌលកេសី** អ.ន. ព្រះថេរីឈ្មោះកុណ្ឌលកេសី ។ - **ថេរីវត្ថុ** នថុំ. រឿងនៃព្រះថេរីឈ្មោះកុណ្ឌលកេសី ។

**កុណ្ឌល** នថុំ. [ កុណ្ឌ+អល ] កុណ្ឌល (គ្រឿងប្រដាប់ត្រចៀក,

Websites: WatKhemaraRatanaram.org or WatKhmers.org

ទំហូ) ។

**កុណ្ឌិកា** ឥ. [ កុឌិ+ក.ស.+អា.ឥ. ] កុណ្ឌី (ប្រដាប់សម្រាប់ដាក់ទឹកជ្រូច) ។

**កុណ្ឌិធានវ័ន** អ.ន. វិហារឈ្មោះកុណ្ឌិធានវ័ន ។

**កុតូហលជាត** គុ. [ កុតូហល+ជាត ] ជាអ្នកមានសេចក្ដីជ្រួលជ្រើមកើតហើយ, ជាអ្នកមានការរីករាយកើតហើយ (កុតូហល័<កុ+តុល+អ, ចុះ ហ.អា.; វិ. **កុំ បាឋំ តុលយតីតិ**> **កុតូហលំ**) ។

**កុទាចនំ** កា.ស. [ កឹ+ទាចនំ, កឹ>កុ ] ក្នុងកាលណាៗ, ក្នុងកាលណាខ្លះ, ជួនកាល, ជួនណា,...។

**កុទ្ទាល** ចុំ. [ កុំ+ទល+ណ ] គ្រឿងទំលាយនូវផែនដី (ចប); វិ. **កុំ ទាលេតិ ឆលតីតិ**> **កុទ្ទាលោ** ។ - **អត្ថ** ចុំ. ប្រយោជន៍ដល់ចប, សេចក្ដីត្រូវការដល់ចប ។ - **បណ្ឌិត** អ.ន. ឈ្មោះកុទ្ទាលបណ្ឌិត ។ - **តល** នចុំ. ផ្ទៃនៃចប ។ - **អាទិហត្ថ** គុ. មានវត្ថុមានចបជាដើមក្នុងដៃ ។

**កុទ្ធ** គុ. [ កុធ+ត ] ក្រោធហើយ, ខឹងហើយ ។ - **បុព្វ** គុ. ធ្លាប់ក្រោធហើយ (ខឹងហើយក្នុងកាលមុន) ។ - **មនុស្ស** ចុំ. មនុស្សក្រោធហើយ ។ - **មានស** គុ. មានចិត្តក្រោធហើយ, មានឆន្ទះមានក្នុងចិត្តក្រោធហើយ ។

**កុធារី** ឥ. [ កុ+ធរ+ណី ] ដីង, ប៉ូវថៅ (ប្រើជា **កុឋារី** ក៏មាន) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# កុ

**កុបិត** គុ. [ កុប+ឥ.អា.+ត ] កំរើកហើយ, គឺ...ឱ្យកំរើកហើយ (ក្រោធ, ខឹង) ។ ‑ **ភាវ** ចុំ. ភាវៈនៃ...ជា...កំរើកហើយ ។ ‑ **មានស** គុ. អ្នកមានចិត្តកំរើកហើយ, អ្នកមានផ្នត់គំនិតមានក្នុងចិត្ត កំរើកហើយ ។

**កុប្បតិ** កិ. [ កុប+យ+តិ.វ. ] កំរើក (ក្រោធ, ខឹង) ។

**កុប្បន្តិ** កិ. [ កុប+យ+អន្តិ.វ. ] កំរើក, កក្រើក ។

**កុប្បិស្សុ** កិ. [ កុប+យ+ឥំ.អជ្ជ. ] កំរើកហើយ ។

**កុព្វន្តិ** កិ. [ ករ+ឱ+អន្តិ.វ. ] ធ្វើ, រមែងធ្វើ ។

**កុព្វតោ** គុ. [ ករ+ឱ+អន្ត+ស.ឆិ. ] កាលធ្វើ(នៃ...កាលធ្វើ) ។

**កុមារ** ចុំ. [ កុ+មរ+ណ, កុម+អារ, កុមារ+អ ] អ្នកគួរសារវ៉ាសនូវផែនដី, (មារក) ដែលគេប្រាថ្នា, អ្នកតែងលេង (កុមារ, ក្មេង); **កុំ ភូមឹ មរតិ ភិន្ទតិ ចិលេខតីតិ> កុមារោ, កាមិយតីតិ> កុមារោ, កុមារតិ កីឡតីតិ> កុមារោ** ។ ‑ **កស្សបត្ថេរវត្ថុ** នចុំ. រឿងនៃព្រះថេរៈឈ្មោះកុមារកស្សប ។ ‑ **បរិវារ** ចុំ. បរិវារនៃកុមារ, កុមារជាបរិវារ ។ ‑ **បរិហារ** នចុំ. វត្ថុជាគ្រឿង នាំទៅជុំវិញនៃកុមារ, វត្ថុជាគ្រឿងរក្សានូវកុមារ ។ ‑ **វណ្ណ** គុ. មានភេទដូចជាភេទនៃកុមារ ។

**កុមារក** ចុំ. ដូចជា «កុមារ» ដែរ ប្លែកតែចុះ «កសកត្ត» ខាងចុង ប្រែថា «កុមារ,ក្មេង ឬកុមារតូច, ក្មេងតូច» ។ ‑ **វណ្ណ** ចុំ. ភេទដូចជាភេទនៃកុមារ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កុមារិកា** ឥ. កុមារិកា, ក្មេងស្រី ឬ កុមារីតូច, ក្មេងស្រីតូច ។ - **កាល** ចុំ. កាលនៃ...ជាកុមារិកា ។ - **វណ្ណាទិវស** ចុំ. អំណាចនៃភេទមានភេទនៃកុមារិកាជាដើម ។

**កុមារីសុត** នចុំ. [ កុមារិ+សុត ] របស់នៃកុមារី ។

**កុមុទ** នចុំ. [ កុ+មុទ+ណ ] (ជលជាត) ត្រកអរក្នុងទឹក ឬត្រកអរក្នុងផែនដី (កុមុទ, ផ្កាកុមុទ); វិ **កុយំ មុទតិយំ មោទតីតិ> កុមុទំ** ។ - **ឧប្បល** នចុំ. ផ្កាកុមុទនិងផ្កាឧប្បល ។

**កុម្ភការ** ចុំ. [ កុម្ភ+ករ+ណ ] (ជន) អ្នកធ្វើនូវឆ្នាំង ឬ ក្អម (ស្មូនឆ្នាំង); វិ. **កុម្ភំ ករោតីតិ> កុម្ភការោ** ។ - **សាលា** ឥ. សាលា (រោង) នៃជនអ្នកធ្វើនូវឆ្នាំង, រោងនៃស្មូនឆ្នាំង ។

**កុម្ភឃោសក** អ.ន. សេដ្ឋីឈ្មោះកុម្ភឃោសកៈ ។ - **វត្ថុ** នចុំ. រឿងនៃ... ។

**កុម្ភទាសី** ឥ. [ កុម្ភ+ទាសី ] ទាសីអ្នកនាំទៅនូវទឹកដោយក្អម (កុម្ភ-ទាសី) ។

**កុម្ភភារ** ចុំ. [ កុម្ភ+ភារ ] ភារៈមានកុម្ភៈជាប្រមាណ, ទ្រព្យមានទម្ងន់មួយកុម្ភៈ ។

**កុម្ភិមុខ** នចុំ. [ កុម្ភិ+មុខ ] មាត់នៃឆ្នាំង, មាត់នៃក្អម ។

**កុម្ភីល** ចុំ. [ ក+ឧភ+ឦល, ឧល+អ ] ក្រពើ; វិ. **កេន ជលេន ឧភតិ បូរេតីតិ> កុម្ភោ (ជលាសយោ), កុម្ភេ ឧលតិ គច្ឆតីតិ> កុម្ភីលោ** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កុម្ភូបម** គុ. [ កុម្ភ+ឧបមា ] មានឧបមាដោយក្អម, មានក្អមជាគ្រឿងប្រៀបធៀប ។

**កម្មាសបូវ** ចុំ. [ កម្មាស+ចូវ ] នំគឺបុគ្គលធ្វើហើយដោយសណ្តែក, នំសណ្តែក, នំកម្មាស, (ជាឈ្មោះនំមួយប្រភេទដែលគេប្រើក្នុងប្រទេសឥណ្ឌា) ។

**កុររឃរ** អ.ន. ក្រុងឈ្មោះកុររឃរៈ ។ . **នគរ** នចុំ. នគរឈ្មោះកុររឃរៈ ។

**កុរ** នចុំ. [ ករ+អ ] (វត្ថុ) ធ្វើនូវកម្លាំង (បាយ); វិ. **ករោតិ ពលន្តិ> កុរំ** ។

**កុរុង្គ** ចុំ. [ កុ+រគ+អ, ចុះនិ.អា. ] (សត្វ) ដើរទៅលើដី (ប្រើស ឬម្រឹគឈ្មោះកុរុង្គៈ); វិ. **កុយំ រង្គតីតិ> កុរុង្គោ** ។ . ជាតកាទិ គុ. (ជាតក) មានកុរុង្គជាតកជាដើម ។ ប្រើជា **កុរង្គ** ក៏មាន ។

**កុរុតេ** កិ. [ ករ+ឱ+តេ.វ.. ] ធ្វើ ។

**កុរុធម្ម** ចុំ. [ កុរុ+ធម្ម ] កុរុធម៌, ធម៌នៃអ្នកដែនកុរុ ។

**កុរុរដ្ឋ** នចុំ. [ កុរុ+រដ្ឋ ] ដែនឈ្មោះកុរុ ។ . **វាសី** ចុំ. ជនអ្នកនៅក្នុងដែនកុរុ, អ្នកមានកិ.នៅក្នុងដែនកុរុជាប្រក្រតី ។

**កុរុមាន** គុ. [ ករ+ឧ+មាន ] កាលធ្វើ ។

**កុរុរាជ** ចុំ. [ កុរុ+រាជ ] ស្តេចក្នុងដែនកុរុ, ស្តេចជាធំក្នុងដែនកុរុ ។

**កុលប** នចុំ. [ កុល+អ ] (វង្ស) ជាហេតុតភ្ជាប់នូវគ្នានឹងគ្នា (ត្រកូល); វិ. **កុលតិ អញ្ញមញ្ញមេតេនាតិ> កុលំ** ។ . **កុមារិកា** ឥ.

Websites: WatKhemaraRatanaram.org or WatKhmers.org

កុមារិកានៃត្រកូល, ក្មេងស្រីនៃត្រកូល ។ - គ្គាម ចុំ. ស្រុកនៃត្រកូល ។ - គេហ នចុំ. ផ្ទះនៃត្រកូល ។ - ឃរគមន នចុំ. កិ. ទៅកាន់ផ្ទះនៃត្រកូល ។ - ឃរគមនភារ ចុំ. ភារៈគឺកិ.ទៅកាន់ផ្ទះនៃត្រកូល, ភារៈនៃកិ.ទៅកាន់ផ្ទះនៃត្រកូល ។ - ទត្តិយ គុ. ដែលត្រកូលឱ្យហើយ ឬ ជារបស់ដែលត្រកូលគប្បីឱ្យ ។ - ទមក គុ. អ្នកទូន្មាននូវត្រកូល ។ - ទូសកកម្ម នចុំ. កម្មនៃបុគ្គលអ្នកប្រទូស្តនូវត្រកូល ។ - ធីតា ឥ. ធីតានៃត្រកូល, កូនស្រីនៃត្រកូល ។ - បវេណិ ឥ. លំដាប់នៃត្រកូល ។ - បរិវដ្ដ ចុំ. កិ.វិលទៅជុំវិញនៃត្រកូល, ផ្លូវនៃត្រកូល ។ - បុត្ត ចុំ. កុលបុត្រ, កូនរបស់ត្រកូល ។ - វំស ចុំ. វង្សនៃត្រកូល ។ - វំសានុគត គុ. ទៅតាមហើយនូវវង្សនៃត្រកូល, ប្រព្រឹត្តទៅតាមហើយនូវវង្សនៃត្រកូល ។ - ភាតា ចុំ. បងប្អូនប្រុសនៃត្រកូល ។ - សតិក គុ. មានវយនៃត្រកូល, ប្រកបដោយវយនៃត្រកូល; វិ. **កុលានំ សតំ> កុលសតំ, កុលសតំ យេសមត្ថីតិ> កុលសតិកា, កុលសតេន និយុត្តា> កុលសតិកា** ។ - សន្តក គុ. ជារបស់នៃត្រកូល ។ - សម្ពន្ធវំស ចុំ. អំណាចនៃកិ.ជាប់ព្រមដោយ ត្រកូល, អំណាចនៃកិ.ទាក់ទងដោយត្រកូល ។

**កុលាល** ចុំ. [ កុ+លល+ណ ] អ្នកប្រាថ្នានូវដី ឬ អ្នកក្រាលនូវសិល្បៈរបស់ខ្លួន, អ្នកកាន់យកនូវដីធ្វើ (ស្មូនឆ្នាំង); វិ. **កុំ លលយតីតិ> កុលាលោ, កុលតិ អត្តនោ សិប្បំ បត្ថរតីតិ> កុលាលោ** ។ - ចក្ក នចុំ. ចក្រនៃស្មូនឆ្នាំង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

-ភាជនសទិស គុ. ប្រាកដស្មើដោយភាជន៍នៃស្មូនឆ្នាំង, ប្រហែលដោយភាជន៍នៃបុគ្គលអ្នកកាន់យកនូវដីធ្វើ ។

**កុលាវក** នបុំ. [ កុ+លុ+ណ្វុ ] សម្បុក (វិ. **កុច្ឆិតមណ្ឌិតានាសនាធិកំ លុនាតីតិ> កុលាវកំ**) ។

**កុលុបគ** គុ. [ កុល+ឧប+គម+ក្វិ ] អ្នកចូលទៅកាន់ត្រកូល; វិ. **កុលំ ឧបគច្ឆតីតិ> កុលុបគោ** ។ -**ត្ថេរ** ពុំ. ព្រះថេរៈអ្នកចូលទៅកាន់ត្រកូល, ព្រះថេរៈជាជីតុន ។

**កុលុបច្ឆេទ** ពុំ. [ កុល+ឧប+ឆិទ+ណ ] កិ.ចូលទៅកាត់បង់នូវត្រកូល, ការចូលទៅផ្តាច់បង់នូវត្រកូល; វិ. **កុលំ ឧបច្ឆិទយតេតិ> កុលុបច្ឆេទនំ, កុលុបច្ឆេទនំ> កុលុបច្ឆេទោ** ។

**កុសគ្គ** គុ. [ កុស+អគ្គ ] ចុងនៃស្មៅ (ដែលធ្លាប់ប្រែថា ចុងនៃស្បូវ) ។

**កុសរាជសន្តក** គុ. [ កុសរាជ+សន្តក ] ជារបស់នៃស្តេចឈ្មោះកុសៈ ។

**កុសល** នបុំ. [ កុស+អល ] (គុណជាត) គួរក្នុងកិផ្តាច់បង់នូវបាប (កុសល; គុ. ឈ្លាស, ប៉ិន, ប្រសប់, វាងវៃ); វិ. **កុសេ បាបច្ឆេទនេ អលន្តិ> កុសលំ** ។ (គុណជាត) ផ្តាច់នូវធម៌ដ៏អាក្រក់គឺធម៌ជាអកុសល; វិ. **កុសតិ បាបកេ អកុសលេ ធម្មេ ឆិន្ទតីតិ> កុសលំ** ។ ម្យ៉ាងទៀត (កុស+លុ+អ) គុណជាតកាត់នូវកិលេសមានរាគៈជាដើមដេកនៅក្នុងសន្តានដោយអាការៈដែលបណ្ឌិតគួរខ្ពើម; វិ. **កុច្ឆិតេនាការេន សន្តានេ សេន្តីតិ> កុសា, រាគាទយោ តេ លុនាតិ ឆិន្ទតីតិ>**

Websites: WatKhemaraRatanaram.org or WatKhmers.org

**កុសលំ** ។ -**កម្មករណ** នបុំ. កិ.ធ្វើនូវកម្មជាកុសល ។ -**កម្មករណកាល** បុំ. កាលនៃកិ.ធ្វើនូវកម្មជាកុសល, កាលជាទីធ្វើនូវកម្មជាកុសល ។ -**កម្មប្បត្តិដ្ឋាករណ** នបុំ. កាលជាទីធ្វើនូវទីជាទីពឹងគឺកម្មជាកុសល, កាលជាទីធ្វើនូវគុណជាតិជាទីពឹងគឺកម្មជាកុសល ។ -**កម្មបថ** បុំ. គន្លងគឺកម្មជាកុសល ។ -**កោដ្ឋាស** បុំ. ចំណែកនៃធម៌ជាកុសល, ចំណែកនៃកម្មជាកុសល ។

-**តា** ឥ. ភាវៈនៃ...នោះជាអ្នកឆ្លាត, -ឈ្លាស, -ប្រសប់ ។ -**ត្ត** នបុំ. ភាវៈនៃ...នោះជាអ្នកឈ្លាស ។ -**បាថេយ្យ** នបុំ. វត្ថុជាប្រយោជន៍ក្នុងផ្លូវជាកុសល ឬ វត្ថុជាប្រយោជន៍ដល់ផ្លូវគឺកុសល, ស្បៀងគឺកុសល; វិ. **បថេ បថស្ស វា ហិតំ> បាថេយ្យំ** ។ <បថ+ណេយ្យ ។ -**វិថិ** ឥ. វិថីនៃចិត្តជាកុសល ។

**កុសលាកុសល** នបុំ. [ កុសល+អកុសល ] កុសលនិងអកុសល ។ -**កម្មករណ** នបុំ. ជាទីធ្វើនូវកម្មជាកុសលនិងកម្មជាអកុសល ។ -**កម្មវីជ** នបុំ. ពូជគឺកម្មជាកុសលនិងអកុសល ។

**កុសលាភិនិព្វត្ត** គុ. [ កុសល+អភិនិព្វត្ត ] ដែលកើតចំពោះហើយអំពីកម្មជាកុសល, គឺកម្មជាកុសលឱ្យកើតចំពោះហើយ ។

**កុសលូបទេស** បុំ. [ កុសល+ឧបទេស ] ឧបទេសនៃបុគ្គលអ្នកឈ្លាស, ឧបាយជាគ្រឿងណែនាំនៃបុគ្គលអ្នកឈ្លាស, ឧបាយជាគ្រឿងចូលទៅសម្តែងនៃបុគ្គលអ្នកប្រសប់ ។ <ឧប+ទិស+ណ ។

**កុសិនារា** អ.ន. ក្រុងឈ្មោះកុសិនារា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កុសីត** គុ. [ កុ+សទ, សទ>សីទ, ទ>ត+អ ] អ្នកលិចចុះ ដោយអាការគឺ បណ្ឌិតគប្បីខ្ពើម, ម៉្យាងទៀត អ្នកលេចចុះ ក្នុងកិលេសគឺបណ្ឌិតគប្បីខ្ពើម (អ្នកខ្ជិល); វិ. **កុច្ឆិតេនាការេន សីទតីតិ> កុសីតោ, កុច្ឆិតេ កិលេសេ សីទតីតិ> កុសីតោ** ។ **- បុគ្គល** ចុំ. បុគ្គលអ្នកខ្ជិល ។ **- មាណព** ចុំ. មាណពអ្នកខ្ជិល, មាណពអ្នកខ្ជិលច្រអូស ។

**កុសុម** នចុំ. [ កុស+ឧម ] ផ្កា, ផ្កាឈើ ។

**កុសុម្ភរត្ត** គុ. [ កុសុម្ភ+រត្ត ] ដែលបុគ្គលជ្រលក់ហើយដោយផ្កាដកគាំ ។

**កុហក** ចុំ. [ កុហ+ណ្វុ ] អ្នកកុហក, អ្នកបំភាន់, អ្នកបញ្ឆោត, អ្នកលលួង, អ្នកបោកប្រាស, អ្នកញុំាងគេឱ្យភាន់ភាំង; វិ. **កុហយតីតិ> កុហកោ** ។ **- ចោរ** ចុំ. ចោរអ្នកកុហក ។ **- តាបស** ចុំ. តាបសអ្នកកុហក, តាបសអ្នកញុំាងលោកឱ្យភាន់ភាំង ។ **- ព្រាហ្មណវត្ថុ** នចុំ. រឿងនៃព្រាហ្មណ៍អ្នកកុហក ។

**កុហឹ** អ.ន. [ កឹ+ហឹ, កឹ>កុ ] ក្នុងទីណា, ត្រង់ទីណា ។

**កូដ** [ កុ+អដ+អ, កុដ+ណ ] ធម្មជាតប្រព្រឹត្តទៅដោយអាការគឺបណ្ឌិតគួរខ្ពើម (គុ. កោង, កាច, បៀតបៀន, ដំ, ក្ដៅក្រហាយ, ន.កំពូល, ញញួរ); វិ. **កុច្ឆិតេនាការេន អដតីតិ> កូដំ** ។ **- ជដិល** ចុំ. ជដិលកោង, ជដិលកោងកាច ។ **- ផ្គុដ្ឋកូណ** នចុំ. កិ.ធ្វើនូវក្ដីកោង ។ **- ដ្ឋបរាជិត** គុ. អ្នកមានក្ដីកោង

Websites: WatKhemaraRatanaram.org or WatKhmers.org

ចាញ់ហើយ, អ្នកចាញ់ហើយដោយក្តីកោង ។ - សក្ខិ បុំ. សាក្សីកោង, បន្ទាល់កោង ។ - សហស្ស នបុំ. ពាន់នៃកំពូល, ពាន់នៃញញួរ ។

**កូដាគារ** នបុំ. [ កុដ+អគារ ] ផ្ទះប្រកបដោយកំពូល; វិ. **កូដេន យុត្តំ អគារំ> កូដាគារំ** ។ ផ្ទះ គឺបុគ្គលសង្គ្រោះហើយដោយកំពូល; វិ. **កូដេន សង្គហិតំ អគារំ> កូដាគារំ**, (ផ្ទះមានកំពូល, ភ្នំយោង) ។ - **កណ្ណិកា** ឥ. បោជាងនៃផ្ទះមានកំពូល ។ - **កុច្ឆិប្បមាណ** គុ. មានផ្ទៃនៃផ្ទះមានកំពូលជាប្រមាណ, មានប្រមាណប៉ុនផ្ទៃនៃផ្ទះមានកំពូល ។ - **មត្ត** គុ. មានផ្ទះគឺបុគ្គលសង្គ្រោះហើយដោយកំពូលជាប្រមាណ, ប៉ុនផ្ទះមានកំពូល ។ - **សត** នបុំ. រយនៃផ្ទះគឺបុគ្គលសង្គ្រោះហើយដោយកំពូល, រយនៃផ្ទះមានកំពូល ។ - **សាលា** ឥ. សាលា (រោង) គឺផ្ទះដែលបុគ្គលសង្គ្រោះហើយដោយកំពូល ។

**កូល** នបុំ. [ កុល+ណ ] (វត្ថុ) បិទរាំងនូវទឹកមិនឱ្យហូរចេញទៅខាងក្រៅ (ច្រាំង, ធ្នេរ); វិ. **កូលតិ អាវរតិ ឧទកំ ពហិ និក្ខមិតុំ ន ទេតីតិ> កូលំ** ។

**កេចិ** វិ.ស.អ. [ កឹ+ចិ ] ពួកមួយ, ពួកខ្លះ, អ្នកខ្លះ, នីមួយ ។

**កេទារ** នបុំ. [ ក្លេទឬក្លិទ+អ, លុបល ] ស្រែ (វិ. **ក្លេទីយតីតិ> កេទារំ**) ។ - **ន្តរ** នបុំ. ចន្លោះនៃស្រែ ។ - **បរិយាទា** ឥ. ភ្លឺស្រែ, ភ្លឺនៃស្រែ ។

**កេរាដិកបក្ខភជន** នបុំ. [ កេរាដិក+បក្ខ+ភជន ] កិ.គប់រកនូវពួកនៃជន

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកអែបអប, កិ.គប់រកនូវពួកនៃជនដែលធាក់បណ្ដោយ, ការគប់រកនូវពួកនៃជនអ្នកអួតអាង ។

**កេលាស** នថុំ. ភ្នំឈ្មោះកេលាស ឬភ្នំឈ្មោះកៃលាស ។ - **កូដប្បដិភាគ** គុ. មានចំណែកប្រៀបដោយកំពូលនៃភ្នំឈ្មោះកៃលាស ។

**កេឡិ** ឥ. [ កិឡ+ឥ ] កិ.លេង, កិ.ឡកឡឺយ, កិ.ចំអក, កិ.ចំអកចំអន់ (ប្រើជា «កេលិ» ក៏មាន) ។

**កេវដ្ដ** ចុំ. [ កេ+វដ្ដ+ណ ] ជនអ្នកវិលទៅក្នុងទឹកដើម្បីប្រយោជន៍ដល់កិ.ចាប់នូវត្រី ឬ ជនអ្នកញ៉ាំងទឹកឱ្យវិល (ព្រានប្រម៉ង់, ព្រានសន្ទូច); វិ. **កេ ឧទកេ មច្ឆគហណត្ថាយ វដ្ដតីតិ> កេវដ្ដោ, កំ ឧទកំ វដ្ដតីតិ> កេវដ្ដោ** ។ - **គាមវាសី** ចុំ. ជនអ្នកនៅក្នុងស្រុកនៃព្រានប្រម៉ង់, ជនអ្នកមានកិ.នៅក្នុងស្រុកនៃព្រានប្រម៉ង់ជាប្រក្រតី; វិ. **កេវដ្ដគាមេ វសតីតិ> កេវដ្ដគាមវាសី, កេវដ្ដគាមេ វសិតុំ សីលមស្សាតិ> កេវដ្ដគាមវាសី** ។ - **គាម** ចុំ. ស្រុកនៃព្រានប្រម៉ង់ ។ - **ជេដ្ឋកបុត្ត** ចុំ. កូននៃព្រានប្រម៉ង់ជាច្បង, កូនច្បងនៃព្រានប្រម៉ង់ ។

**កេវល** គុ. [ កេវ+អល ] ទាំងអស់, ទាំងស្រុង, តែម្យ៉ាង, មិនមានសេសសល់, សុទ្ធ (វិ. **កេវនំ វត្តនំ> កេវលំ**) ។

**កេវលី** គុ. [ កេវល+ឦ ] មានកំពូលដ៏សុទ្ធ ។

**កេស** ចុំ. [ កេ+សី+អ ] សភាវៈដេកតីប្រព្រឹត្តទៅឰដ៏ក្បាល (សក់);

Websites: WatKhemaraRatanaram.org or WatKhmers.org

វិ. កេ សិរស្មិំ សយន្តិ ឋបេន្តីតិ> កេសា ។ ម្យ៉ាងទៀតសភាវៈស្ថិតនៅលើក្បាល; វិ. កេ មត្ថកេ សេន្តិ តិដ្ឋន្តីតិ> កេសា ។ - កល្យាណ នចុំ. លំអពីសក់, លំអនៃសក់ ។ - កលាប ចុំ. បាច់នៃសក់, សំណុំនៃសក់ ។ - អគ្គមត្ត គុ. មានចុងនៃសក់ជាប្រមាណ, ប៉ុនចុងនៃសក់។ - មស្សុ នចុំ. សក់និងពុកមាត់ ។ - លុញ្ចន នចុំ. កិ.ដកនូវសក់ ។ - អាទិសមុហ-សង្ខាត គុ. ពោលគឺប្រជុំនៃអាការមានសក់ជាដើម, គឺបណ្ឌិតរាប់ព្រមហើយថាប្រជុំនៃកោដ្ឋាសៈមានសក់ជាដើម ។

**កេសវ** អ.ន. ឈ្មោះកេសវៈ ។ - តាបស ចុំ. តាបសឈ្មោះកេសវៈ ។

**កេសិ** អ.ន. តាបសឈ្មោះកេសី, តាបសឈ្មោះកេសវៈ ។

**កេសោរោបន** នចុំ. [ កេស+អវ+រុប+យុ ] កិ.ដាក់ចុះនូវសក់, កិ.កោរនូវសក់ ។ - អត្ថ ចុំ. ប្រយោជន៍ដល់កិ. ដាក់ចុះនូវសក់ ។ - សត្ថ នចុំ. សស្ត្រាសម្រាប់ដាក់ចុះនូវសក់, កាំបិតសម្រាប់កោរនូវសក់ ។

**កោ** វិ.ស.អ. [ កឹ+សិ.វិ. ] អ្នកណា, ណា, អ្វី, ដូចម្តេច ។

**កោកនទ** នចុំ. [ កោក+នទ+អ ] ឈ្មោះកោកនទៈ, ជាទីបន្លឺនៃសត្វធ្វើនូវសម្លេងថាកិកិ ។ ម្យ៉ាងទៀតធម្មជាតញ៉ាំងពួកសត្វធ្វើនូវសម្លេងថាកិកិឱ្យបន្លឺឡើង; វិ. កោកេ នាទយតីតិ> កោកនទំ, (ឈូកក្រហម) ។

**កោក** អ.ន. ឈ្មោះកោកៈ ។ - សុនខលុទ្ធកវត្ថុ នចុំ. រឿងនៃព្រាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រោះផ្លែឈ្មោះកោកៈ, រឿងនៃព្រានអ្នកបណ្ដើរនូវផ្លែឈ្មោះ
កោកៈ ។

**កោកាលិក** អ.ន. ឈ្មោះកោកាលិកៈ ។ - **វត្ថុ** នចុំ. រឿងនៃភិក្ខុ
ឈ្មោះកោកាលិកៈ ។

**កោចិ** វិ.ស.អ. [ កឹ+ចិ+សិ.វិ. ] អ្នកណា, អ្នកណានីមួយ, ណានីមួយ
នីមួយ, តិចតួច ។

**កោជវ** ចុំ. កម្រាល, ព្រំ (តាមទម្លាប់ថាអង្រឹង) ។

**កោញ្ច** ចុំ. [ កោញ្ច+អ ] ក្រៀល, សត្វក្រៀល ។ - **រវំ** សម្រែកនៃ
ក្រៀល, កិ.ស្រែកនៃក្រៀល, កិ.ស្រែកដូចជាក្រៀល ។
- **សកុណ** សត្វស្លាបក្រៀល, សត្វក្រៀល ។

**កោណ្ឌញ្ញ** អ.ន. ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ។

**កោដុម្ពរមហាវិហារវាសី** ចុំ. [ កោដុម្ពរមហាវិហារ+វស+ណី ]
អ្នកនៅក្នុងវិហារធំឈ្មោះកោដុម្ពរ ។

**កោដិកណ្ណ** គុ. [ កោដិ+កណ្ណ ] មានត្រចៀកទ្រទ្រង់នូវគ្រឿងសម្រាប់
ពាក់មានតម្លៃមួយកោដិ; វិ. **កោដិអគ្ឃនកបិលន្ធនធារិនោ
កណ្ណា យស្ស សោ> កោដិកណ្ណោ** ។

**កោដិ** ឥ. [ កុដ+ឥ ] កោដិ, ទីបំផុត, ចុង, មុម ។ - **ប្បត្ត** គុ. ដល់
ហើយនូវទីបំផុត ។ - **សតសហស្ស** ប.ស. សែននៃកោដិ ។

**កោដិតខាណុក** ចុំ. [ កោដិត+ខាណុក ] ជង្គត់ដែលបុគ្គលបោះហើយ,
បង្គោលដែលបុគ្គលដាំហើយ, -ដែលបុគ្គលដោតហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កោដិត<កុដ+ឥ+ត ។

**កោដ្ដេត្វា** អ. [ កុដ្ដ+ណេ+ត្វា ] ដំហើយ, ផៃហើយ, វាយហើយ, បុកហើយ, ចិញ្ច្រាំហើយ ។

**កោដ្ដេន្ត** គុ. [ កុដ្ដ+ណេ+អន្ត ] កាលដំ, កាលផៃ, កាលវាយ, ... ។

**កោដ្ដេតិ** កិ. [ កុដ្ដ+ណេ+តិ.វ. ] ដំ, វាយ, បុក,... ។

**កោដ្ដេន្តី** ឥ. [ កុដ្ដ+ណេ+អន្ត+ឦ ] កាលដំ, កាលបុក,... ។

**កោដ្ដេតព្វយុត្តក** គុ. [ កោដ្ដេតព្វ+យុត្តក ] ជារបស់គួរគឺ...គប្បីដំ, -គប្បីផៃ,... ។

**កោដ្ដន** នបុំ. [ កុដ្ដ+យុ ] កិ.ដំ, កិ.បុក,...។ - **អត្ថ** បុំ. ប្រយោជន៍ដល់កិ.ដំ,... ។ - **បចនាទិ** គុ. (កិច្ច) មានកិ.បុក និងកិ. ចំអិនជាដើម ។

**កោដ្ដាបេត្វា** អ. [ កុដ្ដ+ណាបេ+ត្វា ] ញុំាង...ឱ្យបោះហើយ, -ឱ្យដោតហើយ, -ឱ្យដំហើយ, -ឱ្យវាយហើយ, -ឱ្យចិញ្ច្រាំហើយ,... ។

**កោដ្ឋគ្គ** គុ. [ កោដ្ឋ+អគ្គ ] មានដីប្រសើរគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីឡើងកាន់ជង្រុក, មានដីខ្ពោងគឺ..., មានដីលើសគឺ... ។

**កោដ្ឋសត** នបុំ. [ កោដ្ឋ+សត ] រយនៃជង្រុក ។

**កោដ្ឋាគារ** បុំ. នបុំ. [ កោដ្ឋ+អគារ ] ផ្ទះគឺជង្រុក (ឃ្លាំង) ។

**កោដ្ឋាគារិក** គុ. [ កោដ្ឋាគារ+ណិក ] អ្នកប្រកបក្នុងផ្ទះគឺជង្រុក, អ្នក

ប្រកបក្នុងឃ្លាំង (នាយឃ្លាំង); វ. **កោដ្ឋាគារេ និយុត្តោ> កោដ្ឋាគារិកោ** ។

**កោដ្ឋាទិ** គុ. [ កោដ្ឋ+អាទិ ] មានជង្រុកជាដើម ។

**កោដ្ឋាស** ចុំ. [ កោដ្ឋ+សិ+អ ] ចំណែក (វ. **កោដ្ឋំ ចុច្ឆតិ សរីរំ, ឥត្ថ សេតីតិ> កោដ្ឋាសោ**) ។

**កោណ្ឌ** គុ. [ កុណ្ឌ+ណ ] កំបុត, ខ្លៅ, ឆោត, អាក្រក់, លាមក ។

**កោណ្ឌធាន** អ.ន. ព្រះថេរៈឈ្មោះកោណ្ឌធាន ។ . **ត្ថេរវត្ថុ** នចុំ. រឿងនៃព្រះថេរៈឈ្មោះកោណ្ឌធាន ។

**កោតុហល** នចុំ. [ កុ+តុដ+អល ] កិ.ភ្ញាក់ផ្អើល, សេចក្ដីជ្រួលជ្រើម, ការរំជួល ។ . **ជាត** គុ. អ្នកមានសេចក្ដីភ្ញាក់ផ្អើលកើតហើយ; វ. **កោតុហលំ ជាតំ យេសំ តេ> កោតុហលជាតា** ។

**កោតុហលិក** ចុំ. [ កោតុហល+ណិក ] បុរសឈ្មោះកោតុហលិក, បុរសអ្នកមានសេចក្ដីភ្ញាក់ផ្អើល; វ. **កោតុហលំ យស្ស អត្ថីតិ> កោតុហលិកោ** ។ . **កាល** ចុំ. កាលនៃឃោសកៈជាបុរសឈ្មោះកោតុហលិកៈ ។

**កោធនទ្ធិ** ឥ. [ កោធ+នទ្ធិ ] ខ្សែជាគ្រឿងចងគឺសេចក្ដីក្រោធ, ខ្សែជាគ្រឿងត្របែងគឺសេចក្ដីក្រោធ ។

**កោធនមត្ត** គុ. [ កោធន+មត្ត ] ទោសជាតគ្រាន់តែសេចក្ដីក្រោធ ។

**កោធន** ចុំ. [ កុធ+យុ ] (បុគ្គល) អ្នកក្រោធ, អ្នកខឹង; វ. **កុជ្ឈ-តីតិ> កោធនោ** ។ អ្នកមានកិ. ក្រោធជាប្រក្រតី; វ. **កុជ្ឈិតុំ**

Websites: WatKhemaraRatanaram.org or WatKhmers.org

**សីលមស្សាតិ> កោធនោ** ។

**កោធ** បុំ. [ កុធ+ណ ] សេចក្តីក្រោធ, សេចក្តីខឹង, កំហឹង; វិ. **កុជ្ឈនំ> កោធោ** ។ -**វត្ថុវណ្ណនា** ឥ. កថាជាគ្រឿងពណ៌នានូវកោធវត្ថុ; វិ. **កោធវត្ថុំ វណ្ណេតិ ឯតាយាតិ> កោធវត្ថុវណ្ណនា** ។ -**វស** បុំ. អំណាចនៃសេចក្តីក្រោធ ។

**កោធាភិភូ** គុ. [ កោធ+អភិ+ភូ+អ ] អ្នកគ្របសង្កត់នូវសេចក្តីក្រោធ; វិ. **កោធំ អភិភវតីតិ> កោធាភិភូ** ។

**កោធាភិភូត** គុ. [ កោធ+អភិភូត ] អ្នកគឺសេចក្តីក្រោធគ្របសង្កត់ហើយ; វិ. **កោធេន អភិភូតោ> (កោធាភិភូតោ)** ។

**កោធុប្បាទ** បុំ. [ កោធ+ឧប្បាទ ] កិ.ញុំាងសេចក្តីក្រោធឱ្យកើតឡើង, កិ.កើតឡើងនៃសេចក្តីក្រោធ ។

**កោនាគមន** អ.ន. ព្រះពុទ្ធព្រះនាមកោនាគមនៈ ។

**កោប** បុំ. [ កុប+ណ ] កិ.កម្រើក, សេចក្តីក្រោធ, សេចក្តីខឹង, កំហឹង; វិ. **កុបនំ> កោបោ** ។ -**និព្វាបនមត្ត** គុ.. (កុសល) ត្រឹមតែកិ.ញុំាងសេចក្តីក្រោធឱ្យរលត់ ។ -**មត្ត** គុ. ទោសជាតត្រឹមតែសេចក្តីក្រោធ, ទោសជាតគ្រាន់តែកិ.កម្រើក ។

**កោបេតុំ.** អ. [ កុប+ណេ+តុំ ] ដើម្បីញុំាង...ឱ្យកម្រើកបាន ។

**កោមារភច្ច** បុំ. [ កុមារភត+ណ្យ ] ពេទ្យដែលអភយរាជកុមារឱ្យចិញ្ចឹមហើយ, ពេទ្យឈ្មោះកុមារភច្ចៈ; វិ. **កុមារេន ភតោ បោសាបិតោតិ> កុមារភតោ, កុមារភតោ ឯវ>**

Websites: WatKhemaraRatanaram.org or WatKhmers.org

**កោមារភច្ចោ** ។

**កោមុទី** ឥ. [ កោមុទ+ណី ] ជាទីរីកនៃផ្កាកុមុទ (វិ. **កុយំ មុទយំ មោទន្តីតិ> កុមុទា, កុមុទានំ សមូហោ> កោមុទោ, កោមុទោ ឯត្ថ អត្ថីតិ> កោមុទី)** ។

**កោលដ្ឋិមត្ត** ត្រ. [ កោលដ្ឋិ+មត្ត ] មានគ្រាប់នៃក្រពៅជាប្រមាណ, ប៉ុនគ្រាប់នៃក្រពៅ ។ **កោលដ្ឋិ <កោល+អដ្ឋិ** ។

**កោលរុក្ខ** ពុំ. [ កោល+រុក្ខ ] ដើមនៃក្រពៅ ។ - **វាសី** ពុំ. អ្នកនៅទៀបដើមនៃក្រពៅ, អ្នកមានកិ.នៅទៀបដើមនៃក្រពៅជាប្រក្រតី ។

**កោលាប** ត្រ. [ កុល+អាប ] ពុក, ឈើពុក (ប្រើជា **កោឡាប** ក៏មាន) ។

**កោលាហល** ពុំ. [ កុល+អាហល ] កោលាហល, ការជ្រួលជ្រើម, សំឡេងតឹកកង, សម្លេងជាគ្រឿងបាននូវកិ.ប្រសព្វរាប់ (វិ. **កោលនំ> កោលោ, តមាហលតិ ឋិន្ទតីតិ> កោលាហលោ)** ។

**កោលិត** ត្រ. [ កុល+ណិក ] អ្នកកើតក្នុងត្រកូល; វិ. **កុលេ ជាយតីតិ> កោលិតោ, សោ ឯវ> កោលិតោ** ។ អ.ន. ឈ្មោះកោលិតៈ ។ - **គ្គាម** ពុំ. កោលិតគ្រាម, ស្រុកឈ្មោះកោលិតៈ ។ - **បរិព្វាជក** ពុំ. បរិព្វាជកឈ្មោះកោលិតៈ ។ - **មាណវ** ពុំ. មាណពឈ្មោះកោលិតៈ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**កោលិយ** គុ. [ កោល+ណិយ ] អ្នកកើតទៀបដើមក្រពៅ ឬអ្នកនៅទៀបដើមក្រពៅ (ក្រុងឈ្មោះកោលិយ); វិ. **កោលរុក្ខេ ជាយន្តីតិ> កោលិយា, កោលរុក្ខេ វសន្តីតិ វា> កោលិយា** ។ - **កម្មករ** បុំ. ជនអ្នកធ្វើនូវការងារនៃព្រះរាជានៅក្នុងក្រុងកោលិយៈ, កម្មករនៃអ្នកក្រុងកោលិយៈ ។ - **ធីតា** ឥ. ធីតានៃជនអ្នកក្រុងកោលិយ ៈ ។ - **នគរវាសី** បុំ. អ្នកនៅក្នុងក្រុងកោលិយៈ ។

**កោវិទ** បុំ. [ កុ+វិទ+ណ ] អ្នកបាននូវវាចា, អ្នកបាននូវសំដី (អ្នកឆ្លាត, ឈ្លាស, វាងវៃ); វិ. **កុំ វាចំ វិន្ទតីតិ> កោវិទោ** ។

**កោវិឡាររុក្ខ** បុំ. [ កោវិឡារ+រុក្ខ ] ដើមរលួស, ដើមរលួសផ្កុង ។ ប្រើជា **កោវិឡារ** ក៏មាន ។ <កុ+វិទ+អារ = វិ. **កុំ បថវឹ វិទារយតិ មូលេនាតិ> កោវិឡារោ** ។

**កោសជ្ជ** នបុំ. [ កុសីត+ណ្យ ] ភាវៈនៃបុគ្គលអ្នកលិចចុះក្នុងកិលេស គឺបណ្ឌិតគប្បីខ្ពើម (ភាវៈនៃបុគ្គលខ្ជិល; ភាវៈនៃសេចក្ដីខ្ជិល, សេចក្ដីខ្ជិល) វិ. **កុច្ឆិតេ កិលេសេ សីទតីតិ> កុសីតោ; កុសីតស្ស ភាវោ> កោសជ្ជំ; កុសីតោ ឯវ វា> កោសជ្ជំ** ។ - **វស** បុំ. អំណាចនៃសេចក្ដីខ្ជិល ។

**កោសម្ពិក** គុ. [ កោសម្ពី+ណិក ] អ្នកនៅក្នុងក្រុងកោសម្ពី; វិ. **កោសម្ពិយំ វសន្តីតិ> កោសម្ពិកា** ។ - **វត្ថុ** នបុំ. រឿងនៃភិក្ខុអ្នកនៅក្នុងក្រុងកោសម្ពី ។ - **សេដ្ឋី** បុំ. សេដ្ឋីអ្នកនៅក្នុងក្រុងកោសម្ពី ។ - **វាសិតិស្សត្ថេរវត្ថុ** នបុំ. រឿងនៃព្រះថេរៈ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឈ្មោះតិស្សៈនៅក្នុងក្រុងកោសម្ពី ។

**កោសល** អ.ន. ដែនឈ្មោះកោសល ។ - **ជនបទ** ចុំ. ជនបទឈ្មោះកោសល ។ - **នរិន្ទ** គុ. ព្រះរាជាជាធំជាងនរៈឈ្មោះកោសល, ព្រះរាជាជាធំរបស់នរៈក្នុងដែនកោសល ។ - **រដ្ឋ** នចុំ. ដែនឈ្មោះកោសល ។ - **រាជ** ចុំ. ស្ដេចជាធំក្នុងដែនកោសល ។ - **សំយុត្ត** អ.ន. គម្ពីរឈ្មោះកោសលសំយុត្ត ។

**កោសិយ** អ.ន. ឈ្មោះកោសិយ : ។

**កោសុ** និ. [ កោ+សុ ] អ្នកណាអេះ, អ្នកណាហ្ន៎ ។

**កោហញ្ញ** នចុំ. [ កុហក+ណ្យ ] ភាវៈនៃអ្នកកុហក, ភាវៈនៃអ្នកញៀំងលោកឱ្យភាន់ភាំង; វិ. **កុហកស្ស ភាវោ> កោហញ្ញំ** ។

**កោឡាបរុក្ខ** ចុំ. [ កោឡាប+រុក្ខ ] ឈើពុក, ដើមឈើពុក ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ខចិត្វា** អ. [ ខច+ឥ.អា.+ត្វា ] វិចិត្រហើយ, ច្នៃហើយ ។

**ខជ្ជក** ន‌ចុំ. [ ខាទ+ត+ក.ស. ] វត្ថុគឺបុគ្គលគប្បីទំពាស៊ី (បង្អែម, ចំណី); វិ. **ខាទិតព្វន្តិ> ខជ្ជំ; ខជ្ជំ ឯវ> ខជ្ជកំ** ។

**ខជ្ជ** ន‌ចុំ. [ ខាទ+ត ] វត្ថុគឺបុគ្គលគប្បីទំពាស៊ី (បង្អែម, ចំណី); វិ. **ខាទិតព្វន្តិ> ខជ្ជំ** ។ . **ម៉ំស** ន‌ចុំ. បង្អែមនិងសាច់ ។ . **វិកតិ** ឥ. វត្ថុគឺបុគ្គលគប្បីទំពាស៊ីគឺបុគ្គលធ្វើឱ្យវិសេស; -ឱ្យប្លែក; បង្អែមដ៏ប្លែក ។

**ខជ្ជោបនក** ចុំ. អំពិលអំពែក ។ . **សទិស** គុ. ប្រាកដស្មើដោយអំពិលអំពែក, ដូចជាអំពិលអំពែក ។

**ខញ្ជ** គុ. [ ខញ្ជ+អ ] ខ្ជក, មនុស្សខ្ជក; វិ. **ខញ្ជតីតិ> ខញ្ជោ** ។ . **ប្បហារ** ចុំ. កិ.ប្រហារនៃមនុស្សខ្ជក, កិ.ប្រហារនូវអាចម៍នៃពពៃនៃមនុស្សខ្ជក (កិ.ប្រហារដោយអាចម៍នៃពពៃ) ។

**ខដខដសទ្ទ** ចុំ. [ ខដខដ+សទ្ទ ] សំឡេងថាខដខដះ ។

**ខណ** ចុំ. [ ខិ+យុ ] កាលជាទីអស់ទៅ ឬ កាលជាទីអស់ទៅនៃអាយុនៃសត្វ (ខណៈ, ស្របក់, មួយរំពេច); វិ. **ខិយតិ ឯត្ថាតិ> ខណោ; សត្តានំ អាយុ ខិយតិ ហាយតិ ឯត្ថ ការេណតិ ខា> ខណោ** ។ . **មត្ត** គុ. កាលត្រឹមតែមួយខណៈ ។

**ខណាតីត** គុ. [ ខណ+អតីត ] មានខណៈកន្លងទៅហើយ, កន្លងហើយនូវខណៈ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ខណិក** គុ. [ ខណ+ណិក ] ប្រព្រឹត្តទៅក្នុងខណៈ, ប្រព្រឹត្តទៅអស់កាលមួយស្របក់ ឬមួយរំពេច ។ . **ឥត្តរប្បច្ចុប្បន្ន** ចុំ. សេចក្ដីថាកាយប្រព្រឹត្តទៅក្នុងខណៈ និងកិ.ប្រាកដចំពោះថាជារបស់ណាមក, អត្ថថាកាយជាទីចូលទៅតាំងនៅចំពោះថាជារបស់ណាមក ប្រព្រឹត្តទៅអស់កាលមួយរំពេច ។

**ខណ្ឌ** ចុំ., គុ. [ ខណ្ឌ+អ ] កំណាត់, ចំណែក, ដុំ, បាក់, ដាច់; វិ. **ខណ្ឌយតិ សមុច្ឆាយមិតិ> ខណ្ឌោ** ។ . **ទន្ត** គុ. អ្នកមានធ្មេញបាក់ ។ . **សីលាទិតា** ឥ. ភាវៈនៃទោសជាឥតមានសីលដាច់ជាដើម; វិ. **ខណ្ឌំ សីលំ> ខណ្ឌសីលំ; ខណ្ឌសីលំ អាទិ យស្ស តំ> ខណ្ឌសីលាទិ; ខណ្ឌសីលាទិនោ ភាវោ> ខណ្ឌសីលាទិតា** ។

**ខណ្ឌាខណ្ឌិក** គុ. [ ខណ្ឌាខណ្ឌ+ណិក ] មានបំណែកតូចនិងបំណែកធំ (ឲ្យជារបស់មានបំណែកតូចនិងបំណែកធំ); វិ. **ខណ្ឌាខណ្ឌោ យស្ស អត្ថីតិ> ខណ្ឌាខណ្ឌិកំ** ។

**ខណ្ឌាទិភាវប្បត្ត** គុ. [ ខណ្ឌាទិភាវ+បត្ត ] ដល់ហើយនូវភាវៈនៃទោសជាឥតមានសីលដាច់ជាដើម ។

**ខណ្ឌិច្ចាទិ** គុ. [ ខណ្ឌិច្ច+អាទិ ] (វិការៈ) មានភាវៈនៃបុគ្គលមានធ្មេញបាក់ជាដើម; វិ. **ខណ្ឌិកស្ស ភាវោ> ខណ្ឌិច្ចំ** ។

**ខត្តិយ** ចុំ. [ ខត្ត+ឥយ ] ពូជពង្សនៃខត្តៈ, ជាធំក្នុងខេត្តដែន, ជាអធិបតីនៃស្រែ (ក្សត្រិយ៍) ។ . **កញ្ញា** ឥ. កញ្ញានៃក្សត្រិយ៍ ។ . **ធីតា** ឥ. ធីតានៃក្សត្រិយ៍ ។ . **បព្វជិត** គុ. ជាក្សត្រិយ៍បួស

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ, ជាក្សត្រិយ៍ទ្រង់ផ្នួសហើយ ។ - **បរិវារ** គុ. មានក្សត្រិយ៍ជាបរិវារ ។ - **ព្រាហ្មណកុល** នចុំ. ត្រកូលនៃក្សត្រិយ៍ និងត្រកូលនៃព្រាហ្មណ៍ ។ - **មហាសាលព្រាហ្មណមហាសាលកុល** នចុំ. ត្រកូលនៃខត្តិយមហាសាលនិងព្រាហ្មណមហាសាល ។ - **មហាសាល** នចុំ. ក្សត្រិយ៍ជាមហាសាល ។ - **មាន** ចុំ. មានះនៃក្សត្រិយ៍, មានះថាអញជាក្សត្រិយ៍; វិ. **ខត្តិយោ (អហំ) ឥតិ មានោ> ខត្តិយមានោ** ។ - **រាជធីតា** ឥ. ធីតានៃព្រះរាជាជាក្សត្រិយ៍ ។ - **មាយា** ឥ. មាយានៃក្សត្រិយ៍, ពុតនៃក្សត្រិយ៍ ។ - **វំស** ចុំ. វង្សនៃក្សត្រិយ៍ ។ - **សុខុមាល** គុ. ជាក្សត្រិយ៍ចំរើននៅក្នុងសេចក្ដីសុខ, ជាក្សត្រិយ៍ចំរើនដោយសេចក្ដីសុខ, ជាក្សត្រិយ៍ល្អិតទន់, ជាក្សត្រិយ៍ទន់ល្អ ។

**ខទិរ** ចុំ. [ ខទ+ឥរ; ខាទ+រ ] (ឈើ) ជាគ្រឿងជាប់មាំ ឬឈើដែលបាណកជាតតែងទំពាស៊ី (គគីរ, សង្កែ); វិ. **ខទន្តិ ធន្តានេនាតិ> ខទិរោ; ខាទិយតិ បាណកេហីតិ ខា> ខទិរោ** ។ - **ខាណុ** ចុំ., នចុំ. ដង្គត់នៃឈើគគី ។ - **គហណ, - ន** នចុំ. ស្បាតនៃគគី, ជាទីស្បាតដោយដើមគគី (ជាទីស្មុកស្មាញដោយដើមសង្កែ) ។ - **អង្គារជាតក** នចុំ. ជាតកគឺបណ្ដិតកំណាត់ហើយដោយរងើកភ្លើងនៃឈើគគី ។ - **អង្គាររាសិ** ចុំ. គំនររងើកភ្លើងជាវិការះនៃឈើគគី។ - **ឍម្ព** ចុំ. សសរជាវិការះនៃឈើគគី ។ - **ទារុ** នចុំ. ឧសនៃឈើគគី, ឧសជាវិការះនៃឈើគគី, ឧសជាវិការះនៃដើមសង្កែ ។ - **រុក្ខកណ្ដក** ចុំ. បន្លានៃឈើគគី, បន្លានៃឈើសង្កែ ។ - **រុក្ខ** ចុំ. ដើមនៃគគី, ដើមនៃសង្កែ ។ - **វនិយ-**

Websites: WatKhemaraRatanaram.org or WatKhmers.org

**រេវតត្ថេរវត្ថុ** ឧទុំ. រឿងនៃព្រះថេរៈឈ្មោះរេវតៈនៅក្នុងព្រៃនៃឈើគគី, ..នៅក្នុងព្រៃដ៏ដេរដាសដោយដើមគគី ។

**ខនតិ** កិ. [ ខន+អ+តិ.វ. ] ជីក, គាស់ ។

**ខនថ** កិ. [ ខន+អ+ថ.ប. ] ចូរជីក, ចូរគាស់ ។

**ខនាបេត្វា** អ. [ ខន+ណាបេ+ត្វា ] ញុំាង...ឱ្យជីកហើយ ។

**ខនាបេស្សាមិ** កិ. [ ខន+ណាបេ+ស្សាមិ.ភ. ] នឹងញុំាង...ឱ្យជីក ។

**ខនិ** កិ. [ ខន+អ+ឦ.អជ្ជ. ] ជីកហើយ ។

**ខនិត** គុ. [ ខន+ឥ.អា.+ត ] គឺ...ជីកហើយ ។

**ខនិត្វា** អ. [ ខន+ឥ.អា.+ត្វា ] ជីកហើយ ។

**ខនិយមាន** គុ. [ ខន+ឥ.អា.+យ+មាន ] គឺ...កាលជីក ។

**ខន្តិ** ឥ. [ ខម+តិ ] ខន្តី, សេចក្តីអត់ធន់; វិ. **ខមនំ> ខន្តិ** ។ ..**ពល** ឧទុំ. កម្លាំងនៃខន្តី ។ ..**មេត្តោទក** ឧទុំ. ទឹកគឺខន្តីនិងមេត្តា, ខន្តីនិងមេត្តាដូចជាទឹក ។ ..**វាទិជាតក** ឧទុំ. ជាតកគឺបណ្ឌិតកំណាត់ហើយដោយតាបសឈ្មោះខន្តិវាទី ។ ..**វាទិភូត** គុ. ជាតាបសឈ្មោះខន្តិវាទី, ជាតាបសឈ្មោះខន្តិវាទីកើតហើយ ។ ..**សោរច្ច** ឧទុំ. ខន្តីនិងភាវៈនៃបុគ្គលអ្នកត្រេកអរដោយល្អ, ខន្តិនិងភាវៈនៃសេចក្តីត្រេកអរដោយល្អ, សេចក្តីអត់ធន់និងសេចក្តីស្ងប់ស្ងៀម(សោរច្ច<សុរត+ណ្យ = វិ. **សុរតស្ស ភាវោ> សោរច្ចំ, សុរតោ ឯវ> សោរច្ចំ**) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ខន្ធ** ពុំ. [ ខន+ធច្ចខម+ត ] ខន្ធ, គំនរ កង, ដើម, កំណាត់ឈើ, ហ្វូង, ពួក, ប្រជុំ, ក ។ . **អជ្ឈិក** នពុំ. ឆ្អឹងនៃក ។ . **ទុក្ខ** នពុំ. ទុក្ខគឺការរក្សានូវខន្ធ, ទុក្ខដែលកើតអំពីខន្ធ, ទុក្ខប្រចាំខន្ធ ។ . **ធាតុអាយ-តនឥន្ទ្រិយពលពោជ្ឈង្គសតិប្បដ្ឋានបរិទីបក** គុ. ជាគ្រឿងសម្តែងនូវខន្ធ និងធាតុ និងអាយតនៈ និងឥន្ទ្រីយ និងពលៈ និងពោជ្ឈង្គ និងសតិប្បដ្ឋាន ។ . **ធាតុអាយតនពោធិ-បក្ខិយធម្ម** ពុំ. ខន្ធនិងធាតុនិងអាយតនៈនិងពោធិបក្ខិយធម៌ ។ . **ធាតុអាយតនាទិភេទ** គុ. ផ្សេងដោយធម៌មានខន្ធ និងធាតុ និងអាយតនៈជាដើម ។ . **ធាតុអាយតនមត្ត** គុ. ធម៌ត្រឹមតែខន្ធ និងធាតុ និងអាយតនៈ ។ . **បរិហរណទុក្ខ** នពុំ. ទុក្ខគឺកិ.រក្សានូវខន្ធ ។ . **បរិហរណសម** គុ. ស្មើដោយកិ.រក្សានូវខន្ធ, ស្មើដោយកិ.នាំទៅជុំវិញនូវខន្ធ ។ . **រសាទិ** គុ. មានរសនៃដើមជាដើម, មានរសដែលកើតអំពីដើមជាដើម ។ . **លោកា-ទិសង្ខាត** គុ. ពោលគឺលោកមានខន្ធលោកជាដើម, គឺបណ្ឌិតរាប់ព្រមហើយថាលោកមានខន្ធលោកជាដើម ។ . **វដ្ដ** ពុំ. វដ្ដៈគឺខន្ធ ។ . **វស** ពុំ. អំណាចនៃខន្ធ ។ . **សម** គុ. ស្មើដោយខន្ធ ។ . **អា-ទិប្បដិសំយុត្ត** គុ. ប្រកបព្រមចំពោះហើយដោយធម៌មានខន្ធជាដើម ។ . **អាទិភេទ** គុ. ផ្សេងដោយធម៌មានខន្ធជាដើម ។ . **អាវារ** ពុំ. ប្រទេសជាទីបិទបាំងដោយកំណាត់ឈើ (បន្ទាយ, កងទ័ព); វិ. **ខន្ធេហិ អាវារេន្តិ ឯត្ថាតិ> ខន្ធាវារោ** ។

**ខមនីយ** គុ. [ ខម+អនីយ ] គឺ... គប្បីអត់បាន, គឺ...គប្បីអត់ធន់បាន;

Websites: WatKhemaraRatanaram.org or WatKhmers.org

វិ. ខមិតព្វន្តិ> ខមនីយំ ។

**ខមន្តិ** កិ. [ ខម+អ+អន្តិ_វ. ] គួរ, អត់, អត់ឱន ។

**ខមថ** កិ. [ ខម+អ+ថ_ប. ] ចូរអត់, ចូរអត់ទោស, សូមអត់,... ។

**ខម** គុ. [ ខម+អ ] អត់, អត់ធន់, គួរ ។

**ខមាបនុបាយ** ពុំ. [ ខមាបន+ឧបាយ ] ឧបាយជាគ្រឿងញុំាង...ឱ្យអត់, -ឱ្យអត់ទោស ។

**ខមាបិត** គុ. [ ខម+ណាបេ+ឥ_អា.+ត ] គឺ...ឱ្យអត់ហើយ, -ឱ្យអត់ទោសហើយ; វិ. ខមាបិយិត្ថាតិ> ខមាបិតោ ។ . កាល ពុំ. កាលនៃ...គឺ...ឱ្យអត់ហើយ, -ឱ្យអត់ទោសហើយ ។

**ខមាបិយមាន** គុ. [ ខម+ណាបេ+ឥ_អា.+យ+មាន ] គឺ...កាលឱ្យអត់,... ។

**ខមាបេតិ** កិ. [ ខម+ណាបេ+តិ_វ. ] ញុំាង...ឱ្យអត់,... .។

**ខមាបេតុំ** អ. [ ខម+ណាបេ+តុំ ] ដើម្បីញុំាង...ឱ្យអត់,... ។

**ខមាបេត្វា** អ. [ ខម+ណាបេ+ត្វា ] ញុំាង...ឱ្យអត់ហើយ,... ។

**ខមាបេថ** កិ. [ ខម+ណាបេ+ថ_ប. ] ចូរញុំាង....ឱ្យអត់,... ។

**ខមាបេយ្យ** កិ. [ ខម+ណាបេ+ឯយ្យ_ស. ] គប្បីញុំាង...ឱ្យអត់,... ។

**ខមាបេសិ** កិ. [ ខម+ណាបេ+សិ_អជ្ជ., ចុះស_អា. ] ញុំាង...ឱ្យអត់ហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ខមាបេហិ** កិ. [ ខម+ណាបេ+ហិ.ប. ] ចូរញ៉ាំង...ឱ្យអត់,... ។

**ខមាបេស្សំ** កិ. [ ខម+ណាបេ+ឧំ.អជ្ជ., ចុះស.អា. ] ញ៉ាំង...ឱ្យអត់ហើយ,... ។

**ខមាបេស្សាមិ** កិ. [ ខម+ណាបេ+ស្សាមិ.ភ. ] នឹងញ៉ាំង...ឱ្យអត់,... ។

**ខមាមិ** កិ. [ ខម+អ+មិ.វ. ] អត់, អត់ទោស,... ។

**ខមិស្សតិ** កិ. [ ខម+អ+ឥ.អា+ស្សតិ.ភ. ] នឹងអត់,... ។

**ខយ** បុំ. [ ខិ+អ ] កិ.អស់, ការអស់ទៅ; វិ. **ខយនំ> ខយោ** ។ - **ប្បត្ត** គុ. ដល់ហើយនូវកិ.អស់ទៅ ។ - **វយធម្ម** គុ. មានកិ.អស់ទៅនិងកិ.សូន្យទៅជាធម្មតា; វិ. **ខយវយោ ធម្មោ យស្ស តំ> ខយវយធម្មំ** ។ - **វយប្បត្ត** គុ. ដល់ហើយនូវកិ.អស់ទៅ និងកិ.សូន្យទៅ ។ - **វយ** បុំ. កិ.អស់ទៅនិងកិ.សូន្យទៅ ។ - **សង្ខាត** គុ. ពោលគឺកិ.អស់ទៅ, គឺបណ្ឌិតរាប់ព្រមហើយថាកិ.អស់ទៅ ។

**ខរតរ** គុ. [ ខរ+តរ ] ក្លាជាង, ខ្លាំងជាង, រឹងជាង ។

**ខរមន្តី** គុ. [ ខរ+មន្តិ ] មានសេចក្តីគិតដ៏ក្លា, មានគំនិតមោះមុត, មានគំនិតអង់អាច, មានគំនិតវាងវៃ ។

**ខល** នបុំ. [ ខល+អ ] ទីដែលគេគប្បីសំអាត (លាន) ។ - **កាល** បុំ. កាលជាទីធ្វើនូវលាន ។ - **អគ្គ** គុ. មានដ៏ប្រសើរគឺបុគ្គលគប្បី

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យក្នុងកាលជាទីនាំមកកាន់លាន, មានដីលើសគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីធ្វើនូវលាន ។ - **ភណ្ឌកាល** ចុំ. កាលជាទីធ្វើនូវកិ. បញ្ចាន់ក្នុងលាន, កាលជាទីធ្វើនូវកិ.រោយក្នុងលាន ។ - **ភណ្ឌគុ.** មានដីថ្លោងគឺបុគ្គលគប្បីឱ្យក្នុងកាលជាទីបញ្ចាន់ក្នុងលាន ។ - **មណ្ឌលមត្ត** គុ. មានមណ្ឌលនៃលានជាប្រមាណ, ប៉ុនមណ្ឌលនៃលាន ។ - **មណ្ឌលសទិស** គុ. ប្រាកដស្មើដោយមណ្ឌលនៃលាន ។

**ខលិត** គុ. [ ខល+ឥ_អា.+ត ] ដែល...ភ្លាំងភ្លាត់ហើយ, ...ភ្លាត់ហើយ, ន. សេចក្ដីភ្លាំងភ្លាត់ ។

**ខលិត្វា** អ. [ ខល+ឥ_អា.+ត្វា ] ភ្លាត់ហើយ ។

**ខល្លាតសីស** នចុំ. [ ខល្លាត+សីស ] ក្បាលនៃបុគ្គលទំពែក, សីសៈទំពែក (**ខល្លាត**<ខ+លា+ត = អ្នកកាន់យកនូវសីសៈទទេ (ទំពែក); វិ. **ខំ គុច្ឆំ សីសំ លាតីតិ**> **ខល្លាតោ** ។

**ខលុ** និ. ឮថា, បានឮថា, គេឮថា, សេចក្ដីដំណាលថា ។

**ខាទតិ** កិ. [ ខាទ+អ+តិ_វ. ] ស៊ី, ទំពាស៊ី ។

**ខាទន** នចុំ. [ ខាទ+យុ ] កិ.ស៊ី. កិ.ទំពាស៊ី; វិ. **ខាទយតេតិ**> **ខាទនំ** ។ - **បិវនសមត្ថ** គុ. អាចក្នុងកិ.ទំពាស៊ី និងកិ.ផឹក ។ - **វស** ចុំ. អំណាចនៃកិ.ទំពាស៊ី ។ - **សមត្ថ** គុ. អាចក្នុងកិ.ទំពាស៊ី ។

**ខាទនីយ** គុ. [ ខាទ+អនីយ ] វត្ថុគឺបុគ្គលគប្បីទំពាស៊ី (បង្អែម, ចំណី);

Websites: WatKhemaraRatanaram.org or WatKhmers.org

# ខា

១. ខាធិកព្វន្តិ> ខាធនិយំ ។ . ភោជនីយសយន ន៍ចុំ. វត្ថុគឺបុគ្គលគប្បីទំពាស៊ី និងវត្ថុគឺបុគ្គលគប្បីបរិភោគ និងទីជាទីដេក ។ . អាទិទានឱបម្ម ន៍ចុំ. ភាវៈនៃវាចាជាគ្រឿងប្រៀបដោយកិ.ឱ្យនូវវត្ថុមានវត្ថុគឺបុគ្គលគប្បីទំពាស៊ីជាដើម (ឧបមាយភាវោ> ឱបម្មំ) ។

**ខាទមាន** គុ. [ ខាទ+អ+មាន ] កាលទំពាស៊ី ។

**ខាទសិ** កិ. [ ខាទ+អ+សិ.វ. ] ស៊ី, ទំពាស៊ី ។

**ខាទន្ត** គុ. [ ខាទ+អ+អន្ត ] កាលទំពាស៊ី ។

**ខាទន្តិ** កិ. [ ខាទ+អ+អន្តិ.វ ] ស៊ី, ទំពាស៊ី ។

**ខាទាបេសិ** កិ. [ ខាទ+ណាបេ+ឦ.អជ្ជ., ចុះស.អា. ] ញុំាង...ឱ្យទំពាស៊ីហើយ ។

**ខាទាបេស្សាមិ** កិ. [ ខាទ+ណាបេ+ស្សាមិ.ភ. ] នឹងញុំាង...ឱ្យទំពាស៊ី ។

**ខាទាម** កិ. [ ខាទ+អ+ម.ប. ឬស្សាម.ភ. ] ចូរទំពាស៊ី, នឹងទំពាស៊ី ។

**ខាទាហិ** កិ. [ ខាទ+អ+ហិ.ប. ] ចូរទំពាស៊ី ។

**ខាទិ** កិ. [ ខាទ+អ+ឦ.អជ្ជ. ] ទំពាស៊ីហើយ ។

**ខាទិត** គុ. [ ខាទ+ឥ.អា.+ត ] គឺ...ទំពាស៊ីហើយ, ស៊ីហើយ ។ . បឹត.នច្ចគីតវាទិតាទិ គុ. វត្ថុគឺ...ទំពាស៊ី និងវត្ថុគឺ...ផឹក និងគ្រឿងតន្ត្រីមានកិ.រាំ និងកិ.ច្រៀង និងកិ.ប្រគំជាដើម ។ . បុព្វ គុ.

Websites: WatKhemaraRatanaram.org or WatKhmers.org

គឺ...ធ្លាប់ទំពាស៊ីហើយ, គឺ...ទំពាស៊ីហើយក្នុងកាលមុន ។ . មំស
នចុំ. សាច់គឺ...ទំពាស៊ីហើយ ។

ខាទិតុំ អ. [ ខាទ+ឥ_អា.+តុំ ] ដើម្បីទំពាស៊ី ។

ខាទិត្វា អ. [ ខាទ+ឥ_អា+ត្វា ] ទំពាស៊ីហើយ ។

ខាទិត្ត កិ. [ ខាទ+អ+ឥ_អា.+ត្ត_ហេ. ] ទំពាស៊ីហើយ ។

ខាទិយមាន តុ. [ ខាទ+ឥ_អា.+យ+មាន ] គឺ...កាលទំពាស៊ី, គឺ...កាល
ស៊ី ។

ខាទិស្សាមិ កិ. [ ខាទ+អ+ឥ_អា.+ស្សាមិ_ភ. ] នឹងទំពាស៊ី ។

ខាទេយ្យ កិ. [ ខាទ+អ+ឯយ្យ_ស. ] គប្បីទំពាស៊ី ។

ខាណុ, ខានុក ចុំ., នចុំ. ដង្គត់, បង្គោល ។ . សញ្ញី ចុំ. អ្នកមាន
សេចក្តីសំគាល់ថាដង្គត់ ។ . មត្ត តុ. ត្រឹមតែដង្គត់, មានដង្គត់ជា
ប្រមាណ ។ . មត្ថក ចុំ. ទីបំផុតនៃដង្គត់, ចុងនៃដង្គត់, ក្បាលនៃ
ដង្គត់ ។

ខានុកោណ្ឌញ្ញ អ.ន. ព្រះថេរះឈ្មោះខានុកោណ្ឌញ្ញៈ ។ . ត្ថេរវត្ថុ
នចុំ. រឿងនៃព្រះថេរះឈ្មោះខានុកោណ្ឌញ្ញៈ ។

ខាយតិ កិ. [ ខា+យ+តិ_វ. ] ប្រាកដ, ជាក់ស្តែង ។

ខាយិ កិ. [ ខា+យ+ឦ_អជ្ជ. ] ប្រាកដហើយ, ជាក់ស្តែងហើយ ។

ខាយឹសុ កិ. [ ខា+យ+ឧំ_អជ្ជ. ] ប្រាកដហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ខារិក** គុ. [ ខារ+ណិក ] មានរសខារ ។

**ខារបរិសេក** ចុំ. [ ខារ+បរិ+សិច+ណ ] កិ.ស្រោចដោយទឹកដ៏ផ្សា ។

**ខារិភណ្ឌក** នចុំ. [ ខារិ+ភណ្ឌក ] ភណ្ឌៈគឺគ្រឿងបរិក្ខារ, ភណ្ឌៈសម្រាប់នាំនូវបរិក្ខារ (តាមទម្លាប់ថា «ភណ្ឌៈគឺទ្រែក») ភណ្ឌៈមានខារិជាប្រមាណ ។

**ខិឌ្ឌាបសុតតា** ឥ. [ ខិឌ្ឌបសុត+តា ] ភាវៈនៃ...ជាអ្នកខ្វល់ខ្វាយក្នុងកិ.លេង; វិ. **ខិឌ្ឌាបសុតស្ស ភាវោ> ខិឌ្ឌាបសុតតា** ។

**ខិត្ត** គុ. [ ខិប+ត ] គឺ...បោះទៅហើយ, -ចោលទៅហើយ, -គ្រវែងទៅហើយ, -បាញ់ទៅហើយ ។ - **កាល** ចុំ. កាលនៃ...គឺ...បោះទៅហើយ,... ។

**ខិប** កិ. [ ខិប+អ+ហិ-ប., លុបហិ ] ចូរបោះទៅ, ចូរចោលទៅ, ចូរគ្រវែងទៅ ។

**ខិបតិ** កិ. [ ខិប+អ+តិ-វ. ] បោះទៅ, ចោលទៅ, គ្រវែងទៅ ។

**ខិបតុ** កិ. [ ខិប+អ+តុ-ប. ] ចូរបោះទៅ,... ។

**ខិបន្ត** គុ. [ ខិប+អ+អន្ត ] កាលបោះទៅ,... ។

**ខិបមាន** គុ. [ ខិប+អ+មាន ] កាលបោះទៅ ។

**ខិបាបេសិ** កិ. [ ខិប+ណាបេ+ឦ-អជ្ជ.ចុះស-អា. ] ញុំាង...ឱ្យបោះទៅហើយ, -ឱ្យគ្រវែងទៅហើយ ។

**ខិបិ** កិ. [ ខិប+អ+ឦ-អជ្ជ. ] បោះទៅហើយ, ផ្ដាត់ទៅហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# ខិ

**ខិបិត** គុ. [ ខិប+ឥ_អា.+ត ] គឺ...កណ្ដាស់ហើយ, គឺ...បោះទៅហើយ ។ . **កាសាទិ** គុ. មានរោគកណ្ដាស់ និងរោគក្អកជាដើម ។ . **រោគ** ចុំ. រោគកណ្ដាស់, រោគគឺកិ.កណ្ដាស់ ។ . **សទ្ទ** ចុំ. សំឡេងកណ្ដាស់, ស្នូរគឺកិ.កណ្ដាស់, ស្នូរនៃកិ.កណ្ដាស់, ស្នូរគឺ...បោះទៅហើយ ។

**ខិបិតុំ** អ. [ ខិប+ឥ_អា.+តុំ ] ដើម្បីបោះទៅ, វីកិ.បោះទៅ ។

**ខិបិត្វា** អ. [ ខិប+ឥ_អា.+ត្វា ] កណ្ដាស់ហើយ, បោះទៅហើយ ។

**ខិបិយមាន** គុ. [ ខិប+ឥ_អា.+យ+មាន ] គឺ...កាលបោះទៅ ។

**ខិបឹសុ** កិ. [ ខិប+អ+ឧំ_អជ្ជ. ] បោះទៅហើយ ។

**ខិបេយ្យំ** កិ. [ ខិប+អ+ឯយ្យំ_ស. ] គប្បីបោះទៅ ។

**ខិប្បតរ** គុ. [ ខិប្ប+តរ ] ឆាប់ជាង, រហ័សជាង ។

**ខិប្បំ** កិ.វិ. ឆាប់, ឆាប់ៗ, ប្រញាប់, រហ័ស, រួសរាន់, ទាន់ហាន់ ។

**ខិប្បាភិញ្ញាណ** គុ. [ ខិប្ប+អភិញ្ញាណ ] អ្នកមានអភិញ្ញាណដ៏ឆាប់, អ្នកមានគុណជាតជាគ្រឿងដឹងចំពោះដ៏រហ័ស ។

**ខីណ** គុ. [ ខិ+ត, ត>ឦណ ] អស់ហើយ ។ . **ត្ត** នចុំ. ភាវៈនៃ...ជា...អស់ហើយ ។ . **តា** ឥ. ភាវៈនៃ...ជា...អស់ហើយ ។ . **បត្ត** គុ. មានស្លាបអស់ហើយ ។ . **បាថេយ្យ** គុ. មានវត្ថុជាប្រយោជន៍ក្នុងផ្លូវអស់ហើយ, មានស្បៀងអស់ហើយ; វិ. **ចុះថេ ហិតំ> បាថេយ្យំ, ខីណំ បាថេយ្យំ យេសំ តេ> ខីណបាថេយ្យា**

Websites: WatKhemaraRatanaram.org or WatKhmers.org

ថេយ្យា ។ - ភាវ ចុំ. ភាវៈនៃ...ជា...អស់ហើយ ។ - មច្ឆ គុ. មានត្រីអស់ហើយ ។ - សំយោជន គុ. អ្នកមានសំយោជនៈអស់ហើយ, អ្នមានធម៌ជាគ្រឿងញ៉ាំងសត្វឱ្យប្រកបព្រមអស់ហើយ ។

**ខីណាសវ** គុ., ចុំ. [ ខីណ+អាសវ ] អ្នកមានអាសវៈអស់ហើយ, ព្រះខីណាស្រព ។ - ឧសភ ចុំ. ព្រះខីណាស្រពដូចជាគោឧសភ, ព្រះខីណាស្រពអ្នកប្រសើរ, ព្រះខីណាស្រពអ្នកអង់អាច ។ - ព្រាហ្មណ ចុំ. ព្រាហ្មណ៍ជាព្រះខីណាស្រព, ព្រាហ្មណ៍មានអាសវៈអស់ហើយ ។ - ភាវ ចុំ. ភាវៈនៃ...ជាអ្នកមានអាសវៈអស់ហើយ ។ - សហស្ស នចុំ. ពាន់នៃព្រះខីណាស្រព ។ - សាមណេរ ចុំ. សាមណេរជាព្រះខីណាស្រព ។ - សីស នចុំ. សីសៈ (ក្បាល) នៃព្រះខីណាស្រព ។

**ខីយតិ** កិ. [ ខិ+ណ្យ+តិ_វ. ] អស់, អស់ទៅ ។

**ខីយន្ត** គុ. [ ខី+អ+អន្ត, ផ្លាស់ ណ្យនៃធាតុជា ណ្យ ] កាលតិះដៀល ។

**ខីយមាន** គុ. [ ខី+ណ+មាន ] កាលតិះដៀល ។

**ខីយមាន** គុ. [ ខិ+ណ្យ ឬណយ+មាន ] កាលអស់ទៅ, កាលឱ្យអស់ទៅ ។

**ខីយិត្វា** អ. [ ខី+ឥ_អា.+ត្វា ] តិះដៀលហើយ ។

**ខីយេ** កិ. [ ខិ+ណ្យ+ឯយ្យ_ស. ] គប្បីអស់ទៅ ។

ចុន្តិ៍ តប្តតិ ឯត្ថ កុសលាកុសលន្តិ> ទេហោ ។ -និស្សិត គុ. អាស្រ័យហើយក្នុងកាយ, -នូវរាងកាយ ។

**ទេហិ** កិ. [ ទា+អ+ហិ-ប. ] ចូរឱ្យ ។

**ទោណមាបក** ចុំ. [ ទោណ+មា+ណាបេ+ណ្វុ ] អ្នកវាល់ដោយទោណៈ; វិ. ទោណេន មាបេតីតិ> ទោណមាបកោ ។

**ទោមនស្ស** នចុំ. [ ទុម្មន+ណ្យ ] ភាវៈនៃបុគ្គលមានចិត្តតឹទោសប្រទូស្ត ហើយ, ភាវៈនៃ...មានចិត្តអាក្រក់, -មានចិត្តអាក់អន់ (ទោមនស្ស, សេចក្តីទោមនស្ស); វិ. ទុដ្ឋោ មនោ យស្ស សោ> ទុម្មនោ; ទុដ្ឋុ ចា មនោ យស្ស សោ> ទុម្មនោ; ទុម្មនស្ស ភាវោ> ទោមនស្សំ ។ -ប្បត្ត គុ. អ្នកដល់ហើយនូវទោមនស្ស, អ្នកមានទោមនស្សដល់ហើយ ។ -មត្ត គុ. ត្រាន់តែ ឬត្រឹមតែទោមនស្ស ។ -វូបសមនត្ថ ចុំ. ដើម្បីប្រយោជន៍ដល់កិរិយាចូលទៅរម្ងាប់នូវទោមនស្ស ។ -សហគត គុ. ទៅមួយអន្លើដោយទោមនស្ស, ប្រព្រឹត្តទៅមួយអន្លើដោយទោមនស្ស, ប្រកបដោយទោមនស្ស ។

**ទោវារិក** គុ. [ ទ្វារ+ណិក ] (ជន) អ្នកប្រកបក្នុងទ្វារ; វិ. ទ្វារេ និយុត្តោ> ទោវារិកោ ។ -អ្នករក្សានូវទ្វារ (អ្នកចាំទ្វារ); វិ. ទ្វារំ រក្ខតីតិ> ទោវារិកោ ។ -បុត្ត ចុំ. កូននៃជនអ្នកប្រកបក្នុងទ្វារ ឬអ្នករក្សានូវទ្វារ ។

**ទោស** ចុំ. [ ទុស+ណ ] សេចក្តីប្រទូស្ត, កិ.ប្រទូស្ត (ទោសៈ); វិ. ទុស្សនំ> ទោសោ ។ (សភាវៈ) ដែលប្រទូស្តក្នុងអារម្មណ៍;

Websites: WatKhemaraRatanaram.org or WatKhmers.org

**វិ. អារម្មណេ ទុស្សតីតិ> ទោសោ** ។ - **កលិ** ចុំ. ទោសគឺទោសះ, សេចក្ដីអាក្រក់គឺទោសះ ។ - **គហ** ចុំ. កិ.ចាប់នៃទោសះ, អ្នកចាប់គឺទោសះ ។ - **ទុដ្ឋ** គុ. អ្នកគឺទោសះប្រទូស្ដហើយ ។ - **និស្សិត** គុ. អ្នកអាស្រ័យនូវទោសះ, អ្នកគឺទោសះអាស្រ័យហើយ ។ - **អន្តរ** គុ. មានក្នុងចន្លោះនៃទោសះ, មានក្នុងរវាងនៃទោសះ, មានទោសះជាចន្លោះ, មានទោសះជាហេតុ, មានទោសះជាខាងក្នុង ។ - **មហន្តតា** ឥ. ភាវៈនៃ...នោះជាអ្នកមានទោសះដ៏ធំ; វិ. **ទោសោ មហន្តោ យស្ស សោ> ទោសមហន្តោ; ទោសមហន្តស្ស ភាវោ> ទោស-មហន្តតា** ។ - **មោហមានាទិ** គុ. មានទោសះ និងមោហៈនិងមានះជាដើម ។ - **សម** គុ. ស្មើដោយទោសះ ។ - **សោធ-និក** ចុំ. ប្រយោជន៍ដល់កិ.ជំរះនូវទោសះ, -កិ.សំអាតនូវទោសះ ។

**ទោសាភាវ** ចុំ. [ ទោស+អភាវ ] កិ.មិនមាននៃទោសះ ។

**ទោហឡ** ចុំ. [ ទ្វិ>ទោ+ហទយ, ហទយ>ហឡ ] សេចក្ដីប្រាថ្នាដ៏វិសេស, សេចក្ដីប្រាថ្នាដ៏ប្លែក, ចំណង់ដ៏ប្លែក (អ. សុ.) ។ បើតាមរូបសព្ទនេះប្រែថា «ហឫទ័យពីរ» ។ ចូរមើលភាគ១ ។

**ទោហឡិនី** ឥ. [ ទោហឡ+ឡ+ឥនី ] អ្នកមានសេចក្ដីប្រាថ្នាដ៏ប្លែក; **វិ. ទោហឡោ យស្សា អត្ថីតិ> ទោហឡិនី** ។

**ទ្វត្តឹស** ប.សំ. [ ទ្វិ+តឹស ] សាមសិបដ៏លើសដោយពីរ (៣២); វិ. **ទ្វីហិ អធិកា តឹស> ទ្វត្តឹស** ។ - **មហាបុរិសលក្ខណ-បដិមណ្ឌិត** គុ. ប្រដាប់ចំពោះហើយដោយលក្ខណៈនៃមហា

Websites: WatKhemaraRatanaram.org or WatKhmers.org

បុរស ៣២ ។ - **យុគ** នបុំ. គូនៃសំពត់សាដក ៣២ ។ - **យុគ-លទ្ធកាល** បុំ. កាលនៃគូនៃសំពត់សាដក ៣២ គឺខ្លួនបានហើយ, កាលនៃខ្លួនមានគូនៃសំពត់សាដក ៣២ បានហើយ ។ - **សុណិ-សា** ឥ. កូនប្រុសស្រី ៣២ នាក់ ។

**ទ្វត្តិំសាការ** បុំ. [ ទ្វត្តិំស+អាការ ] អាការៈ ៣២ ។ - **កម្មដ្ឋាន** នបុំ. កម្មដ្ឋានមានអាការៈ ៣២ ជាអារម្មណ៍, កម្មដ្ឋានគឺបណ្ឌិតកំណត់ហើយដោយអាការៈ ៣២ ។ - **បរិបូរ** តុ. ពេញជុំវិញដោយអាការៈ៣២, បរិបូរដោយ... ។ - **វំស** បុំ. អំណាចនៃអាការៈ ៣២ ។ - **សជ្ឈាយ** បុំ. កិ.ស្វាធ្យាយនូវអាការៈ ៣២ ។

**ទ្វយ** នបុំ. [ ទ្វិ+ណ ] ប្រជុំនៃពីរ, ប្រជុំនៃ...ពីរ (ទាំងពីរ); វិ. ទ្វិន្នំ សមូហោ> ទ្វយំ ។

**ទ្វាទស** ប.សំ. [ ទ្វិ+ទស ] ដប់ដ៏លើសដោយពីរ(១២); វិ. ទ្វីហិ អធិកា ទស> ទ្វាទស ។ - **នហុតបុរិស** បុំ. បុរសមាននហុត ១២ ជាប្រមាណ, បុរសមានម៉ឺន១២ជាប្រមាណ (១២ម៉ឺន) ។ - **នហុត** នបុំ. មានម៉ឺន១២ ជាប្រមាណ ។ - **មា-សិក** តុ. (កាល) ប្រកបដោយខែ ១២, មានខែ១២ជាប្រមាណ ។ - **យោជនដ្ឋាន** នបុំ. ទីមានយោជន៍១២ជាប្រមាណ ។ - **យោជនិក** តុ. ប្រកបដោយយោជន៍១២, មានយោជន៍១២ជាប្រមាណ ។ - **វស្ស** នបុំ. ឆ្នាំ ១២ ។ - **ហត្ថ** តុ. មានហត្ថ១២ជាប្រមាណ ។ - **អាយតន** នបុំ. អាយតនៈ១២ ។

**ទ្វាទសម** បូ. សំ. [ ទ្វាទស+ម ] ទី១២, គំរប់១២, ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្វារ នថុំ. [ ទ្វរ+អ ] (វត្ថុ ឬសន្ទះ) ជាគ្រឿងបិទ (ទ្វារ); វិ. ទ្វារតិ សំវរតិ ឯតេនាតិ> ទ្វារំ ។ ម្យ៉ាងទៀត ទ្វារ<ទ្វិ+អរ+អ = ទីជាទីប្រព្រឹត្តទៅនៃសន្ទះទាំងពីរ; វិ. ទ្វេ កវាដានិ អរន្ត្យ-ត្រេតិ> ទ្វារំ ។ . កោដ្ឋក ថុំ. ស៊ុមនៃទ្វារ, ស៊ុមជិត ទ្វារ, ខ្លោងនៃទ្វារ ។ . កោដ្ឋកាភិមុខ គុ. អ្នកមានមុខឆ្ពោះទៅកាន់ស៊ុមនៃទ្វារ ។ . អដ្ដាលកយុត្ត គុ. ប្រកបដោយទ្វារនិងប៉ម ។ . អន្តរ នថុំ. ចន្លោះនៃទ្វារ, ខាងក្នុងនៃទ្វារ ។ . បាការាទិ គុ. (ទី) មានទ្វារនិងកំពែងជាដើម ។ . បាល ថុំ. អ្នករក្សានូវទ្វារ (នាយទ្វារ); វិ. ទ្វារំ បាលេតីតិ> ទ្វារបាលោ ។ . ពាហ មេនៃទ្វារ ។ . មជ្ឈ នថុំ. កណ្តាលនៃទ្វារ ។ . រក្ខិត គុ. មានទ្វាររក្សាហើយ, រក្សាហើយនូវទ្វារ ។ . សមីប គុ. ជិតនៃទ្វារ ។ . សម្មុខ នថុំ. ទីចំមុខនៃទ្វារ, ទីប្រទល់មុខនៃទ្វារ ។ . សហស្សយុត្ត គុ. ប្រកបដោយពាន់នៃ ទ្វារ ។

ទ្វារាភិមុខ គុ. [ ទ្វារ+អភិមុខ ] មានមុខឆ្ពោះទៅកាន់ទ្វារ, មានមុខបែរទៅកាន់ទ្វារ, មានមុខសំដៅទៅកាន់ទ្វារ ។

ទ្វាវីសតិម បូ.សំ. [ ទ្វាវីសតិ+ម ] ទី២២, គំរប់២២ ។

ទ្វាសដ្ឋី ប.សំ. [ ទ្វិ+សដ្ឋី ] ហុកសិបពីរលែងដោយពីរ (៦២); វិ. ទ្វីហិ អធិកា សដ្ឋី> ទ្វាសដ្ឋី ។ . ទិដ្ឋិគតមគ្គ ថុំ. ផ្លូវគឺទិដ្ឋិ៦២ ។

ទ្វាសត្តតិ ប. សំ. [ ទ្វិ+សត្តតិ ] ចិតសិបពីរលើសដោយពីរ (៧២) ។ . ប្បមាណ គុ. មានប្រមាណ ៧២, មាន ៧២ ជាប្រមាណ ។ . ភាណវារប្បមាណ គុ. មានភាណវារៈ ៧២ ជាប្រមាណ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ទ្វិតាលមត្ត** គុ. [ ទ្វិ+តាល+មត្ត ] មានដើមត្នោតពីរជាប្រមាណ ។

**ទ្វិតា** ឥ. [ ទ្វិ+តា ] ភាវៈនៃភ្នំមាសនោះជាពីរ; វិ. **ទ្វិន្នំ ភាវោ> ទ្វិតា** ។

**ទ្វិត្តិក្ខត្តុំ** អ. ឬ កិ.វិ. [ ទ្វិត្តិ+សកឹ>ទ្វិត្តិក្ខត្តុំ ] វារៈនៃពីរឬបី, វារៈពីរផងឬបីផង, វារៈពីរបីផង, ពីរបីលើក ។ មយ៉ាងទៀត ប្រព្រឹត្តទៅអស់វារៈពីរផង ឬបីផង; វិ. **ទ្វិវារេ តិវារេ វា បវត្តតីតិ> ទ្វិត្តិក្ខត្តុំ** ។

**ទ្វិធា** អ. [ ទ្វិ+ធា ] ដោយចំណែកពីរ; វិ. **ទ្វីហិ វិភាគេហិ> ទ្វិធា** ។

**ទ្វិធាភាវ** បុំ. [ ទ្វិធា+ភាវ ] ភាវៈនៃ...ដោយចំណែកពីរ, ភាវៈដោយចំណែកពីរ ។

**ទ្វិន្នំ** ប.សំ. [ ទ្វិ+នំ_វិ.>ទ្វិន្នំ ] ពីរ, ទាំងពីរ ។

**ទ្វិបទ** គុ. [ ទ្វិ+បទ ] (សត្វ) មានជើងពីរ; វិ. **ទ្វេ បទានិ យេសំ តេ> ទ្វិបទា** ។ - **ចតុប្បទ** គុ. (សត្វ) ទាំងមានជើងពីរទាំងមានជើងបួន ។

**ទ្វិភូមិក** គុ. [ ទ្វិ+ភូមិ+ក ] មានជាន់ពីរ, មានថ្នាក់ពីរ, (ពីរជាន់ ឬពីរថ្នាក់); វិ. **ទ្វេ ភូមិយោ យស្ស តំ> ទ្វិភូមិកំ** ។ **ទ្វិភូមិក** <ទ្វិភូមិ+ណិក = ប្រកបដោយជាន់ពីរ; វិ. **ទ្វិភូមិយា និយុត្តំ> ទ្វិភូមិកំ** ។

**ទ្វិយោជន** នបុំ. [ ទ្វិ+យោជន ] យោជន៍ពីរ (ពីរយោជន៍) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ទ្វីហ** នបុំ. [ ទ្វិ+អហ ] ថ្ងៃពីរ (ពីរថ្ងៃ); រី. **ទ្វេ អហានិ**> **ទ្វីហំ** ។

**ទ្វីហតីហ** នបុំ. [ ទ្វីហ+តីហ ] ថ្ងៃពីរនិងថ្ងៃបី ។ - **អច្ចយ** បុំ. កាលជាទីប្រព្រឹត្តកន្លងទៅនៃថ្ងៃពីរនិងថ្ងៃបី ។

**ទ្វេ** ប.សំ. [ ទ្វិ+យោ.រី.>ទ្វេ ] ពីរ, ទាំងពីរ ។ - **អសីតិកោដិធន** នបុំ. ទ្រព្យមានកោដិប៉ែតសិបពីរជាប្រមាណ, ទ្រព្យគឺបុគ្គលរាប់ដោយកោដិប៉ែតសិបពីរ ។ - **អសីតិញាតិកុលសហស្ស** នបុំ. ពាន់នៃត្រកូលនៃញាតិប៉ែតសិបពីរ, ពាន់នៃត្រកូលជាញាតិប៉ែតសិបពីរ ។ - **កោដិមត្ត** គុ. មានកោដិពីរជាប្រមាណ, មានប្រមាណពីរកោដិ ។ - **នវុតិកប្ប** បុំ. កប្បកៅសិបពីរ ។ - **ភូមិក** គុ. <ទ្វិភូមិ+ណិក = ប្រកបដោយជាន់ពីរ ។ - **មាសច្ចយ** បុំ. កាលជាទីប្រព្រឹត្តកន្លងទៅនៃខែពីរ ។ - **សហាយកភិក្ខុវត្ថុ** នបុំ. រឿងនៃភិក្ខុជាសំឡាញ់នឹងគ្នាពីររូប ។

**ទ្វេធា** អ. [ ទ្វេ+ធា ] ដោយចំណែកពីរ (ចូរមើល ទ្វិធា) ។

**ទ្វេធាបថ** បុំ. [ ទ្វេធា+បថ ] ផ្លូវដោយចំណែកពីរ, ផ្លូវពីរចំណែក, ផ្លូវបែកជាពីរ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធជ** ចុំ. [ ធជ+អ ] ទង់, ទង់ជ័យ ។

**ធជបដាក** នចុំ. [ ធជ+បដាក ] ទង់និងទង់ផ្ទាំងសំពត់, ទង់ជ័យនិងទង់បដាក, ទង់ជ័យនិងទង់គឺបុគ្គលធ្វើដោយផ្ទាំងសំពត់ ។ . **កទលិ** ចុំ. ទង់ជ័យ និងទង់ផ្ទាំងសំពត់ និងដើមចេក ។ . **កទលិអាទិ** គុ. (វត្ថុ) មានទង់ជ័យ និងទង់ផ្ទាំងសំពត់ និងដើមចេកជាដើម ។ . **ឆត្តាតិឆត្តាទិ** គុ. (គ្រឿងអលង្ការ) មានទង់ជ័យ និងទង់ផ្ទាំងសំពត់ និងឆ័ត្រដ៏កន្លងនូវឆ័ត្រជាដើម ។

**ធជភូត** គុ. [ ធជ+ភូត ] ជាទង់កើតហើយ, ដូចជាទង់កើតហើយ ។

**ធញ្ញបិដក** នចុំ. [ ធញ្ញ+បិដក ] ល្អីដ៏ពេញដោយស្រូវ, កញ្ជើដ៏ពេញដោយស្រូវ ។

**ធន** នចុំ. [ ធន+អ ] ទ្រព្យ ឧ. **មម យិធន្តិ ធនាយិកញ្ចំ សទ្ធាយិកព្វន្តិ> ធនំ** = វត្ថុគឺបុគ្គលគប្បីពោលថា «នេះរបស់អញ») ។

**ធនករណីយ** គុ. [ ធន+ករ+អនីយ ] (កិច្ច) គឺបុគ្គលគប្បីធ្វើដោយទ្រព្យ; ឧ. **ធនេន កត្តព្វន្តិ> ធនករណីយំ** ។

**ធនការណ** នចុំ. [ ធន+ការណ ] ហេតុនៃទ្រព្យ ។

**ធនក្កីតាទិ** គុ. [ ធនក្កីត+អាទិ ] មានទាសៈ (ខ្ញុំ) គឺបុគ្គលទិញហើយដោយទ្រព្យជាដើម, មានខ្ញុំគឺបុគ្គលលោះដោយទ្រព្យជាដើម ។

**ធនក្ខយ** ចុំ. [ ធន+ខយ ] កិ.អស់ទៅនៃទ្រព្យ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធនគព្ភទ្វារ** នបុំ. [ ធន+គព្ភ+ទ្វារ ] ទ្វារនៃបន្ទប់ជាទីទុកនូវទ្រព្យ, ទ្វារនៃបន្ទប់ជាទីដាក់នៃទ្រព្យ, ទ្វារនៃ បន្ទប់ដ៏ពេញដោយទ្រព្យ ។

**ធនច្ឆេទភយ** នបុំ. [ ធន+ឆេទ+ភយ ] កិ.ខ្លាចអំពីសេចក្ដីដាច់នៃទ្រព្យ, ភ័យអំពីការដាច់បង់នៃទ្រព្យ ។

**ធនញ្ជយសេដ្ឋី** បុំ. [ ធនញ្ជយ+សេដ្ឋី ] សេដ្ឋីឈ្មោះធនញ្ជយៈ ។

**ធនញ្ជានិ** អ.ន. ឈ្មោះធនញ្ជានិ ។

**ធនដ្ឋាន** នបុំ. [ ធន+ឋាន ] ទីជាទីតាំងនៃទ្រព្យ, ទីជាទីទុកនូវទ្រព្យ; វិ. **ធនានំ ឋានំ> ធនដ្ឋានំ** ។

**ធនតណ្ហា** ឥ. [ ធន+តណ្ហា ] សេចក្ដីប្រាថ្នាក្នុងទ្រព្យ; .នូវទ្រព្យ, ចំណង់ក្នុងទ្រព្យ ។

**ធនទាន** នបុំ. [ ធន+ទាន ] កិ.ឱ្យនូវទ្រព្យ ។

**ធនធញ្ញបុត្តទារាទិ** គុ. [ ធនធញ្ញបុត្តទារ+អាទិ ] (សត្វនិងសង្ខារ) មានទ្រព្យ និងស្រូវ និងកូន និងប្រពន្ធជាដើម; វិ. **ធនំ ច ធញ្ញំ ច បុត្តោ ច ទារា ច> ធនធញ្ញបុត្តទារា ; ធនធញ្ញបុត្តទារា អាទយោ យេសំ តេ> ធនធញ្ញបុត្តទារាទយោ** ។

**ធនធញ្ញាទិក** គុ. [ ធនធញ្ញ+អាទិ+ក ] មានទ្រព្យនិងស្រូវជាដើម ។

**ធននិស្សិត** គុ. [ ធន+និស្សិត ] អាស្រ័យហើយនូវទ្រព្យ ។

**ធនបារិជុញ្ញកាល** បុំ. [ ធន+បារិជុញ្ញ+កាល ] កាលនៃ...មានភាវៈនៃសេចក្ដីសូន្យនៃទ្រព្យ ។ **បារិជុញ្ញ**<បរិជិន+ណ្យ = វិ. **ឋរ.**

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱនស្ស ភាសោ> បារិជុញ្ញុំ ។

**ធនបាលក** ពុំ. [ ធន+បាល+ណ្វុ ] ឈ្មោះធនបាលកៈ (អ្នករក្សានូវទ្រព្យ) ។

**ធនបាល** ពុំ. [ ធន+បាល+អ ] ដំរីឈ្មោះធនបាល (អ្នករក្សានូវទ្រព្យ) ។

**ធនរាសិ** ពុំ. [ ធន+រាសិ ] គំនរនៃទ្រព្យ ។

**ធនលាភ** ពុំ. [ ធន+លភ+ណ ] កិ.បាននូវទ្រព្យ ។

**ធនលោភ** ពុំ. [ ធន+លុភ+ណ ] សេចក្ដីលោភក្នុងទ្រព្យ, ការជាប់ជំពាក់ក្នុងទ្រព្យ, .ដោយទ្រព្យ ។

**ធនសារ** ពុំ. [ ធន+សារ ] ទ្រព្យជាសារៈ, ទ្រព្យជាខ្លឹម, ទ្រព្យមានខ្លឹម ។

**ធនសេដ្ឋី** ពុំ. [ ធន+សេដ្ឋី ] សេដ្ឋីមានទ្រព្យ ។

**ធនសេដ្ឋីកុល** នពុំ. [ ធនសេដ្ឋី+កុល ] ត្រកូលនៃសេដ្ឋីអ្នកមានទ្រព្យ ។

**ធនហរណ** នពុំ. [ ធន+ហរ+យុ ] កិ.នាំទៅនូវទ្រព្យ ។

**ធនហានិភយ** នពុំ. [ ធនហានិ+ភយ ] កិ. ខ្លាចអំពីសេចក្ដីសាបសូន្យនៃទ្រព្យ, ភ័យអំពីសេចក្ដីសាបសូន្យនៃទ្រព្យ ។

**ធនាហរណត្ថ** ពុំ. [ ធន+អាហរណ+អត្ថ ] ប្រយោជន៍ដល់កិ.នាំមកនូវទ្រព្យ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធន្វាទិ** គុ. [ ធនុ+អាទិ ] (អាវុធ) មានធ្នូជាដើម ។

**ធមនិសន្ថតគត្ត** គុ. [ ធមនិ+សន្ថត+គត្ត ] អ្នកមានខ្លួនដេរដាសដោយសរសៃ, អ្នកមានខ្លួនរវាមដោយសរសៃ ។

**ធមនិសន្ថត** គុ. [ ធមនិ+សំ+ថរ+ត ] ដេរដាសដោយសរសៃ, រវាមដោយសរសៃ ។

**ធម្មកថា** ឥ. [ ធម្ម+កថ+អ+អា.ឥ. ] ធម្មកថា, វាចាជាគ្រឿងពោលនូវធម៌, សំដែងនូវធម៌; វិ. **ធម្មំ កថេតិ ឯតាយាតិ> ធម្ម-កថា** ។

**ធម្មកថាវសាន** នបុំ. [ ធម្មកថា+អវសាន ] ទីបំផុតនៃធម្មកថា, កាលជាទីបំផុតនៃ..., កាលជាទីចប់នៃ...។

**ធម្មកថិក** បុំ. [ ធម្ម+កថ+ឥក ] អ្នកសំដែងនូវធម៌; វិ. **ធម្មំ កថេ-តីតិ> ធម្មកថិកោ** ។ . **បេម្ម** នបុំ. សេចក្តីស្រឡាញ់ក្នុងភិក្ខុជាធម្មកថិក ។ . **ភាវ** បុំ. ភាវៈនៃ....នោះជាធម្មកថិក ។

**ធម្មករក** [ ធម្ម+ករក ] ធម្មក្រក ។ . **មណ្ឌន** នបុំ. កិ.ប្រដាប់នូវធម្មក្រក ។

**ធម្ម** បុំ. [ ធរ+រម្ម ] (សភាវៈ) ទ្រទ្រង់នៃសត្វ ឬ (សភាវៈ) ជាហេតុទ្រទ្រង់នៃសត្វ(ធម៌); វិ. **ធារេតីតិ> ធម្មោ; ធារេតិ តេនា-តិ វា> ធម្មោ** ។

**ធម្មគត** គុ. [ ធម្ម+គត ] ទៅហើយក្នុងធម៌, តាំងនៅក្នុងធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធម្មគម្ពីរតាបច្ចវេក្ខណ** នថុំ. [ ធម្មគម្ពីរតា+បច្ចវេក្ខណ ] កិ.ពិចារណានូវភារៈនៃធម៌ដ៏ជ្រាលជ្រៅ ។ ធម្មគម្ភីរតា<ធម្មគម្ពីរ+តា =វិ. **ធម្មោ គម្ភីរោ> ធម្មគម្ភីរោ; គស្ស ភាវោ> ធម្មគម្ភីរតា** ។

**ធម្មគរុក** គុ. [ ធម្ម+គរុ+ក.ស. ] អ្នកគោរពក្នុងធម៌, អ្នកធ្ងន់ក្នុងធម៌ ។

**ធម្មគារវ** ចុំ. [ ធម្ម+គារវ ] ភាវៈនៃសេចក្ដីគោរពក្នុងធម៌, សេចក្ដីគោរពក្នុងធម៌ ។

**ធម្មគុណ** ចុំ. [ ធម្ម+គុណ ] គុណធម៌, គុណនៃធម៌ ។

**ធម្មគុត្ត** គុ. [ ធម្ម+គុប+ត ] អ្នកគ្រប់គ្រងនូវធម៌; វិ. **ធម្មេន គោបេតីតិ> ធម្មគុត្តោ** ។

**ធម្មឃោសក** ចុំ. [ ធម្ម+ឃុស+ណ្វុ ] សំឡេងដ៏គឹកកងដោយធម៌ ឬអ្នកញ៉ាំងសំឡេងឱ្យគឹកកងដោយធម៌; វិ. **ធម្មេន ឃោសេតីតិ> ធម្មឃោសកោ** ។ - **កម្ម** នថុំ. កម្មនៃបុគ្គលអ្នកញ៉ាំងសំឡេងឱ្យគឹកកងដោយធម៌ ។

**ធម្មឃោស** ចុំ. [ ធម្ម+ឃុស+ណ ] សំឡេងដ៏គឹកកងដោយធម៌ ។

**ធម្មចក្ក** នថុំ. [ ធម្ម+ចក្ក ] ចក្រគឺធម៌, ឬធម៌ដូចជាចក្រ; វិ. **ធម្មោ ឯវ ចក្កំ> ធម្មចក្កំ; ធម្មោ ចក្កំ ឥវ ចា> ធម្មចក្កំ** ។ - **បវត្តន** នថុំ. កិ.ញ៉ាំងចក្រគឺធម៌ឱ្យប្រព្រឹត្តទៅ ។

**ធម្មចរិយា** ឥ. [ ធម្ម+ចរ+ណ្យ+ឥ.អា. ] កិ.ប្រព្រឹត្តិនូវធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធម្មចារី** ពុ. [ ធម្ម+ចរ+ណី ] អ្នកប្រព្រឹត្តនូវធម៌; វិ. **ធម្មំ ចរតីតិ> ធម្មចារី** ។ អ្នកប្រព្រឹត្តនូវធម៌ដោយប្រក្រតី; វិ. **ធម្មំ ចរតិ សីលេនាតិ> ធម្មចារី** ។ អ្នកមានកិ.ប្រព្រឹត្តិនូវធម៌ជាប្រក្រតី; វិ. **ធម្មំ ចរិតុំ សីលមស្សាតិ> ធម្មចារី** ។ ឥ. **ធម្មចារិនី** ។

**ធម្មចេតិយសុត្តនិយាម** ពុ. [ ធម្មចេតិយសុត្ត+និយាម ] ទំនងនៃធម្មចេតិយសូត្រ, និយាមៈ (លំអាន) នៃ... ។

**ធម្មជីវិត** នពុ. [ ធម្ម+ជីវិត ] កិ.រស់នៅដោយធម៌, រស់នៅដោយធម៌ ។

**ធម្មជីវី** ពុ. [ ធម្ម+ជីវ+ណី ] អ្នករស់នៅដោយធម៌, អ្នកមានកិ.រស់នៅដោយធម៌ជាប្រក្រតី; វិ. **ធម្មេន ជីវតីតិ> ធម្មជីវី; ធម្មេន ជីវិតុំ សីលមស្សាតិ> ធម្មជីវី** ។

**ធម្មដ្ឋ** ពុ. [ ធម្ម+ឋា+អ ] អ្នកឋិតនៅក្នុងធម៌, អ្នកតាំងនៅក្នុងធម៌; វិ. **ធម្មេ តិដ្ឋតីតិ> ធម្មដ្ឋោ** ។

**ធម្មដ្ឋវត្តវណ្ណនា** ឥ. [ ធម្មដ្ឋវត្ត+វណ្ណ+យុ+អា_ឥ. ] កថាជាគ្រឿងពណ៌នានូវធម្មដ្ឋវត្ត, នូវសេចក្ដីនៃធម្មដ្ឋវត្ត; វិ. **ធម្មដ្ឋវត្តំ វណ្ណេន្តិ ឯតាយាតិ> ធម្មដ្ឋវត្តវណ្ណនា; ធម្មដ្ឋវត្តស្ស អត្ថំ វណ្ណេន្តិ ឯតាយាតិ> ធម្មដ្ឋវត្តវណ្ណនា** ។

**ធម្មតណ្ហា** ឥ. [ ធម្ម+តណ្ហា ] សេចក្ដីប្រាថ្នាក្នុងធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធម្មតា** ន. [ ធម្ម+តា.ស. ] ជាធម្មតា, ជាទំនៀម (**ធម្មោ ឯវ ធម្មតា**) ។

**ធម្មតេជ** ចុំ. [ ធម្ម+តេជ ] តេជះនៃធម៌ ។

**ធម្មទស្សី** ចុំ. [ ធម្ម+ទិស+ណី ] អ្នកមានកិ.ឃើញនូវធម៌ជាប្រក្រតី (ព្រះពុទ្ធព្រះនាមធម្មទស្សី); វិ. **ធម្មំ បស្សិតុំ សីលមស្សាតិ> ធម្មទស្សី** ។

**ធម្មទាន** នចុំ. [ ធម្ម+ទាន ] ធម្មទាន, កិ.ឱ្យនូវធម៌ ។

**ធម្មទិន្នា** អ.ន ឈ្មោះធម្មទិន្នា ។

**ធម្មទិន្នាថេរី** ឥ. [ ធម្មទិន្នា+ថេរី ] ព្រះថេរីឈ្មោះធម្មទិន្នា, ធម្មទិន្នា-ថេរី ។

**ធម្មទេសក** ចុំ. [ ធម្ម+ទិស+ណ្វុ ] អ្នកសំដែងនូវធម៌; វិ. **ធម្មំ ទេសេតីតិ> ធម្មទេសកោ** ។

**ធម្មទេសនា** ឥ. [ ធម្ម+ទិស+យុ+អា.ឥ. ] កិ.សំដែងនូវធម៌; វិ. **ទេសិយតេ> ទេសនា; ធម្មស្ស ទេសនា> ធម្មទេស-នា** ។ វាចាជាគ្រឿងសំដែងនូវធម៌; វិ. **ធម្មំ ទេសេតិ ឯតាយាតិ> ធម្មទេសនា** ។ - **ឃោស** ចុំ. សំឡេងគឹកកងនៃធម្មទេសនា ។

**ធម្មទេសនានុគត** គុ. [ ធម្មទេសនា+អនុគត ] ទៅតាមហើយនូវធម្មទេសនា, ប្រព្រឹត្តទៅតាមហើយនូវធម៌ទេសនា, ទៅតាមលំដាប់នៃ... ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធម្មធរ** គុ. [ ធម្ម+ធរ+អ ] អ្នកទ្រទ្រង់នូវធម៌, អ្នកទ្រង់ទុកនូវធម៌, អ្នកចាំនូវធម៌; វិ. **ធម្មំ ធារេតីតិ> ធម្មធរោ** ។

**ធម្មន្តេវាសិក** ចុំ. [ ធម្ម+អន្តេវាសិក ] អន្តេវាសិក (សិស្ស) ព្រោះធម៌ ។

**ធម្មប្បដិសន្ថារ** ចុំ. [ ធម្ម+បដិសន្ថារ ] វាចៈជាគ្រឿងរៀបរៀងព្រមចំពោះដោយធម៌, ការរាក់ទាក់ដោយធម៌, បដិសន្ថារៈដោយធម៌ ។ **បដិសន្ថារ**<បដិ+សំ+ថរ+ណ = ការក្រាលចំពោះដោយធម៌ ។

**ធម្មប្បដិស្សរណ** នចុំ. [ ធម្ម+បដិស្សរណ ] កិ.រលឹកចំពោះនូវធម៌, កិ.រលឹកអាស្រ័យនូវធម៌, មានធម៌ជាគ្រឿងរលឹកអាស្រ័យ ។

**ធម្មបទ** នចុំ. [ ធម្ម+បទ ] ធម្មបទ, បទនៃធម៌, ចំណែកជាគ្រឿងដល់នៃធម៌, ធម្មជាតិជាហេតុដល់នៃធម៌ ។ - **ភាណកមហាតិស្សត្ថេរ** ចុំ. ព្រះថេរៈឈ្មោះមហាតិស្សៈអ្នកពោលនូវបទនៃធម៌ ។

**ធម្មប្បាមោជ្ជ** នចុំ. [ ធម្ម+បាមោជ្ជ ] ភាវៈនៃចិត្តដែលរីករាយក្នុងធម៌; វិ. **បមុទិតស្ស ចិត្តស្ស ភាវោ> បាមោជ្ជំ; ធម្មេ បាមោជ្ជំ> ធម្មប្បាមោជ្ជំ** ។

**ធម្មបាយក** ចុំ. [ ធម្ម+បា+ណ្វុ ] អ្នកផឹកនូវធម៌ ឬអ្នកផឹកនូវរសនៃធម៌ វិ. **ធម្មំ បិវតីតិ> ធម្មបាយកោ; ធម្មស្ស រសំ បិវតីតិ> ធម្មបាយកោ** ។

**ធម្មប្បីតិ** គុ. [ ធម្ម+បីតិ ] អ្នកមានបីតិដែលកើតអំពីធម៌; វិ. **ធម្មតោ ឧប្បន្នា បីតិ យស្ស សោ> ធម្មប្បីតិ** ។ អ្នកមាន

បីតិដែលកើតដោយអំណាចនៃធម៌; វិ. **ធម្មវសេន ឧប្បន្នា បីតិ យស្ស សោ> ធម្មប្បីតិ** ។ បីតិដែលកើតអំពីធម៌; វិ. **ធម្មតោ ឧប្បន្នា បីតិ> ធម្មប្បីតិ** ។ . រស បុំ. រសនៃបីតិដែលកើតអំពីធម៌ ។

**ធម្មបុរេក្ខារតា** ឥ. [ ធម្មបុរេក្ខារ+តា ] ភាវៈនៃ...នោះជាអ្នកមានធម៌ជាគ្រឿងធ្វើក្នុងខាងមុខ; វិ. **ធម្មោ បុរេក្ខារោ យស្ស សោ> ធម្មបុរេក្ខារោ, តស្ស ភាវោ> ធម្មបុរេក្ខារ.តា** ។ **បុរេក្ខារ**<បុរេ+ករ+ណ= វិ. **បុរេ ករោតិ ឯតេនាតិ> បុរេក្ខារោ** ។

**ធម្មបូជា** ឥ. [ ធម្ម+បូជា ] កិ.បូជានូវធម៌ ។

**ធម្មប្បមាណិក** គុ. [ ធម្មប្បមាណ+ណិក ] អ្នកប្រកបដោយប្រមាណក្នុងធម៌; វិ. **ធម្មប្បមាណេន និយុត្តា> ធម្មប្បមាណិកា** ។ អ្នកមានប្រមាណក្នុងធម៌; វិ. **ធម្មប្បមាណំ យេសមត្ថីតិ> ធម្មប្បមាណិកា** ។

**ធម្មមាមក** គុ. [ ធម្ម+មម+ណ្ក ] អ្នករាប់អាននូវធម៌, អ្នកស្រឡាញ់នូវធម៌; វិ. **ធម្មំ មមេតិ មានេតីតិ> ធម្មមាមកោ** ។

**ធម្មយាគ** បុំ. [ ធម្ម+យជ+ណ ] កិ.បូជានូវធម៌; វិ. **ធម្មស្ស យជនំ> ធម្មយាគោ** ។

**ធម្មរក្ខិត** គុ. [ ធម្ម+រក្ខិត ] អ្នករក្សានូវធម៌; វិ. **ធម្មំ រក្ខតីតិ> ធម្មរក្ខិតោ** ។ អ្នកមានធម៌រក្សាហើយ; វិ. **ធម្មោ រក្ខិតោ**

Websites: WatKhemaraRatanaram.org or WatKhmers.org

**យេន សោ> ធម្មរក្ខិតោ** ។

**ធម្មរតន** នបុំ. [ ធម្ម+រតន ] ធម្មរ័ត្ន, កែវគឺធម៌, វត្ថុដ៏ញុំាងសេចក្ដីត្រេកអរឱ្យកើតគឺធម៌ ។

**ធម្មរត** គុ. [ ធម្ម+រម+ត ] អ្នកត្រេកអរក្នុងធម៌; ឧ. **ធម្មេ រមតីតិ> ធម្មរតោ** ។

**ធម្មរតិ** ឥ. [ ធម្ម+រតិ ] សេចក្ដីត្រេកអរក្នុងធម៌ ។

**ធម្មរស** ពុំ. [ ធម្ម+រស ] រសនៃធម៌ ។

**ធម្មរាជតា** ឥ. [ ធម្មរាជ+តា ] ភាវៈនៃ...នោះជាស្ដេចនៃធម៌, ភាវៈនៃ...នោះជាស្ដេចព្រោះធម៌ ។

**ធម្មរាជ** ពុំ. [ ធម្ម+រាជ ] ស្ដេចនៃធម៌, ជាស្ដេចព្រោះធម៌, ព្រះរាជាប្រកបដោយធម៌ ។

**ធម្មវាទី** ពុំ. [ ធម្ម+វទ+ណី ] អ្នកពោលនូវធម៌; ឧ. **ធម្មំ វទតីតិ> ធម្មវាទី** ។ អ្នកពោលដោយធម៌; ឧ. **ធម្មេន វទតីតិ> ធម្មវាទី** ។ អ្នកមានកិ.ពោលនូវធម៌ជាប្រក្រតី; ឧ. **ធម្មំ វទិតុំ សីលមស្សាតិ> ធម្មវាទី** ។

**ធម្មវិនយ** ពុំ. [ ធម្ម+វិនយ ] ធម៌និងវិន័យ ។

**ធម្មវិនិច្ឆយ** ពុំ. [ ធម្ម+វិនិច្ឆយ ] ការវិនិច្ឆ័យនូវធម៌, ការវិនិច្ឆ័យតាមធម៌ ។

**ធម្មសភា** ឥ. [ ធម្ម+សភា ] រោងជាទីប្រជុំនូវធម៌; ឧ. **ធម្មំ សង្គម្ម**

Websites: WatKhemaraRatanaram.org or WatKhmers.org

ភាសតិ ឯត្ថាតិ> **ធម្មសភា** ។ រោង ជា ទីពោលមួយអន្លើដោយធម៌; វិ. ធម្មេន សហ ភាសន្ត្យស្មិន្តិ> ធម្មសភា ។ សភា<ស+ភាស+ក្វិ ។

**ធម្មសម្មន្តនា** ឥ. [ ធម្ម+សំ+មន្ត+យុ+អា.ឥ. ] កិ.ប្រឹក្សាព្រមដោយធម៌, កិ.ពិភាក្សាដោយធម៌, កិ.ពិគ្រោះគ្នាដោយធម៌ ។

**ធម្មសំវេគ** បុំ. [ ធម្ម+សំវេគ ] សេចក្តីស្លុតចិត្តព្រោះធម៌, សេចក្តីតក់ស្លុតព្រោះធម៌, សេចក្តីសង្វេគព្រោះធម៌ ។ សំវេគ<សំ+វិជ+ណ ។

**ធម្មសេនាបតិ** បុំ. [ ធម្ម+សេនាបតិ ] សេនាបតីព្រោះធម៌, ជាសេនាបតិ ព្រោះធម៌ ។

**ធម្មស្សវន** នបុំ. [ ធម្ម+សុ+យុ ] កិ.ស្តាប់នូវធម៌; វិ. សុយ្យតេតិ សវនំ; ធម្មស្ស សវនំ> ធម្មស្សវនំ ។ ទីជាទីស្តាប់នូវធម៌; វិ. ធម្មំ សុណន្តិ ឯត្ថាតិ> ធម្មស្សវនំ ។

**ធម្មស្សវនកាល** បុំ. [ ធម្មស្សវន+កាល ] កាលជាទីស្តាប់នូវធម៌ ។

**ធម្មស្សវនគ្គ** នបុំ. [ ធម្មស្សវន+អគ្គ ] រោងជាទីស្តាប់នូវធម៌ ។

**ធម្មស្សវនដ្ឋាន** នបុំ. [ ធម្មស្សវន+ឋាន ] ទីជាទីស្តាប់នូវធម៌ ។

**ធម្មស្សវនត្ថ** បុំ. [ ធម្មស្សវន+អត្ថ ] ប្រយោជន៍ដល់កិ.ស្តាប់នូវធម៌, ត្រូវការដល់កិ.ស្តាប់នូវធម៌ ។

**ធម្មស្សវនទិវស** បុំ. [ ធម្មស្សវន+ទិវស ] ថ្ងៃជាទីស្តាប់នូវធម៌ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ធម្មស្សវនន្តរាយ ពុំ. [ ធម្មស្សវន+អន្តរាយ ] អន្តរាយដល់កិ.ស្តាប់នូវធម៌, .នៃកិ.ស្តាប់នូវធម៌ ។

ធម្មស្សវនយក្ខសមាគមាទិ គុ. [ ធម្មស្សវនយក្ខសមាគម+អាទិ ] (កាល) មានកាលជាទីស្តាប់នូវធម៌ និងកាលជាទីប្រជុំនៃយក្សជាដើម; (សមាគម) មានសមាគមជាទីស្តាប់នូវធម៌ និងសមាគមនៃយក្សជាដើម ។

ធម្មស្សវនវត្ថុ នពុំ. [ ធម្មស្សវន+វត្ថុ ] វត្ថុ (រឿង) នៃកិ.ស្តាប់នូវធម៌ ។

ធម្មស្សវនវេលា ឥ. [ ធម្មស្សវន+វេលា ] វេលាជាទីស្តាប់នូវធម៌ ។

ធម្មស្សវនាវសាន នពុំ. [ ធម្មស្សវន+អវសាន ] កាលជាទីបំផុតចុះនៃកិ.ស្តាប់នូវធម៌, កាលជាទីចប់នៃកិ.ស្តាប់នូវធម៌, កាលជាអវសាននៃកិ.ស្តាប់នូវធម៌ ។

ធម្មស្សាមិ ពុំ. [ ធម្ម+សាមិ ] ម្ចាស់នៃធម៌, ជាម្ចាស់នៃធម៌, ជាម្ចាស់ព្រោះធម៌ ។

ធម្មាចរិយ ពុំ. [ ធម្ម+អាចរិយ ] អាចារ្យព្រោះធម៌, អាចារ្យអ្នកបង្រៀននូវធម៌, ធម្មាចារ្យ ។

ធម្មាធម្ម ពុំ. [ ធម្ម+អធម្ម ] ធម៌និងអធម៌, ធម៌និងមិនមែនជាធម៌, ធម៌និងសភាពមិនមែនជាធម៌ ។

ធម្មានិ ឈិ.វិ. [ ធម្ម+យោ.វិ.>ធម្មានិ ] នូវធម៌ទាំងឡាយ ។

ធម្មានុធម្ម ពុំ. [ ធម្ម+អនុធម្ម ] ធម៌ដ៏ប្រព្រឹត្តទៅតាមនូវធម៌, ធម៌ដ៏

Websites: WatKhemaraRatanaram.org or WatKhmers.org

សមគួរដល់ធម៌ ។ . **ប្បដិបត្តិ** ឥ. សេចក្ដីប្រព្រឹត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។

**ធម្មានុវត្តី** ពុំ. [ ធម្ម+អនុ+វត្ត+ណី ] អ្នកប្រព្រឹត្តតាមនូវធម៌, អ្នកមានកិ.ប្រព្រឹត្តនូវធម៌ជាប្រក្រតី; វិ. **ធម្មំ អនុវត្តតីតិ> ធម្មានុ. វត្តី, ធម្មំ អនុវត្តិតុំ សីលមស្សាតិ> ធម្មានុវត្តី** ។

**ធម្មានុស្សតិ** ឥ. [ ធម្មានុ+សរ+តិ ] ធម្មជាតិជាគ្រឿងរលឹកតាមនូវធម៌, ជាគ្រឿងរលឹករឿយៗនូវធម៌; វិ. **ធម្មំ អនុស្សរតិ ឯតាយាតិ> ធម្មានុស្សតិ** ។ . **អាទិ** គុ. (អនុស្សតិ) មានធម្មានុស្សតិជាដើម។

**ធម្មាភិសមយ** ពុំ. [ ធម្ម+អភិសមយ ] កិ.ដល់ព្រមចំពោះនូវធម៌, កិ. ត្រាស់ដឹងនូវធម៌ ។ (**អភិសមយ**<អភិ+សំ+ឥ ឬអយ+អ) ចូរមើលភាគទី១ផង ។

**ធម្មារាម** គុ. [ ធម្ម+អារាម ] អ្នកមានធម៌ជាទីមកត្រេកអរ, អ្នកត្រេកអរទូទៅក្នុងធម៌, ព្រះថេរៈឈ្មោះធម្មារាម ។ មួយវិញទៀតអ្នកមានកិ.ត្រេកអរទូទៅក្នុងធម៌; វិ. **ធម្មេ អារាមោ អស្សាតិ> ធម្មារាមោ** ។ . **ត្ថេរ** ពុំ. ព្រះថេរៈឈ្មោះធម្មារាម ។ . **សទិស** គុ. ប្រាកដស្មើដោយភិក្ខុឈ្មោះធម្មារាម, ដូចជាភិក្ខុឈ្មោះ..., ប្រហែលនឹងភិក្ខុឈ្មោះ... ។

**ធម្មាសន** នពុំ. [ ធម្ម+អាសន ] ធម្មាសនៈ, អាសនៈជាទីសំដែងនូវធម៌, ទីជាទីអង្គុយដើម្បីសំដែងនូវធម៌ ។

**ធម្មិក** គុ. [ ធម្ម+ណិក ] អ្នកប្រកបដោយធម៌; វិ. **ធម្មេន និយុ.**

Websites: WatKhemaraRatanaram.org or WatKhmers.org

ត្តោ> ធម្មិកោ ។ អ្នកប្រព្រឹត្តនូវធម៌ឬអ្នកប្រព្រឹត្តក្នុងធម៌; វិ. ធម្មំ ធម្មេ វា ចរតីតិ> ធម្មិកោ ។ អ្នកប្រព្រឹត្តតាមធម៌; វិ. ធម្មេន ចរតីតិ> ធម្មិកោ ។ -ឧបាសក បុំ. ឧបាសកអ្នកប្រកបដោយធម៌, ឧបាសកឈ្មោះធម្មិកៈ ។ -ជីវិត នបុំ. កិ. រស់នៅប្រកបដោយធម៌, ជីវិតប្រកបដោយធម៌ ។ -ថេរ បុំ. ព្រះថេរៈអ្នកប្រព្រឹត្តនូវធម៌, -ក្នុងធម៌ ។ -រាជ បុំ. ព្រះរាជាព្រះអង្គប្រកបដោយធម៌, -ប្រព្រឹត្តក្នុងធម៌ ។ -លាភ បុំ. លាភប្រកបដោយធម៌, លាភកើតហើយដោយធម៌ ។

**ធម្មិស្សរតា** ឥ. [ ធម្មិស្សរ+តា ] ភាវៈនៃ...ជាឥស្សរៈព្រោះធម៌, -នៃធម៌; វិ. ធម្មេន ឥស្សរោ> ធម្មិស្សរោ; តស្ស ភាវោ> ធម្មិស្សរតា ។

**ធម្មីកថា** ឥ. [ ធម្ម+ឦ-អា.+កថា ] វាចាជាហេតុពោលដោយធម៌, -តាមធម៌, -ប្រព្រឹត្តទៅក្នុងធម៌, -ប្រកបដោយធម៌ (ឦអាគមនេះចុះមកដើម្បីស្រួលដល់ការអានប៉ុណ្ណោះ) ។

**ធម្មោជបញ្ញា** ឥ. [ ធម្មោជ+បញ្ញា ] បញ្ញាមានឱជះកើតអំពីធម៌ ។

**ធរន្ត** គុ. [ ធរ+អ+អន្ត ] កាលទ្រទ្រង់, កាលទ្រង់ទុក, កាលទ្រង់នៅ ។

**ធរន្តិ** កិ. [ ធរ+អ+អន្តិ-វ. ] ទ្រទ្រង់, ទ្រង់ទុក (ស្លៀកដណ្ដប់, ចេះចាំ, នៅ) ។

**ធរមាន** គុ. [ ធរ+អ+មាន ] (ប្រែដូច ធរន្ត) ។

**ធរមានកពុទ្ធ** បុំ. [ ធរមានក+ពុទ្ធ ] ព្រះពុទ្ធកាលទ្រង់នៅ, ព្រះពុទ្ធ

Websites: WatKhemaraRatanaram.org or WatKhmers.org

កំពុងទ្រង់នៅ ។

**ធរមានមាតាបិតា** ចុំ. [ ធរមាន+មាតាបិតុ ] មាតាបិតាកាលទ្រង់នៅ, កំពុងរស់នៅ ។

**ធំសី** ចុំ. [ ធំស+ណី ] អ្នកកំចាត់, អ្នកកំចាត់បង់; វិ. **ធំសតីតិ> ធំសី** ។ អ្នកមានកិ.កំចាត់បង់ជាប្រក្រតី; វិ. **ធំសិតុំ សីល-មស្សាតិ> ធំសី** ។

**ធាតិ** ឥ. [ ធា+តិ ឬ ធរ+តិ ] (ស្ត្រី) អ្នកទ្រទ្រង់នូវកុមារ (ម៉ែដោះ, មេនំ, ភីលៀង, បងចិញ្ចឹម, បងរក្សា); វិ. **កុមារេ ធរតីតិ> ធាតិ**; (ប្រើកិរិយាសព្ទជាធរតិក៏បាន) ។

**ធាតុកម្មដ្ឋាន** នចុំ. [ ធាតុ+កម្មដ្ឋាន ] កម្មដ្ឋានគឺបណ្ឌិតកំណត់ហើយដោយធាតុ, កម្មដ្ឋានមានធាតុជាអារម្មណ៍ ។

**ធាតុគ្គហណ** នចុំ. [ ធាតុ+គហណ ] កិ.កាន់យកនូវព្រះធាតុ, កិ. រើសនូវព្រះធាតុ ។

**ធាតុចេតិយ** នចុំ. [ ធាតុ+ចេតិយ ] ចេតិយជាទីបញ្ចុះនូវព្រះធាតុ; វិ. **ធាតុនិធានំ ចេតិយំ> ធាតុចេតិយំ** ។

**ធាតុនិធាន** នចុំ. [ ធាតុ+និធាន ] កិ.បញ្ចុះនូវព្រះធាតុ, កិ.កប់នូវព្រះធាតុ ។

**ធាតុនិធានកាល** ចុំ. [ ធាតុនិធាន+កាល ] កាលជាទីបញ្ចុះនូវព្រះធាតុ, កាលជាទីកប់នូវព្រះធាតុ ។

**ធាតុនិធានដ្ឋាន** នចុំ. [ ធាតុនិធាន+ឋាន ] ទីជាទីបញ្ចុះនូវព្រះធាតុ, ទី

Websites: WatKhemaraRatanaram.org or WatKhmers.org

នៃកិ.បញ្ចុះនូវព្រះធាតុ ។

**ធារណា** នថ្ង. [ ធរ+យុ ] កិ.ទ្រទ្រង់, កិ.ទ្រង់ទុក (ការចេះចាំ); វិ. **ធរិយតេតិ> ធារណា** ។ - **តន្ទ** ថ្ង. ភ្លិនតីកិ.ទ្រទ្រង់, ភ្លិនតីកិ.ចាំ ។

**ធារយេ** កិ. [ ធរ+ណយ+ឯយ្យ.ស. ] គប្បីទ្រទ្រង់, គប្បីទ្រង់ទុក ។

**ធារា** ឥ. [ ធរ+ណ+អា.ឥ. ] (ធម្មជាតិ) ទ្រទ្រង់នូវកំលាំង, .នូវសន្ទុះ (ធារ, ធារទឹក, ទ, ទទឹក, ថ្នារទឹក); វិ. **ពេគំ ធារេតីតិ> ធារា** ។

**ធារាបាតនិរន្តរ** គុ. [ ធារាបាត+និរន្តរ ] មានកិ.ធ្លាក់ចុះនៃទទឹកមានចន្លោះមិនមាន, កាលមានចន្លោះមិនមាននៃកិ.ធ្លាក់ចុះនៃធារទឹក, .នៃទទឹក ។

**ធារាវេគ** ថ្ង. [ ធារា+វេគ ] កម្លាំងជាគ្រឿងដល់នៃទទឹក, កម្លាំងនៃធារទឹក, សន្ទុះនៃទទឹក, - នៃខ្សែទឹក (វេគ<វជ+អ = វិ. **ចជតិ ឯតេនាតិ> ពេគោ**) ។

**ធារិយមាន** គុ. [ ធរ+ឥ.អា.+យ+មាន ] តី...កាលទ្រទ្រង់ (.កាលទ្រាល, .កាលបាំង) ។

**ធារេតិ** កិ. [ ធរ+ណេ+តិ.វ. ] ទ្រទ្រង់,... ។

**ធារេតុំ** អ. [ ធរ+ណេ+តុំ ] ដើម្បីទ្រទ្រង់,... ។

**ធារេត្វា** អ. [ ធរ+ណេ+ត្វា ] ទ្រទ្រង់ហើយ,... ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ធាវេថ កិ. [ ធរ+ណេ+ថ-ប. ] ចូរទ្រទ្រង់,... ។

ធាវេន្តិ កិ. [ ធរ+ណេ+អន្តិ-វ. ] ទ្រទ្រង់,... ។

ធាវេន្ត គុ. [ ធរ+ណេ+អន្ត ] កាលទ្រទ្រង់, កំពុងទ្រទ្រង់ ។

ធាវេហិ កិ. [ ធរ+ណេ+ហិ-ប. ] ចូរទ្រទ្រង់ ។

ធាវតិ កិ. [ ធាវ+អ+តិ-វ. ] ស្ទុះទៅ, លឿនទៅ ។

ធាវន្ត គុ. [ ធាវ+អ+អន្ត ] កាលស្ទុះទៅ, កាលលឿនទៅ ។

ធាវិត គុ. [ ធាវ+ឥ-អា.+ត ] ស្ទុះទៅហើយ, លឿនទៅហើយ ។

ធិ និ. ថ្វីយ, មុខគួរអោយតិះដៀល, ដូចយើងតិះដៀល ។

ធិតិម គុ. [ ធិតិ+មន្តុ ] អ្នកមានប្រាជ្ញា (អ្នកមានប្រាជ្ញាជាគ្រឿងទ្រទ្រង់); វិ. **ធិតិ ឯតស្ស អត្ថីតិ> ធិតិមា** ។ ប្រើជា **ធីតិមា** ក៏មាន ។

ធិតិសម្បន្ន គុ. [ ធិតិ+សម្បន្ន ] អ្នកដល់ព្រមហើយដោយប្រាជ្ញា; វិ. **ធិតិយា សម្បន្នោ> ធិតិសម្បន្នោ** ។ អ្នកមានប្រាជ្ញាដល់ព្រមហើយ; វិ. **ធិតិ សម្បន្នា យស្ស សោ> ធិតិសម្បន្នោ** ។

ធីតា ឥ. [ ធរ+វិតុ ] (កុមារិកា) ដែលមាតានឹងបិតាទ្រទ្រង់ (ធីតា, កូនស្រី); វិ. **មាតាបិតូហិ ធារិយតីតិ> ធិតា** ។

ធុតង្គគុណ បុំ. [ ធុតង្គ+គុណ ] គុណគឺធុតង្គ, គុណគឺអង្គនៃធម៌ជាគ្រឿងកំចាត់បង់នូវកិលេស; វិ. **កិលេសេ ធុនាតិ ឯតេ-**

Websites: WatKhemaraRatanaram.org or WatKhmers.org

នាតិ> ធុតោ; ធុតស្ស អង្គំ> ធុតង្គំ, ធុតង្គំ ឯវ គុណោ> ធុតង្គគុណោ ។

ធុតង្គធរ ពុំ. [ ធុតង្គ+ធរ+អ ] អ្នកទ្រទ្រង់នូវអង្គនៃធម៌ជាគ្រឿងកំចាត់បង់នូវកិលេស, អ្នកទ្រទ្រង់នូវធុតង្គ; វិ. ធុតង្គំ ធារេ. តីតិ> ធុតង្គធរោ ។

ធុតង្គបរិហរណ នបុំ. [ ធុតង្គ+បរិហរណ ] កិ.នាំទៅជុំវិញនូវធុតង្គ; កិ.រក្សានូវធុតង្គ ។

ធុតង្គវត្ត នបុំ. [ ធុតង្គ+វត្ត ] វត្តគឺធុតង្គ, វត្តគឺអង្គនៃធម៌ជាគ្រឿងកំចាត់បង់នូវកិលេស ។

ធុតង្គារញ្ញាវាសវស ពុំ. [ ធុតង្គ+អរញ្ញ+អាវាស+វស ] អំណាចនៃកិ.នៅក្នុងព្រៃដើម្បីធុតង្គ, -ដើម្បីកិ.រក្សានូវធុតង្គ ។

ធុតវាទ ពុំ. [ ធុត+វាទ ] អ្នកមានវាទៈថាធុតៈ, អ្នកមានវាទៈថាធម៌ជាគ្រឿងកំចាត់បង់នូវកិលេស, អ្នកមានកិ.ពោលថាធុតៈ ។

ធុរ ពុំ. [ ធរ+អ, អនៃធ>ឧ ] នឹម, ខ្នង់ (តាមទម្លាប់មកថាទូករទេះ) ។ នបុំ. ធុរៈ, ការរវល់, ការកង្វល់ ។ គុ. ជិត, ទីដែលជិត ។

ធុរគ្គាម ពុំ. [ ធុរ+គាម ] ស្រុកជិត, ស្រុកដ៏ជិត ។

ធុរវហានសីលតា ឥ. [ ធុរវហានសីល+តា ] ភាវៈនៃ... ជាអ្នកមានកិ.នាំទៅនូវធុរៈជាប្រក្រតី; វិ. ធុរវហនំ សីលំ យស្ស សោ> ធុរវហានសីលោ; តស្ស ភាវោ>ធុរវហានសីលតា ។

ធុរវិហារ ពុំ. [ ធុរ+វិហារ ] វិហារដ៏ជិត, វត្តដ៏ជិត ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធុរ** នថុ. [ ធុ>ធុរ+អ ] ធម្មជាតនាំមុន, ..មិត្តថេរ (គុ. ទៀង, ទៀងទាត់; ថុ. ប្តី); វិ. **ធុចតិ ថិរភាវំ គច្ឆតីតិ> ធុរំ** ។

**ធុរដ្ឋាន** នថុ. [ ធុរ+ឋាន ] ទីដ៏ទៀងទាត់ ។

**ធុរធម្ម** ថុ. [ ធុរ+ធម្ម ] ធម៌ដ៏ទៀង, ធម៌ដ៏ទៀងទាត់, មានការទៀងទាត់ជាធម្មតា ។

**ធុរភត្ត** នថុ. [ ធុរ+ភត្ត ] ភត្តដ៏ទៀង, ភត្តគឺបុគ្គលគប្បីឱ្យដ៏ទៀង; វិ. **ធុរំ ធារកញ្ញំ ភត្តំ> ធុរភត្តំ** ។

**ធុរភាវ** ថុ. [ ធុរ+ភាវ ] ភាវៈនៃ...ជា...ដ៏ទៀង, ភាវៈជា...ដ៏ទៀង ។

**ធុរយាគុ** ឥ. [ ធុរ+យាគុ ] បបរដ៏ទៀង, បបរគឺបុគ្គលគប្បីឱ្យដ៏ទៀង ។

**ធូម** ថុ. [ ធុ+ម ] (សភាវៈ) រមែងញាប់ញ័រ (ផ្សែង); វិ. **ធុនាតីតិ> ធូមោ** ។

**ធូមកដច្ឆុក** ថុ. [ ធូម+កដច្ឆុក ] វែកសម្រាប់ដួសនូវផ្សែង ។

**ធូមតិមិរភាវ** ថុ. [ ធូមតិមិរ+ភាវ ] ភាវៈនៃ... ដូចជាផ្សែងនិងអ័ព្ទ, ភាវៈនៃ... មានសភាពដូចជាផ្សែង ឬដូចជាអ័ព្ទ ។

**ធូមរាសិ** ថុ. [ ធូម+រាសិ ] គំនរនៃផ្សែង, ដង្គោលនៃផ្សែង ។

**ធូមវេគ** ថុ. [ ធូម+វេគ ] កម្លាំងជាគ្រឿងដល់នៃផ្សែង; កម្លាំងនៃផ្សែង, សន្ទុះនៃផ្សែង ។

**ធូមាទិ** គុ. [ ធូម+អាទិ ] (វត្ថុ) មានផ្សែងជាដើម ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធូមេបេត្វា** អ. [ ធូម+ណាបេ+ត្វា ] ញុំាងភ្លើងឱ្យផ្សែងហើយ, បង្ហុយផ្សែងហើយ ។

**ធូមាយន្ត** គុ. [ ធូម+អាយ+អន្ត ] កាលប្រព្រឹត្តនូវផ្សែង, កាលបង្ហុយផ្សែង ។

**ធូមាយន្តិ** កិ. [ ធូម+អាយ+អន្តិ-វ. ] ប្រព្រឹត្តនូវផ្សែង, បង្ហុយនូវផ្សែង ។

**ធូមាយិ** កិ. [ ធូម+អាយ+ឦ-អជ្ជ. ] ប្រព្រឹត្តនូវផ្សែងហើយ, បង្ហុយផ្សែងហើយ ។

**ធូមាយិតុំ** អ. [ ធូម+អាយ+ឥ-អា.+តុំ ] ដើម្បីប្រព្រឹត្តនូវផ្សែង, ដើម្បីបង្ហុយផ្សែង ។

**ធូមាយិត្វា** អ. [ ធូម+អាយ+ឥ-អា.+ត្វា ] ប្រព្រឹត្តនូវផ្សែងហើយ, បង្ហុយផ្សែងហើយ ។

**ធេនុ** ឥ. [ ធេ+នុ ] គោញុំាងកូនឱ្យបៅនូវដោះ (មេគោ); វិ. **ធយតិ បិវតិ ឥតោ ខីរំ វច្ឆកោតិ> ធេនុ; ធប្បំ បាយេតីតិ វា> ធេនុ** ។

**ធេនុមង្គល** នបុំ. [ ធេនុ+មង្គល ] មង្គលគឺបុគ្គលគប្បីធ្វើដល់មេគោ, មង្គលដើម្បីមេគោ ។

**ធេនុរូប** នបុំ. [ ធេនុ+រូប ] រូបដូចជារូបនៃមេគោ ។

**ធេនុវេស** បុំ. [ ធេនុ+វេស ] ភេទដូចជាភេទនៃមេគោ ។

**ធោត** គុ. [ ធុ+ត ] គឺ...លាងហើយ, ..ជំរះហើយ, ..សំអាតហើយ,

Websites: WatKhemaraRatanaram.org or WatKhmers.org

-កំចាត់ហើយ ។ - មគ្គ គុ. គ្រាន់តែគឺ...លាងហើយ, គ្រាន់តែគឺព្រះសាស្តាលាងហើយ ។ - មូល គុ. មានឫសគឺ... រំលើងហើយ, មានឫសគឺ...ជ្រោះហើយ ។

**ធោនា** ឥ. [ ធុ+យុ+អា_ឥ. ] ឈ្មោះធោនា, ឱ្យឈ្មោះថាធោនា, (ប្រាជ្ញាជាគ្រឿងកំចាត់បង់នូវកិលេស; វិ. **កិលេសេ ធុនាតិ ឯតាយាតិ> ធោនា**) ។

**ធោរយ្ហសីល** គុ. [ ធោរយ្ហ+សីល ] អ្នកមានកិ.នាំទៅនូវធុរៈជាប្រក្រតី, អ្នកគួរដើម្បីនាំទៅនូវធុរៈជាប្រក្រតី; វិ. **ធោរយ្ហំ សីលំ យស្ស សោ> ធោរយ្ហសីលោ** ។ អ្នកគួរដើម្បីនាំទៅនូវធុរៈ; វិ. **ធុរំ ចហិតុំ អរហតីតិ> ធោរយ្ហោ** ។

**ធោវ** កិ. [ ធោវ+អ+ហិ_ប., លុបហិ ] ចូរលាង, ចូរបោកគក់, ចូរជំរះ, ចូរសំអាត ។

**ធោវតិ** កិ. [ ធោវ+អ+តិ_វ. ] លាង, គក់, ជំរះ, សំអាត, ជ្រោះ ។

**ធោវថ** កិ. [ ធោវ+អ+ថ_ប. ] ចូរលាង,... ។

**ធោវន្តី** ឥ. [ ធោវ+អ+អន្ត+ឦ ] កាលលាង,... ។

**ធោវន្តុ** កិ. [ ធោវ+អ+អន្តុ_ប. ] ចូរលាង,... ។

**ធោវន្ត** គុ. [ ធោវ+អ+អន្ត ] កាលលាង, កំពុងលាង ។

**ធោវាបេត្វា** អ. [ ធោវ+ណាបេ+ត្វា ] ឱ្យលាងហើយ, ញុំាង...ឱ្យលាងហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ធោវាបេសិ** កិ. [ ធោវ៑+ណាបេ+ញ្ញ.អជ្ជ.+ស.អា. ] ឱ្យលាងហើយ, ញ៉ាំង...ឱ្យលាងហើយ ។

**ធោវិ** កិ. [ ធោវ៑+អ+ញ្ញ.អជ្ជ. ] លាងហើយ ។

**ធោវិតុកាម** គុ. [ ធោវិតុំ+កម+ណ ] អ្នកចង់ដើម្បីលាង; វិ. **ធោវិតុំ កាមេតីតិ> ធោវិតុកាមោ** ។ ធោវិតុំ+កាម = អ្នកមានបំណងដើម្បីលាង; វិ. **ធោវិតុំ កាមោ អស្សាតិ> ធោវិតុកាមោ** ។

**ធោវិតុំ** អ. [ ធោវ៑+ឥ.អា.+តុំ. ] ដើម្បីលាង ។

**ធោវិត្វា** អ. [ ធោវ៑+ឥ.អា.+ត្វា ] លាងហើយ ។

**ធោវិយមាន** គុ. [ ធោ+ឥ.អា.+យ+មាន ] គឺ... កាលលាង ។

**ធោវិស្សាមិ** កិ. [ ធោវ៑+អ+ឥ.អា.+ស្សាមិ.ភ. ] នឹងលាង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ន និ. មិន, មិនមែន, ឥត, ទេ; (ន **អហោសិ** មិនបានមានហើយ; **ន អហោសិ មញ្ញេ** ទំនងជា ឬប្រហែលជាមិនបានមានហើយ, **ន កេវលំ** មិនតែប៉ុណ្ណោះ, មិនមែនតែម៉្យាងប៉ុណ្ណោះ) ។

នក្ខត្ត នប៉ុ. នក្ខត្តឫក្ស, ផ្កាយ ( នក្ខ+តា+អ = ធម្មជាតិរក្សានូវដំណើររបស់ខ្លួន; វិ. **អត្តនោ នក្ខនំ តមនំ តាយតិ រក្ខតីតិ> នក្ខត្តំ;** ន+ខី+ត = ធម្មជាតមិនចេះអស់ព្រោះការរះឡើងរឿយៗ; វិ. **បុនប្បុនមុទយតោ ន ខីយតេតិ> នក្ខត្តំ;** ន+ខរ+ត = ធម្មជាតមិនញ៉ាំងទីជាដំណើរនៃខ្លួនឱ្យវិនាស; វិ. **អត្តនោ គមនដ្ឋានំ ន ខរតិ ន វិនាសេតីតិ> នក្ខត្តំ)** ។ - **កីឡនក្ខត្ត** ប៉ុ. ប្រយោជន៍ដល់កិ.លេងនូវនក្ខត្តឫក្ស ។ - **កីឡន** នប៉ុ. កិ.លេងនូវនក្ខត្តឫក្ស ។ - **កោវិទ** គុ. អ្នកឈ្លាសក្នុងនក្ខត្តឫក្ស (**កោវិទ**<កុ+វិទ+អ = អ្នកបាននូវវាចា; វិ. **កុំ វាចំ វិន្ទតីតិ> កោវិទោ)** ។ - **ទិវស** ប៉ុ., នប៉ុ. ថ្ងៃនៃនក្ខត្តឫក្ស, ថ្ងៃមាននក្ខត្តឫក្ស, ថ្ងៃជាទីលេងនូវនក្ខត្តឫក្ស ។ - **បថ** ប៉ុ. គន្លង ឬផ្លូវនៃនក្ខត្តឫក្ស ។ - **បថសង្ខាត** គុ. ពោលគឺនក្ខត្តឫក្ស, គឺបណ្ឌិតរាប់ព្រមហើយថានក្ខត្តឫក្ស ។ - **បាឋក** ប៉ុ. អ្នកទាយនូវនក្ខត្តឫក្ស (ហោរ); វិ. **នក្ខត្តំ បឋតីតិ> នក្ខត្តបាឋកោ** ។ បឋ+ណ្វុ>បាឋក ។ - **បីឡន** នប៉ុ. កិ.បៀតបៀននៃនក្ខត្តឫក្ស ។ - **មុហុត្ត** នប៉ុ. នក្ខត្តឫក្សនិងយាម ។ - **យោគ** ប៉ុ. កិ.ប្រកបនៃនក្ខត្តឫក្ស, កិ.ជួបនៃផ្កាយ ។ ប្រើជា **យោគ្គ** ក៏មាន ។ - **រាជ** ប៉ុ. ស្ដេចនៃផ្កាយ (ព្រះចន្ទ្រ) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**នខ** ចុំ. ក្រចក ។ **បញ្ចរ** ចុំ. គ្រុងនៃក្រចក, គ្រញាំនៃក្រចក ។ **បិដ្ឋ** នចុំ. ខ្នងនៃក្រចក ។

**នគមុទ្ធនិ** [ នគមុទ្ធ+ស្ទ.វិ, ស្ទ.វិ.>និ ] លើកំពូលនៃភ្នំ ។

**នគរ** នចុំ. នគរ, ក្រុង (នគរ<នគ+រ=ទីមាននគៈ (១)គឺមានប្រាសាទជាដើម; វិ. **នគា បាសាទាទយោ អស្ស សន្តីតិ> នគរំ; នគរ**<ន+ឃរ, ឃ>គ = ទីមានផ្ទះដេរដាស; វិ. **នំ សម្បុណ្ណំ ឃរំ ឯត្ថាតិ> នគរំ**) ។ **គុត្តិក** ចុំ., គុ. អ្នកគ្រប់គ្រងនូវនគរ ។ **ទ្វារន្តរ** នចុំ. ចន្លោះនៃទ្វារនៃនគរ ។ **ទ្វារបាលក** ចុំ. អ្នករក្សានូវទ្វារនៃនគរ ។ **បទក្ខិណ** នចុំ. ប្រទក្សិណនៃក្រុង, ប្រទក្សិណនូវក្រុង ។ **បរិគ្គាហក** គុ. អ្នករក្សានូវនគរ, អ្នកគ្រប់គ្រងនូវនគរ, អ្នកកំណត់នូវនគរ; វិ. **នគរំ បរិគ្គណ្ហាតីតិ> នគរបរិគ្គាហកោ** ។ **បរិគ្គាហិក** គុ. អ្នកប្រកបក្នុងកិ.រក្សានូវនគរ, អ្នកគ្រប់គ្រងនូវនគរ ។ **បវិសនកាល** ចុំ. កាលនៃកិ.ចូលទៅកាន់នគរ, កាលជាទីចូលទៅកាន់នគរ ។ **មជ្ឈ** នចុំ. កណ្តាលនៃនគរ ។ **វាសី** ចុំ. អ្នកនៅក្នុងក្រុង, អ្នកនៅក្នុងក្រុងដោយប្រក្រតី, អ្នកមានកិ.នៅក្នុងក្រុងជាប្រក្រតី ។ **វិនាសនភីត** គុ. អ្នកខ្លាចអំពីសេចក្តីវិនាសនៃក្រុង ។ **វីថិ** ឥ. វិថីនៃក្រុង, ថ្នល់មានក្នុងក្រុង ។ **សទិស** គុ. ប្រាកដស្មើដោយក្រុង, ដូចជាក្រុង ។ **សង្ខាត** គុ. គឺបុគ្គលរាប់ព្រមហើយថាក្រុង, ពោលគឺក្រុង ។ **សេដ្ឋី** ចុំ.

---

១ ឈើ, ភ្នំ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សេដ្ឋីក្នុងក្រុង, សេដ្ឋីនៅក្នុងក្រុង ។ . **សោភណ** គុ. អ្នកមាន លំអរក្នុងក្រុង, អ្នកញ៉ាំងក្រុងឲ្យល្អ ។ . **សោភណិត្ថី** ឥ. ស្រីអ្នកល្អក្នុងក្រុង, ស្រីអ្នកមានលំអរក្នុងក្រុង, ស្រីអ្នកញ៉ាំង ក្រុងឲ្យល្អ (ស្រីផ្កាមាស) ។

**នគរាភិមុខ** គុ. [ នគរាភិមុខ+ណ្យ ] អ្នកមានមុខឆ្ពោះទៅកាន់ក្រុង, អ្នកមានមុខសំដៅទៅកាន់ក្រុង ។

**នគរូបចារ** ពុំ. [ នគរ+ឧបចារ ] ឧបចារៈនៃក្រុង, ទីជាទីត្រាច់ទៅជិត នៃក្រុង ។

**នគរូបម** គុ. [ នគរ+ឧបមា ] មានឧបមាដោយក្រុង, មានសេចក្ដី ប្រៀបដោយក្រុង, មានក្រុងជាគ្រឿងប្រៀប ។

**នគ្គ** គុ. អាក្រាត, ស្រាត (នគ្គ<ន+គម+ក្វ = រិ. ន គច្ឆតីតិ> នគ្គោ) ។ . **ចរិយា** ឥ. កិ.ប្រព្រឹត្តិអាក្រាត, កិ.ប្រព្រឹត្តិដោយ ភាពជាអ្នកអាក្រាត ។ . **ចរិយាទិ** គុ. (វត្ថុ) មានកិ.ប្រព្រឹត្តិ អាក្រាតជាដើម, .មានកិ.ប្រព្រឹត្តិដោយភាពជាអ្នកអាក្រាតជា ដើម ។ . **សមណ** ពុំ. សមណៈអាក្រាត, សមណៈអ្នកអាក្រាត, សមណៈស្រាត ។

**នង្គល** នពុំ. នង្គ័ល (នង្គល<នង្គ+លុ+អ = រិ. ភូមិំ នង្គំ ករោន្តោ លុនាតីតិ> នង្គលំ) ។ . **កូដត្ថេរ** ពុំ. ព្រះថេរៈឈ្មោះ នង្គលកូដៈ ។ . **ផាលាទិឧបករណបូរ** គុ. ដ៏ពេញដោយគ្រឿង ឧបករណ៍មាននង្គ័លនិងផាលជាដើម ។ . **សីស** នពុំ. សីសៈនៃ នង្គ័ល, យាមនៃនង្គ័ល (តាមទម្លាប់ថា ភ្ញៀងនៃនង្គ័ល) ។

Websites: WatKhemaraRatanaram.org or WatKhmers.org

- **សីសមត្តក្ខន្ធ** គុ. មានដើមប៉ុនយាមនៃនង្គ័ល, មានដើមមានសីសៈនៃនង្គ័លជាប្រមាណ ។

**នង្គុដ្ឋ** នបុំ. [ ន+អង្គ+ដ្ឋ ] កន្ទុយ, កន្ទុយសត្វ; (វិ. **ន អង្គតិ គច្ឆតីតិ> នង្គុដ្ឋំ**) ។

**នចិរស្ស** និ. មិនយូរ, អស់កាលមិនយូរ, មិនយូរប៉ុន្មាន ។

**នចិរំ** កិ.វិ. មិនយូរ, អស់កាលមិនយូរ ។

**នច្ច** នបុំ. [ នត+យ ] កិ.រាំ (កិ.មីតពត់នូវខ្លួន); វិ. **នច្ចនំ> នច្ចំ** ។

**នច្ចគីត** នបុំ. [ នច្ច+គីត ] កិ.រាំនិងកិ.ច្រៀង ។ - **កុសល** គុ. អ្នកឈ្លាសក្នុងកិ.រាំនិងកិ.ច្រៀង, អ្នកប្រសប់ក្នុងកិ.រាំនិងកិ.ច្រៀង ។ - **វាទិតមត្ត** គុ. (សិល្បៈ) គ្រាន់តែកិ.រាំ និងកិ.ច្រៀង និងកិ.ប្រគំ ។

**នច្ចនមយូរ** បុំ. [ នច្ចន+មយូរ ] ក្ងោកមានកិ.រាំជាប្រក្រតី, ក្ងោកជាទីរាំ ។

**នច្ចន្ត** គុ. [ នត+យ+អន្ត ] កាលរាំ, កំពុងរាំ ។

**នច្ចន្តិ** កិ. [ នត+យ+អន្តិ.វ. ] រាំ ។

**នច្ចមាន** គុ. [ នត+យ+មាន ] កាលរាំ, កំពុងរាំ ។

**នច្ចសមជ្ជ** បុំ. [ នច្ច+សមជ្ជ ] មហោស្រពគឺបុគ្គលតប្បីលេងដោយអំណាចនៃកិ.រាំ, មហោស្រពគឺបុគ្គលលេងដោយកិ.រាំ, មហោស្រពគឺបុគ្គលតប្បីរាំ ។

**នច្ចាបនទិវស** បុំ. [ នច្ចាបន+ទិវស ] ថ្ងៃជាទីញុំាង...ឱ្យរាំ, ថ្ងៃនៃកិ.

Websites: WatKhemaraRatanaram.org or WatKhmers.org

ញ៉ាំង...ឱ្យរាំ (និច្ចាបន<នត+យ+ណាបេ+យុ) ។

**និច្ចាបេត្វា** អ. [ នត+យ+ណាបេ+ត្វា ] ឱ្យរាំហើយ, ញ៉ាំង...ឱ្យរាំហើយ ។

**និច្ចិតុំ** អ. [ នត+យ+ឥ_អា.+តុំ ] ដើម្បីរាំ ។

**និច្ចិស្សាម** កិ. [ នត+យ+ឥ_អា.+ស្សាម_ភ. ] នឹងរាំ ។

**និច្ចាទេតិ** កិ. [ ន+ឆាទេតិ ] មិនញ៉ាំង...ឱ្យបិទបាំង, មិនបិទបាំង, មិនស្លៀកដណ្ដប់ ។

**នដ** ពុំ. [ នត+ ឬនដ+អ ] (ជន) អ្នករាំ (អ្នករបាំ); វិ. **នដតីតិ> នដោ** ។ - **កីឡ** កិវិ. លេងនៃជនអ្នករាំ, កិ.លេងនៃអ្នករបាំ ។ - **គេហ** នបុំ. ផ្ទះនៃជនអ្នករាំ, -អ្នករបាំ ។ - **ទារក** ពុំ. ទារកនៃជនអ្នករាំ, -អ្នករបាំ ។ - **ធីតា** ឥ. ធីតានៃជនអ្នករាំ, -អ្នករបាំ ។ - **បុត្ត** ពុំ. កូននៃជនអ្នករាំ, -អ្នករបាំ ។ - **បុព្វក** គុ. ធ្លាប់ជាជនអ្នករាំ, ធ្លាប់ជាអ្នករបាំ ។ - **បុព្វកវត្ថុ** នបុំ. រឿងនៃព្រះថេរៈអ្នកធ្លាប់រាំ, រឿងនៃព្រះថេរៈជាអ្នកធ្លាប់រាំ ។

**នដាទិ** គុ. [ នដ+អាទិ ] (ជន) មានជនអ្នករាំជាដើម ។

**នដ្ឋ** គុ. [ នស+ត ] វិនាសហើយ, បាត់ហើយ, ខូចហើយ, លាញហើយ ។ - **គោណ** ពុំ. គោដែលបាត់ហើយ ។

**នត្ត** ពុំ. [ នហ+វិតុ ] (កុមារ) ដែលជីដូននិងជីតាចងដោយសេចក្ដីស្រឡាញ់ (ចៅ); វិ. **នយ្ហតិ ពន្ធិយតិ បេមេនាតិ> នត្តា** ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ន័យខ្លះថា នី+តុ ។ - មត្ត គុ. ប៉ុនថៅ, មានថៅជាប្រមាណ, គ្រាន់តែជាថៅ ។

**នត្ថិ** កិ. [ ន+អត្ថិ ] មិនមាន, គ្មាន ។

**នត្ថិតា** ឥ. [ នត្ថិ+តា ] ភាវៈនៃ...ជារបស់មិនមាន, -គ្មាន ។

**នត្ថិប្លវ** បុំ. [ នត្ថិ+ប្លវ ] នំមិនមាន, នំគ្មាន ។

**នត្ថិភាវ** បុំ. [ នត្ថិ+ភាវ ] ភាវនៃ... ជារបស់មិនមាន, គ្មាន ។

**នត្ថុកម្ម** នបុំ. [ នត្ថុ+កម្ម ] កម្មគឺបុគ្គលគប្បីធ្វើតាមច្រមុះ ។

**នទន្ត** គុ. [ នទ+អ+អន្ត ] កាលបន្លឺ, កំពុងបន្លឺ ។

**នទាបេតុកាម** គុ. [ នទាបេតុំ+កម+ណ ] អ្នកចង់ដើម្បីញ៉ាំង... ឱ្យបន្លឺ ។

**នទិ** កិ. [ នទ+អ+ញ្ញ-អជ្ជ. ] បន្លឺហើយ, ស្រែកហើយ ។

**នទិត្វា** អ. [ នទ+ឥ-អា.+ត្វា ] បន្លឺហើយ, ស្រែកហើយ ។

**នទិស្សតិ** កិ. [ នទ+អ+ឥ-អា.+ស្សតិ-ភ. ] នឹងបន្លឺ ។

**នទី** ឥ. [ នទ+អ ឬឦ ] (ធម្មជាតិ) ហូរទៅរឿយៗ ឬបន្លឺរឿយៗ (មេទឹក, ស្ទឹង, ទន្លេ); វិ. **អភិក្ខណំ នទតីតិ> នទី** ។ - **អាទិសទិស** គុ. ប្រាកដស្មើដោយប្រទេសមានស្ទឹងជាដើម ។ - **ចរកកាកជាតក** នបុំ. ជាតកគឺបណ្ឌិតកំណត់ដោយក្អែកត្រាច់ទៅក្នុងស្ទឹង ។ - **តិត្ថ** នបុំ. កំពង់នៃស្ទឹង, -នៃទន្លេ, កំពង់

Websites: WatKhemaraRatanaram.org or WatKhmers.org

ឮដីទន្លេ ។ **តីរ** នបុំ. ឆ្នេរនៃទន្លេ, ត្រើយនៃទន្លេ ។ **បទេស** បុំ. ប្រទេសនៃស្ទឹង, -នៃទន្លេ ។ **សោត** បុំ. ខ្សែនៃទឹកទន្លេ, ខ្សែនៃទឹកស្ទឹង ។

**នទ្ធិ** នបុំ. ឬឥ. [ នហ+ត+ឰ ] (វត្ថុជាគ្រឿងចង ឬជាគ្រឿងត្របែង (ខ្សែ, ព្រួរ, ខ្សែព្រួរ); វិ. **នយ្ហតិ ឯតេនាតិ>** **នទ្ធិ** ។ ម្យ៉ាងទៀត : ខ្សែជាគ្រឿងដែលជនចង ឬត្របែង (នៃវត្ថុ); វិ. **នយ្ហតេ ពន្ធិយតេ យាយ សា>** **នទ្ធិ** ។ ប្រើជា នទ្ធី ក៏មាន ។

**នទ្ធិវរត្តា** អ. [ នទ្ធិ+វរត្ត ] ព្រួរនិងព្រ័ត្រ, ខ្សែព្រួរនិងព្រ័ត្រស្បែក ។

**ននិកាមសេយ្យ** [ ននិកាម+សេយ្យ ] កិ.ដេកនៃបុគ្គលអ្នកមិនមានសេចក្តីប្រាថ្នា ។

**ននុ** និ. មិនមែនឬ, មិនមែនទេឬ, មិនដូច្នោះឬ ។

**នន្ទកុមារ** បុំ. [ នន្ទ+កុមារ ] កុមារឈ្មោះនន្ទ ។

**នន្ទគោបាលក** បុំ. [ នន្ទ+គោបាលក ] បុរសអ្នកថែរក្សានូវគោឈ្មោះនន្ទៈ, នាយគោបាលឈ្មោះនន្ទៈ (វិ. **គាវោ បាលេតីតិ> គោបាលកោ**) ។ **វត្ថុ** នបុំ. រឿងនៃបុរសអ្នករក្សានូវគោឈ្មោះនន្ទៈ, រឿងនៃបុរសអ្នកឃ្វាលនូវគោឈ្មោះនន្ទៈ ។

**នន្ទតិ** កិ. [ នន្ទ+អ+តិ.វ. ] ត្រេកអរ, រីករាយ ។

**នន្ទនដ្ឋាន** នបុំ. [ នន្ទន+ឋាន ] ទីជាទីត្រេកអរ, ទីជាទីរីករាយ (នន្ទន<នន្ទ+យុ = សេចក្តីត្រេកអរ; វិ. **នន្ទិយតេតិ>**

Websites: WatKhemaraRatanaram.org or WatKhmers.org

នន្ទន៍) ។

នន្ទមូលកបព្ភារ ចុំ. [ នន្ទមូលក+បព្ភារ ] ញកនៃភ្នំឈ្មោះនន្ទ-មូលកៈ ។

នន្ទមាណវ ចុំ. [ នន្ទ+មាណវ ] មាណពឈ្មោះនន្ទៈ ។

នន្ទមាតា ឥ. [ នន្ទ+មាតា ] មាតានៃកុមារឈ្មោះនន្ទៈ ។

នន្ទមាន គុ. [ នន្ទ+អ+មាន ] កាលត្រេកអរ, កំពុងត្រេកអរ ។

នន្ទិវិសាលជាតក នចុំ. [ នន្ទិវិសាល+ជាតក ] ជាតកគឺបណ្ដិតកំណត់ហើយដោយគោឈ្មោះនន្ទិវិសាល ។

នន្ទិភវបរិក្ខីណ គុ. [ នន្ទី+ភវ+បរិក្ខីណ ] មានសេចក្ដីត្រេកអរនិងភពអស់រលីងហើយ, មានតណ្ហាជាគ្រឿងត្រេកអរក្នុងភពអស់រលីងហើយ, មានតម្រេកក្នុងភពអស់រលីងហើយ ។ សេចក្ដីត្រេកអរ; វិ. នន្ទនំ> នន្ទី ។

នន្ទិយវត្ថុ នចុំ. [ នន្ទិយ+វត្ថុ ] រឿងនៃមាណពឈ្មោះនន្ទិយៈ ។

នន្ទិរាគ ចុំ. [ នន្ទី+រាគ ] រាគៈកើតដោយអំណាចនៃសេចក្ដីត្រេកអរ, តម្រេកដោយអំណាចនៃតណ្ហាជាគ្រឿងត្រេកអរ ។

នន្ទិស្សំ កិ. [ នន្ទ+អ+ឥ_អា.+ស្សំ_ភ. ] នឹងត្រេកអរ ។

នប្បដិក្កោសិ កិ. [ ន+បដិក្កោសិ ] មិនហាមហើយ, មិនឃាត់ហើយ (បដិ+កុស+អ+ឦ_អជ្ជ.) ។

នប្បតិដ្ឋហិស្សតិ កិ. [ ន+តិដ្ឋហិស្សតិ ] នឹងមិនតាំងនៅ, នឹងមិន

Websites: WatKhemaraRatanaram.org or WatKhmers.org

ឋិតនៅ, នឹងមិនតំកល់នៅ, នឹងមិនតាំងនៅស៊ប់ (ប+ឋា, ឋា> តិដ្ឋ+អ+ហ.អា.+ឥ.អា.+ស្សតិ.ភ.) ។

**នប្បមជ្ជតិ** កិ. [ ន+បមជ្ជតិ ] មិនប្រមាទ, មិនធ្វេសប្រហែស (ប+មទ+យ+តិ.វ.) ។

**នប្បវត្តន្តិ** កិ. [ ន+បវត្តន្តិ ] មិនប្រព្រឹត្ត, មិនប្រព្រឹត្តទៅ (ប+វត្ត+អ+អន្តិ.វ.) ។

**នប្បវត្តេសិ** កិ. [ ន+បវត្តេសិ ] មិនញ៉ាំង...ឱ្យប្រព្រឹត្តទៅហើយ, មិនឱ្យប្រព្រឹត្តទៅហើយ (ប+វត្ត+ណេ+ឦ.អជ្ជ.+ស.អា.) ។

**នប្បសហេយ្យ** កិ. [ ន+បសហេយ្យ ] មិនគប្បីកំហែង, គប្បីកំហែងមិនបាន, មិនគប្បីគ្របសង្កត់, គប្បីគ្របសង្កត់មិនបាន (ប+សហ +អ+ឯយ្យ.ស.) ។

**នប្បសំសន្តិ** កិ. [ ន+បសំសន្តិ ] មិនសរសើរ (ប+សំស+អ+អន្តិ.វ.) ។

**នប្បហោតិ** កិ. [ ន+បហោតិ ] មិនល្មម, មិនល្មមគ្រាន់, មិនគ្រប់គ្រាន់, មិនចេះអស់មិនចេះហើយ (ប+ហុ+អ+តិ.វ.) ។

**នពហុជ្ជន** គុ. [ ន+ពហុជ្ជន ] មិនមែនជាជនច្រើន, មិនមែនមានជនច្រើន (ពហុ+ជន) ។

**នភមជ្ឈ** នថុំ. [ នភ+មជ្ឈ ] កណ្ដាលនៃអាកាស ។ នភ<ន+ភូ+អ = វិ. ន ភវតិ ឯត្ថ កិញ្ចិ ចត្ថុតិ> នភំ = ទីជាទីមិនមាននៃវត្ថុសូម្បីបន្តិចបន្តួច (អាកាស) ។ ម្យ៉ាងទៀត នភ<ន+ភី

Websites: WatKhemaraRatanaram.org or WatKhmers.org

+អ = វិ. ន ភាយន្តិ បក្ខិនោ ឯត្ថាតិ ខា> នភំ = ទីជាទីមិនខ្លាចនៃបក្សី (អាកាស) ។

**នមតិ** កិ. [ នម+អ+តិ.វ. ] ឱនទៅ, បង្អោនទៅ, ពត់ ។

**នមយន្តិ** កិ. [ នម+ណយ+អន្តិ.វ. ] ញុំាង...ឱ្យឱនទៅ, បង្អោនទៅ, ពត់ ។

**នមស្សតិ** កិ. [ នមស្ស+អ+តិ.វ. ] បង្អោនទៅ, នមស្សការ, ថ្វាយបង្គំ ។

**នមស្សនភាវ** ចុំ. [ នមស្សន+ភាវ ] ភាវៈនៃកិ.បង្អោនទៅ, -នៃកិ.នមស្សការ, -នៃកិ.ថ្វាយបង្គំ ។

**នមស្សន្ត** គុ. [ នមស្ស+អ+អន្ត ] កាលនមស្សការ, កាលថ្វាយបង្គំ ។

**នមស្សមាន** គុ. [ នមស្ស+អ+មាន ] កាលនមស្សការ, កាលថ្វាយបង្គំ ។

**នមស្សិតព្វ** គុ. [ នមស្ស+ឥ.អា+តព្វ ] គឺ...គប្បីនមស្សការ,... ។

**នមស្សិត្វា** អ. [ នមស្ស+ឥ.អា.+ត្វា ] នមស្សការហើយ,... ។

**នមស្សេយ្យ** កិ. [ នមស្ស+អ+ឯយ្យ.ស. គប្បីនមស្សការ ។

**នមិ** កិ. [ នម+អ+ឦ.អជ្ជ. ] ឱនទៅហើយ (មូរហើយ, ខូរហើយ) ។

**នមិត** គុ. [ នម+ឥ.អា.+ត ] ឱនទៅហើយ,... ។

**នមេយ្យ** កិ. [ នម+អ+ឯយ្យ.ស. ] គប្បីឱនទៅ, គប្បីបង្អោន

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅ,... ។

**នយ** ពុំ. [ នី+អ ] កិ.នាំទៅ, សេចក្ដីពន្យល់, ន័យ; វិ. **នយនំ> នយោ** ។

**នយទាន** នពុំ. [ នយ+ទាន ] កិ.ឱ្យនូវន័យ, កិ.ឱ្យនូវសេចក្ដីពន្យល់ ។

**នយន្តិ** កិ. [ នី+អ+អន្តិ_វ. ] នាំទៅ, ដឹកទៅ ។

**នយសត** នពុំ. [ នយ+សត ] រយនៃន័យ ។

**នយសហស្ស** នពុំ. [ នយ+សហស្ស ] ពាន់នៃន័យ ។

**នយិស្សាមិ** កិ. [ នី+អ+ឥ_អា.+ស្សាមិ_ភ. ] នឹងនាំទៅ ។

**នយីសុ** កិ. [ នី+អ+ឥំ_អជ្ជ. ] នាំទៅហើយ ។

**នយេ** កិ. [ នី+អ+ឯយ្យ_ស. ] គប្បីនាំទៅ ។

**នរក** ពុំ. [ នរ+ណុ ] ប្រទេសនាំទៅនូវសត្វឥតបុណ្យ (នរក, រណ្ដៅ); វិ. **អបុញ្ញេ នរតិ នេតីតិ> នរកោ** ។ - **សទិស** គុ. ប្រាកដស្មើដោយនរក, ដោយរណ្ដៅ, ដូចជារណ្ដៅ ។

**នរ** ពុំ. នរៈ (និរ<ន+អរ ឬនរ+អ = វិ. **នេតីតិ> នរោ; នរតិ នេតីតិ វា> នរោ** ។ - **ទម្មសារថិ** ពុំ. ជាអ្នកទូន្មាននូវនរៈដូចជាសារថី, ជាអ្នកគួរដើម្បីទូន្មាននូវនរៈដូចជាសារថី, ជាសារថីគួរដើម្បីទូន្មាននូវនរៈ ។ - **ទេវ** ពុំ. ជាទេវតានៃនរៈ, ដូចជាទេវតានៃនរៈ ។ - **វីរសេដ្ឋ** អា. ន. បពិត្រព្រះអង្គប្រសើរបំផុតដោយព្យាយាមជាងនរៈ, បពិត្រព្រះអង្គអ្នកមានព្យាយាមប្រសើរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាងនរៈ ។

**នរាសភ** គុ. [ នរ+អាសភ ] ប្រសើរជាងនរៈ, ទ្រង់អង់អាច ជាងនរៈ ។

**នរិន្ទ** គុ. [ នរ+ឥន្ទ ] ជាធំជាងនរៈ, ជាកំពូលនៃនរៈ, ជាមេនៃនរៈ ។

**នល-នឡ** ចុំ. បបុស ។ - **សាកិយ** ចុំ. ឈ្មោះនលសាកិយៈ (សាកិយៈបបុស) ។ នល<និ+អល ។

**នលាដន្ត** ចុំ. [ នលាដ+អន្ត ] ទីបំផុតនៃថ្ងាស ។

**នវ** ប.សំ. ប្រាំបួន; គុ. ថ្មី ។

**នវអត្ថសស្សទាន** នចុំ. [ នវ+អត្ថ+សស្ស+ទាន ] កិ.ឱ្យនូវសំទូងដ៏ប្រសើរ៩ផង, ទានគឺបណ្ឌិតកំណត់ហើយដោយសំទូងដ៏ប្រសើរ៩ផង ។

**នវក** គុ. [ នវ+ក.ស. ] ថ្មី, របស់ថ្មី(១) ។ - **និបាត** ចុំ. គម្ពីរឈ្មោះនវកនិបាត ។ **ភាវ** ចុំ. ភាវៈនៃ...ជាអ្នកថ្មី, ភាពជាអ្នកថ្មី, ភាពជារបស់ថ្មី ។

**នវកម្ម** នចុំ. [ នវ+កម្ម ] កម្មថ្មី, ការងារថ្មី ។

**នវកម្មិក** គុ. [ នវកម្ម+ណិក ] អ្នកប្រកបក្នុងកម្មថ្មី, អ្នកប្រកបក្នុងការងារថ្មី (និយុត្តតទ្ធិត) ។

**នវកោដិអគ្ឃនក** គុ. [ នវកោដិ+អគ្ឃនក ] គួរនូវថ្លៃមានកោដិ៩ជា

---

១ បរិមាណទ្ធិត ប្រែថាមានបរិមាណ៩; វិ. នវ បរិមាណានិ អស្សាតិ> នវកោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រមាណ, ដល់នូវថ្លៃមានកោដិ៩ជាប្រមាណ (មានតម្លៃ៩កោដិ) ។

**នវកោដិ** ត. [ នវ+កោដិ ] កោដិ៩ ។

**នវកោដិធន** នបុំ. [ នវ+កោដិ+ធន ] ទ្រព្យមានកោដិ៩ជាប្រមាណ ។

**នវក្ខត្តុំ** កិ. វិ. [ នវ+សកឹ>នវក្ខត្តុំ ] វារៈ៩ដង, ៩ដង, ៩លើក ។ មយ៉ាងទៀតអព្យយតទ្ធិត "ប្រព្រឹត្តទៅក្នុងវារៈ៩ដង, .អស់វារៈ៩ដង; វិ. **នវវារេ បវត្តតីតិ> នវក្ខត្តុំ** " ។

**នវប្បព្វជិត** គុ. [ នវ+បព្វជិត ] បួសហើយថ្មី, បួសថ្មី, ជាអ្នកទើបនឹងបួសថ្មី; បុំ. បព្វជិតថ្មី ។

**នវប្បាសាទ** បុំ. [ នវ+បាសាទ ] ប្រាសាទថ្មី ។

**នវភាជន** នបុំ. [ នវ+ភាជន ] ភាជន៍ថ្មី ។

**នវមធុ** នបុំ. [ នវ+មធុ ] ទឹកឃ្មុំថ្មី ។

**នវម** បូ.សំ. [ នវ+ម ] ទី៩, គំរប់៩ ។

**នវយោជន** នបុំ. [ នវ+យោជន ] យោជន៍៩, មានយោជន៍៩ជាប្រមាណ ។ -**សតប្បមាណ** គុ. មានរយនៃយោជន៍៩ជាប្រមាណ ។

**នវលោកុត្តរធម្មសង្ខាត** គុ. [ នវ+លោកុត្តរ+ធម្ម+សង្ខាត ] គឺបណ្ឌិតរាប់ព្រមហើយថាធម៌ជាលោកុត្តរៈ៩, ពោលគឺធម៌ជាលោកុត្តរ៩,

Websites: WatKhemaraRatanaram.org or WatKhmers.org

គឺលោកុត្តរធម៌ទាំង ៩ ។

**នវវារ** ចុំ. [ នវ+វារ ] វារៈ៩, វារៈ៩ដង, ៩លើក ។

**នវវិធ** គុ. [ នវ+វិធ ] មានប្រការ៩, មាន៩យ៉ាង; វិ. **នវ វិធា បការា យស្សាតិ> នវវិធោ** ។ - **មាន** ចុំ. មានះមានប្រការ៩, មានះមាន៩យ៉ាង ។ - **លោកុត្តរធម្មវស** ចុំ. អំណាចនៃលោកុត្តរធម៌មានប្រការ៩ ។

**នវវុដ្ឋ** គុ. [ នវ+វុដ្ឋ ] ដែលតាំងឡើងថ្មី, គឺភ្លៀងធ្លាក់ចុះថ្មីៗ, គឺភ្លៀងបង្អុរចុះថ្មីៗ, ដែលទើប ភ្លៀងថ្មីៗ (វុដ្ឋ<វស្ស+ត) ។

**នវសត** គុ. [ នវ+សត ] មានរយ៩ជាប្រមាណ (ប្រាំបួនរយ) ។

**នវសប្បិ** នបុំ. [ នវ+សប្បិ ] សប្បិថ្មី, ទឹកដោះថ្លាថ្មី ។ - **សង្ខតខីរយាគុ** ឥ. បបរគឺបុគ្គលចំអិនដោយទឹកដោះស្រស់ដែលបុគ្គលចាត់ចែងហើយដោសប្បិថ្មី, ខីរយាគុដែលបុគ្គលតាក់តែងដោយសប្បិថ្មី (សង្ខត<សំ+ករ+ត, ករ>ខ = ប្រុង, តាក់តែង, ចាត់ចែង, លាយ, ផ្សំ )។

**នវសីវថិកាវស** ចុំ. [ នវ+សីវថិកា+វស ] អំណាចនៃភូមិជាទីតាំងនៃសាកសព៩ ។

**នវហត្ថ** គុ. [ នវ+ហត្ថ ] មានហត្ថ៩ជាប្រមាណ ( ៩ហត្ថ ) ។

**នវុតិកប្ប** ចុំ. [ នវុតិ+កប្ប ] កប្បកៅសិប ។

**នវុតិវស្សសហស្សបរិមាណ** គុ. [ នវុតិវស្ស+សហស្ស+បរិមាណ ]

Websites: WatKhemaraRatanaram.org or WatKhmers.org

មានពាន់នៃឆ្នាំកៅសិបជាប្រមាណ ។

**នវោទក** នពុំ. [ នវ+ឧទក ] ទឹកថ្មី ។

**នស្សៃ** កិ. [ នស+យ+ហិ_ប., លុប ហិ_ប. ] ចូរវិនាស, ចូរបាត់, ចូរសូន្យទៅ,.... ។

**នស្សតុ** កិ. [ នស+យ+តុ_ប. ] ចូរវិនាស, ចូរបាត់, ចូរសូន្យ,... ។

**នស្សន្តិ** កិ. [ នស+យ+អន្តិ_វ. ] វិនាស, បាត់, សូន្យ,... ។

**នស្សិស្សន្តិ** កិ. [ នស+យ+ឥ_អា.+ស្សន្តិ_ភ. ] នឹងវិនាស,.... ។

**នស្សឹសុ** កិ. [ នស+យ+ឱំ_អជ្ជ. ] វិនាសហើយ ។

**នហាត** គុ. [ នហា+ត ] ងូតហើយ, លាងហើយ ។

**នហាតក** ពុំ. [ នហា+ត+ក_ស. ] អ្នកងូត, អ្នកលាង, អ្នកផ្ងូត ។

**នហាតក្កិលេសតា** ឥ. [ នហាតក្កិលេស+តា ] ភាវៈនៃ...ជាអ្នកមានកិលេសលាងហើយ ។

**នហាត្វា** អ. [ នហា+ត្វា ] ងូតហើយ, លាងហើយ, កក់ហើយ ។

**នហាន** នពុំ. [ នហា+យុ ] កិ.ងូត, ជាទីងូត, កិ.លាង, ជាទីលាង, សម្រាប់ងូត; វិ. **នហាយតេ>** **នហានំ**; **នហាយន្តិ ឯត្ថាតិ>** **នហានំ**; **នហាយន្តិ ឯតេនាតិ>** **នហានំ** ។ - **កាល** ពុំ. កាលជាទីងូត, កាលនៃកិ.ងូត ។ - **កោដ្ឋក** ពុំ. បន្ទប់ជាទីងូត, បន្ទប់សម្រាប់ងូត ។ - **ចុណ្ណមូល** នពុំ. ជាមូលនៃលំអិតសម្រាប់ងូត, ជាតម្លៃនៃលំអិតសម្រាប់ងូត ។ - **តិត្ថ**

Websites: WatKhemaraRatanaram.org or WatKhmers.org

នថុំ. កំពង់ជាទីងូត, កំពង់គឺជាទីងូត ។ . **បរិយោសាន** នថុំ. កាលជាទីបំផុតចុះជ្រំវិញនៃកិ.ងូត, កាលជាទីហើយស្រេចនៃកិ.ងូត ។ . **ផលក** នថុំ. ផែនក្ដារជាទីងូត, បន្ទះក្ដារសម្រាប់ងូត ។ . **មូល** នថុំ. ជាតម្លៃនៃកិ.ងូត, ជាតម្លៃនៃលំអិតសម្រាប់ងូត ។ . **វេលា** ឥ. វេលាជាទីងូត ។

**នហានោទក** នថុំ. [ នហាន+ឧទក ] ទឹកសម្រាប់ងូត ។

**នហាបិត** ថុំ. ឬគុ. [ នហា+ណាបេ+ឥ.អា.+ត ] ជនអ្នកញ៉ាំងបុគ្គលឱ្យងូត (ជាងកំណោរ, ជាងអ្នកកោរកាត់); វិ. **នហាបេតីតិ> នហាបិតោ** ។

**នហាបេត្វា** អ. [ នហា+ណាបេ+ត្វា ] ឱ្យងូតហើយ, ញ៉ាំង...ឱ្យងូតហើយ, ផ្ងូតហើយ ។

**នហាបេន្ត** គុ. [ នហា+ណាបេ+អន្ត ] កាលឱ្យងូត, កាលញ៉ាំង...ឱ្យងូត, កាលផ្ងូត ។

**នហាបេសិ** កិ. [ នហា+ណាបេ+ឦ.អជ្ជ.+ស.អា. ] ឱ្យងូតហើយ, ញ៉ាំង...ឱ្យងូតហើយ, ផ្ងូតហើយ ។

**នហាបេហិ** កិ. [ នហា+ណាបេ+ហិ.ប. ] ចូរឱ្យងូត, ចូរញ៉ាំង...ឱ្យងូត, ចូរផ្ងូត ។

**នហាយថ** កិ. [ នហា+យ+ថ.ប. ] ចូរងូត ។

**នហាយន្ត** គុ. [ នហា+យ+អន្ត ] កាលងូត, កំពុងងូត ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**នហាយន្តិ** ចិ. [ នហា+យ+អន្តិ-វ. ] ងូត ។

**នហាយមាន** គុ. [ នហា+យ+មាន ] កាលងូត, កំពុងងូត ។

**នហាយិតុកាម** គុ. [ នហាយិតុំ+កម+ណ ] អ្នកចង់ដើម្បីងូត ។

**នហាយិតុំ** អ. [ នហា+យ+ឥ-អា.+តុំ ] ដើម្បីងូត ។

**នហាយិស្សាមិ** កិ. [ នហា+យ+ឥ-អា.+ស្សាមិ-ភ. ] នឹងងូត ។

**នហារុវិនទ្ធ** គុ. [ នហារុ+វិនទ្ធ ] គឺសរសៃចងហើយ, -ចងឆ្នាក់ហើយ, ដែលចងដោយសរសៃ, រួបរឹតដោយសរសៃ (វិនទ្ធ<វិ+នហ+ត) ។

**នហុត** នបុំ. នហុត (ម៉ឺន) ។

**នាគ** បុំ. នាគ, ដំរី (អ្នកមិនធ្វើនូវអំពើអាក្រក់ ឬអ្នកមិនមានអំពើដំណាមក ក៏ហៅថា " នាគ " ដែរ; វិ. **ន អាគុំ ករោតីតិ> នាគោ; នត្ថិ អាគុំ ឯតស្សាតិ វា> នាគោ**) ។

**នាគគណបរិវុត** គុ. [ នាគគណ+បរិវុត ] គឺពួកនៃនាគចោមរោមហើយ, គឺហ្វូងនៃនាគហែហមហើយ; វិ. **នាគានំ គណោ> នាគគណោ; នាគគណេន បរិវុតោ> នាគគណ-បរិវុតោ** ។

**នាគត្ត** នបុំ. [ នាគ+ត្ត ] ភាវៈនៃ... ជានាគ; វិ. **នាគស្ស ភាវោ> នាគត្តំ** ។

**នាគទេវព្រហ្មានុភាវ** បុំ. [ នាគទេវព្រហ្ម+អានុភាវ ] អានុភាពនៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

នាគ និងទេវតា និងព្រហ្ម ។

**នាគភវន** នបុំ. [ នាគ+ភវន ] ភពនៃនាគ, ទីជាទីកើតនៃនាគ, លំនៅនៃនាគ (ភវន<ភូ+យុ = វិ. **ភវន្តិ ឯត្ថាតិ> ភវនំ**) ។

**នាគមាណវិកា** ឥ. [ នាគ+មាណវិកា ] នាងមាណវិកានៃនាគ, នាងនាគមាណវិកា ។

**នាគយោនិ** ឥ. [ នាគ+យោនិ ] កំណើតនៃនាគ, កំណើតនៃដំរី ។

**នាគរ** ពុំ. [ នគរ+ណ ] អ្នកនៅក្នុងនគរ, -ក្នុងក្រុង (អ្នកនគរ, អ្នកក្រុង); វិ. **នគរេ ចសន្តីតិ> នាគរា** ។

**នាគរាជ** ពុំ. [ នាគ+រាជ ] ស្ដេចនៃនាគ, នាគជាស្ដេច ។

**នាគលតាទន្តកដ្ឋ** នបុំ. [ នាគលតា+ទន្តកដ្ឋ ] ឈើសម្រាប់ជំរះនូវធ្មេញឈ្មោះនាគលតា, ឈើសម្រាប់ជំរះនូវធ្មេញគឺបុគ្គលធ្វើហើយដោយវល្លិខ្ទឹង, ឈើស្ទន់គឺបុគ្គលធ្វើហើយដោយវល្លិខ្ទឹង (ខ្លះថា វល្លិម្លូព្រៃ) ។

**នាគវត្តវណ្ណនា** ឥ. [ នាគវត្ត+វណ្ណ+យុ+អា_ឥ. ] កថាជាគ្រឿងពណ៌នានូវនាគវត្ត, -នូវសេចក្ដីនៃនាគវត្ត ។

**នាគវន** នបុំ. [ នាគ+វន ] ព្រៃនៃដើមខ្ទឹង, ព្រៃដ៏ដេរដាសដោយដើមខ្ទឹង ។

**នាគវិភវ** ពុំ. [ នាគ+វិភវ ] ភោគៈគឺបុគ្គលគប្បីសោយនៃនាគ, សម្បត្តិនៃនាគ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**នាគសរីរ** នពុំ. [ នាគ+សរីរ ] សរីរៈនៃនាគ ។

**នាគសុបណ្ណ** ពុំ. [ នាគ+សុបណ្ណ ] នាគនិងគ្រុឌ ។ . **វេមានិក-បេ្រត** ពុំ. នាគនិងគ្រុឌនិងប្រេតអ្នកមានវិមាន, នាគ និងគ្រុឌ និងវេមានិកប្រេត ។

**នាគសេនត្ថេរ** ពុំ. [ នាគសេន+ថេរ ] ព្រះថេរៈឈ្មោះនាគសេនៈ ។

**នាគានុភាវ** ពុំ. [ នាគ+អានុភាវ ] អានុភាពនៃនាគ ។

**នាដក** ពុំ. [ នដ+ណ្វុ ] (ជន) អ្នករាំ, អ្នករបាំ; វិ. **នច្ចតីតិ> នាដកោ** ។

**នាដកបរិវុត** គុ. [ នាដក+បរិវុត ] គឺអ្នករាំចោមរោមហើយ, គឺអ្នករបាំចោមរោមហើយ; វិ. **នាដកេហិ បរិវុតោ> នាដក-បរិវុតោ** ។

**នាដកិត្ថី** ឥ. [ នាដក+ឥត្ថី ] ស្ត្រីអ្នករាំ, ស្ត្រីអ្នករបាំ ។ . **បរិវុត** គុ. គឺស្ត្រីរបាំចោមរោមហើយ ។

**នាដបុត្ត** ពុំ. [ នាដ+បុត្ត ] នាដបុត្រ, បុត្រនៃជនអ្នករាំ, កូននៃអ្នករបាំ ។

**នាតិសង្ខេបនាតិវិត្ថារវស** ពុំ. [ នាតិសង្ខេប+នាតិវិត្ថារ+វស ] អំណាចនៃសេចក្តីមិនសង្ខេបពេកនិងមិនពិស្តារពេក ។

**នាថ** គុ. [ នាថ+អ ] ជាទីពឹង, ជាទីពុំនាក់ ។ ម្យ៉ាងទៀតអ្នកប្រាថ្នានូវសុខនិងប្រយោជន៍ដល់វេនេយ្យសត្វ; វិ. **នាថតិ វេនេយ្យានំ**

Websites: WatKhemaraRatanaram.org or WatKhmers.org

**ហិតសុខំ អាសីសតីតិ> នរោថា ។** អ្នកគ្រប់សង្កត់នូវសត្វទាំងពួង; រ៉ៃ. **នាថតិ សព្វសត្តេ ពុទ្ធសតិ អភិភវតីតិ> នរោថោ ។**

នានា អ. ផ្សេងៗ, វៀរ, លះបង់ ។

នានគ្គរស គុ. [ នានាអគ្គ+រស ] មានរសដ៏លើសផ្សេងៗ, មានរសដ៏ប្រសើរផ្សេងៗ ។ . **ភោជន** នថុំ. ភោជនមានរសដ៏លើសផ្សេងៗ, .ដ៏ប្រសើរផ្សេងៗ ។

នានប្បការ គុ. [ នានា+បការ ] មានប្រការផ្សេងៗ; រ៉ៃ. **នានាបការា យេសំ តេ> នានប្បការា ។** . **បណ្ណាការាភិហរណាវស** ថុំ. អំណាចនៃកិ.នាំទៅចំពោះ នូវគ្រឿងបណ្ណាការមានប្រការផ្សេងៗ, .នូវជំនូនមានប្រការផ្សេងៗ ។

នានាគច្ឆ ថុំ. [ នានា+គច្ឆ ] គុម្ពឈើផ្សេងៗ, គុម្ពផ្សេងៗ ។

នានាទារុ នថុំ. [ នានា+ទារុ ] ឈើផ្សេងៗ, ឧសផ្សេងៗ ។

នានាបុប្ផ នថុំ. [ នានា+បុប្ផ ] ផ្កាផ្សេងៗ, ផ្កាឈើផ្សេងៗ ។ . **ផលប្បដិមណ្ឌិត** គុ. ប្រដាប់ចំពោះដោយផ្កានិងផ្លែផ្សេងៗ ។

នានាផល នថុំ. [ នានា+ផល ] ផ្លែផ្សេងៗ ។

នានាភណ្ឌ នថុំ. [ នានា+ភណ្ឌ ] ភណ្ឌៈផ្សេងៗ, ទ្រព្យផ្សេងៗ ។

នានាភរណប្បដិមណ្ឌិត គុ. [ នានាភរណ+បដិមណ្ឌិត ] ប្រដាប់ចំពោះដោយអាភរណៈផ្សេងៗ, ប្រដាប់ចំពោះដោយគ្រឿងអម្ពរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ផ្សេងៗ ។

**នានារម្មណ** នថុំ. [ នានា+អារម្មណ ] អារម្មណ៍ផ្សេងៗ ។

**នានាវណ្ណ** គុ. [ នានា+វណ្ណ ] មានវណ្ណៈផ្សេងៗ, មានពណ៌ផ្សេងៗ ។

**នានាវិធ** គុ. [ នានា+វិធ ] មានប្រការផ្សេងៗ, មានបែបផ្សេងៗ; វិ. **នានា វិធា បការា យស្ស តំ> នានាវិធំ** ។

**នានាសមាបត្តិ** ឥ. [ នានា+សមាបត្តិ ] សមាបត្តិផ្សេងៗ ។

**នាភិ** ឥ. [ នភ+ឥ ឬណិ ] ដុំរទេះ, ផ្ចិត វិ. **នភតិ ហឹសតីតិ> នាភិ)** ។

**នាភិប្បមាណ** គុ. [ នាភិ+បមាណ ] មានផ្ចិតជាប្រមាណ, ត្រឹមផ្ចិត ។

**នាភិមណ្ឌល** នថុំ. [ នាភិ+មណ្ឌល ] មណ្ឌលនៃផ្ចិត ។

**នាម** នថុំ., និ. [ នម+ណ ] ធម្មជាតជាគ្រឿងដែលគេហៅ (នាម, ឈ្មោះ); វិ. **នមិយតេ វោហរិយតេ ឯតេនាតិ> នាមំ** ។ - **ករណទិវស** ថុំ., នថុំ. ថ្ងៃជាទីធ្វើនូវឈ្មោះ ។ - **ករណមង្គល** នថុំ. មង្គលជាទីធ្វើនូវឈ្មោះ ។ - **កាយ** ថុំ. នាមកាយ (កងនៃនាមធម៌, ពួកនៃនាមធម៌) ។ - **គ្គហណទិវស** ថុំ., នថុំ. ថ្ងៃជាទីកាន់យកនូវឈ្មោះ ។ - **គោត្តវស** ថុំ. អំណាចនៃនាមនិងគោត្រ ។ - **រូប** នថុំ. នាមនិងរូប, នាមរូប ។

**នារទ** អ.ន. ឈ្មោះនារទៈ ( តាបសឈ្មោះនារទៈ, អាមាត្យឈ្មោះនារទ,

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះពុទ្ធព្រះនាមនារទ) ។

**នារី** ឥ. [ នរ+ណ+ឦ.ឥ. ] នារី, នាងនារី (ស្ត្រី) ។ - **គណសម្បន្ន** គុ. អ្នកដល់ព្រមហើយដោយពួកនៃនារី, អ្នកមានពួកនៃនារីដល់ព្រមហើយ, បរិបូណ៌ហើយដោយក្រុមនៃនារី ។

**នាលកគ្គាម** ចុំ. [ នាលក+គាម ] ស្រុកឈ្មោះនាលកៈ, នាលកគ្រាម ។

**នាវជីយតិ** កិ. [ ន+អវជីយតិ ] មិនចាញ់វិញ ។

**នាវា** ឥ. [ នុ+ណ+អា.ឥ., ឧនៃនុ>អាវ ] ទូក, សំពៅ (វិ. **នេតីតិ> នាវា**) ។

**នាវាទិ** គុ. [ នាវា+អាទិ ] (យាន) មានទូកជាដើម; វិ. **នាវា អាទិ យេសំ តានិ> នាវាទីនិ** ។

**នាវាសេត** នចុំ. [ នាវា+សេត ] រយៈនៃទូក ។

**នាវិក** គុ. [ នាវា+ណិក ] (ជន) អ្នកជាធំក្នុងទូក, អ្នកឆ្លង (នូវទឹក) ដោយទូក (នាយទូក, នាយសំពៅ); វិ. **នាវាយំ ឥស្សរោ> នាវិកោ; នាវាយ តរតីតិ> នាវិកោ** ។

**នាសយិ** កិ. [ នស+ណយ+ឦ.អជ្ជ. ] ឱ្យវិនាសហើយ, ញុំាង...ឱ្យវិនាស ។

**នាសយិត្វា** កិ. [ នស+ណយ+ឥ.អា.+ត្វ.ហី. ] ឱ្យវិនាសហើយ, ញុំាង...ឱ្យវិនាសហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**នាសា** ឥ. [ នាសុ+អ ] ច្រមុះ (វិ. **នាសន្តិ អពាគ្គសទ្ទំ ករោន្តិ ឯតាយាតិ> នាសា**) ។

**នាសិត** គុ. [ នស+ណេ+ឥ_អា.+ត ] គឺ...ឱ្យវិនាសហើយ, ឱ្យខូចហើយ, ឱ្យបាត់ហើយ ។

**នាសេតិ** កិ. [ នស+ណេ+តិ_វ. ] ញុំាង...ឱ្យវិនាស, ឱ្យខូច, ឱ្យបាត់ ។

**នាសេតុកាម** គុ. [ នាសេតុំ+កម+ណ ] អ្នកចង់ដើម្បីញុំាង...ឱ្យវិនាស, អ្នកចង់ដើម្បីឱ្យវិនាស; វិ. **នាសេតុំ កាមេតីតិ> នាសេតុកាមោ** ។ នាសេតុំ+កាម = អ្នកមានប្រាថ្នាដើម្បីញុំាង...ឱ្យវិនាស; វិ. **នាសេតុំ កាមោ អស្សាតិ> នាសេតុកាមោ** ។

**នាសេតុំ** អ. [ នស+ណេ+តុំ ] ដើម្បីញុំាង...ឱ្យវិនាស ។

**នាសេថ** កិ. [ នស+ណេ+ថ_ប. ] ចូរញុំាង...ឱ្យវិនាស, ចូរឱ្យវិនាស ។

**នាសេន្តិ** កិ. [ នស+ណេ+អន្តិ_វ. ] ញុំាង...ឱ្យវិនាស, ឱ្យវិនាស ។

**នាសេយ្យ** កិ. [ នស+ណេ+ឯយ្យ_ស. ] គប្បីញុំាង...ឱ្យវិនាស ។

**នាសេស្សតិ** កិ. [ នស+ណេ+ស្សតិ_ភ. ] នឹងញុំាង...ឱ្យវិនាស ។

**នាសេហិ** កិ. [ នស+ណេ+ហិ_ប. ] ចូរញុំាង...ឱ្យវិនាស ។

**នាឡាគិរិ** អ. ន. ឈ្មោះនាឡាគិរី ។ . **ហត្ថី** ចុំ. ដំរីឈ្មោះនាឡាគិរី ។

